សៀវភៅកម្រងមេរៀនស្តីពី

# សិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌




ខែកញ្ញា ឆ្នាំ២០២២


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

Sweden
Sverige

People Change the World
Diakonia

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាពដែលប្រជាពលរដ្ឋគ្រប់រូបអាចទទួលបានសិទ្ធិមនុស្ស មូលដ្ឋានដែលខ្លួនមានពីកំណើត ទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។ ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបសត្វស្លាបពណ៌ស កំពុងហើរបំបែកចេញពីរង្វង់មូលពណ៌ផ្ទៃមេឃដែលមានន័យថា គឺជាការទាមទារសេរីភាពនៅកម្ពុជា។

គេហទំព័ររបស់សិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទសិទ្ធិ និងសេរីភាព និងទទួលពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនទីក្រុងប្រ៊ីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។

សម្រាប់ព័ត៌មានបន្ថែមអំពី ម.ស.ម.ក សូមចូលទស្សនា គេហទំព័រ www.cchrcambodia.org។

## អំពីគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

កម្រងមេរៀនស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មានចំនួន១៤ មេរៀន ដែលផ្តោតលើសិទ្ធិពាក់ព័ន្ធ ដូចជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិនៅស្ងៀម សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលជាដើម។ កម្រងមេរៀននេះ ចងក្រងឡើងជាផ្នែកមួយនៃគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ("គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌")។

គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាគម្រោងដំបូងតែមួយគត់នៅប្រទេសកម្ពុជាដែលមានគោលបំណងលើកកម្ពស់ និងការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងការអនុវត្តជាក់ស្តែង។ គម្រោងនេះមានគោលដៅបង្កើនអព្យាក្រឹត្យ និងឯករាជ្យនៃប្រព័ន្ធយុត្តិធម៌របស់ប្រទេសកម្ពុជា ដោយគាំទ្រសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការកម្ពុជា។ ដើម្បីសម្រេចគោលដៅនេះ គម្រោងមានគោលបំណងពីរ គឺបញ្ជ្រាបនូវគោលគំនិតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជន តាមរយៈលើកកម្ពស់ការយល់ដឹងពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងបង្កើនការអនុលោមតាមបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការ តាមរយៈការសង្កេតការណ៍សវនាការ។

## សេចក្ដីថ្លែងអំណរគុណ

ម.ស.ម.ក សូមថ្លែងអំណរគុណចំពោះអង្គការដាយកូនៀ (Diakonia) និងប្រទេសស៊ុយអែតសម្រាប់ការចូលរួមចំណែកដ៏សប្បុរសដែលធ្វើឱ្យមេរៀននេះកើតមានឡើង។ មាតិកានៃមេរៀននេះ គឺជាការទទួលខុសត្រូវរបស់ ម.ស.ម.ក ហើយមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការ Diakonia និងប្រទេសស៊ុយអែតនោះទេ។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមទាក់ទងនឹងមេរៀននេះ សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖

ផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរស័ព្ទ៖ ៨៥៥ (០) ២៣ ៧២ ៦៩ ០១

គេហទំព័រ៖ www.cchrcambodia.org ។

CC BY NC SA

### ចូលទៅកាន់កម្រងមេរៀន៖

https://sith.org/km/fair-trial-rights

ឬ ស្កេនទីនេះ

# មាតិកា


អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា.....I
សេចក្តីថ្លែងអំណរគុណ.....II
មាតិកា.....III
មេរៀនទី១៖សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌.....1
មេរៀនទី២៖សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិនៅស្ងៀម.....9
មេរៀនទី៣៖សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល.....16
មេរៀនទី៤៖សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់.....28
មេរៀនទី៥៖សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង.....33
មេរៀនទី៦៖សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិនិយាយជាមួយមេធាវី.....40
មេរៀទី៧៖សិទ្ធិការពារខ្លួនដោយខ្លួនឯងផ្ទាល់ ឬសិទ្ធិមានមេធាវី និងសិទ្ធិមានវត្តមាននៅពេលសវនាការ.....46
មេរៀនទី៨៖សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង.....57
មេរៀនទី៩៖សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ.....64
មេរៀនទី១០៖សិទ្ធិបង្ហាញភស្តុតាង.....68
មេរៀនទី១១៖សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ.....74
មេរៀនទី១២៖ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ.....82
មេរៀនទី១៣៖ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល.....88
មេរៀនទី១៤៖សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់.....92
គន្លងនិទ្ទេស.....103

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌



# មាតិកា

១.និយមន័យ........ 1
២.ប្រវត្តិសង្ខេបនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌........ 1
៣ . ក្របខ័ណ្ឌច្បាប់ ........ 3
៣.១. ច្បាប់អន្តរជាតិ ........ 3
៣.២. ច្បាប់ជាតិ........ 4
៤. សារៈសំខាន់ ........ 5
៥. ដែនកំណត់ ........ 6
៦.សំណួរ ........ 8

## ១.និយមន័យ

**សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌** គឺជាសិទ្ធិមនុស្ស ដែលជាសសរស្តម្ភស្នូលនៃប្រព័ន្ធយុត្តិធម៌។ សិទ្ធិនេះត្រូវអនុវត្តទាំងនៅក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណី និងដំណើរការនីតិវិធីព្រហ្មទណ្ឌ។ យោងតាមដំណើរការនីតិវិធីព្រហ្មទណ្ឌ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ផ្តល់សិទ្ធិឱ្យជនគ្រប់រូប ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងស្មើភាព ខណៈពេលដែលរដ្ឋកំពុងដំណើរការនីតិវិធីស្វែងរកថាតើជនមានពិរុទ្ធភាព ឬគ្មានទោស។

**សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌** រួមមាននូវសិទ្ធិផ្សេងៗមួយចំនួនរបស់បុគ្គលម្នាក់ៗ ដែលហៅកាត់រួមថា "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ដែលរួមបញ្ចូលនូវគ្រប់ដំណើរការផ្លូវច្បាប់ទាំងមូល ចាប់ពីពេលឃាត់ខ្លួនជនសង្ស័យក្នុងដំណាក់កាលដំបូង រហូតដល់ពេលបញ្ចប់ដំណើរការបណ្តឹងតវ៉ាជាស្ថាពរ។

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានចែងនៅក្នុងច្បាប់អន្តរជាតិ ជាពិសេស នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលធានានូវ **សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិទទួលការជំនុំជម្រះជាសាធារណៈដោយតុលាការឯករាជ្យ និងមិនលម្អៀង**។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏មានចែងលម្អិតបន្ថែមអំពីធាតុផ្សំផ្សេងៗនៃការជំនុំជម្រះដោយយុត្តិធម៌ ដែលរួមមានជាអាទិ៍នូវសិទ្ធិដូចខាងក្រោម៖



- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល
- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី
- សិទ្ធិមានមេធាវី
- សិទ្ធិមានវត្តមាននៅពេលសវនាការ
- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិទទួលបាននូវសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុច្បាស់លាស់ និង
- សិទ្ធិប្តឹងតវ៉ាទៅកាន់តុលាការជាន់ខ្ពស់លើផ្នែកអង្គហេតុ និងអង្គច្បាប់។

## ២.ប្រវត្តិសង្ខេបនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

នៅលើឆាកអន្តរជាតិ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នេះត្រូវបានបញ្ជាក់ និងទទួលស្គាល់ជាផ្លូវការថាជាសិទ្ធិមូលដ្ឋានរបស់មនុស្ស តាមរយៈការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ក្នុងមហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៨ ដែលជាឯកសារដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រនៃសិទ្ធិមនុស្ស។ អង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើងដោយសហគមន៍អន្តរជាតិនៅក្នុងឆ្នាំ១៩៤៥ ដើម្បីឆ្លើយតបទៅនឹងអំពើឃោរឃៅនានាដែលបានប្រព្រឹត្តឡើងកាលពីក្នុងអំឡុងពេលសង្គ្រាមលោកលើកទីពីរ។ សេចក្តីប្រកាសជា

សកលស្តីពីសិទ្ធិមនុស្ស គឺជាសន្ធិសញ្ញាដំបូងគេបង្អស់ដែលអង្គការសហប្រជាជាតិ បានអនុម័តឡើង ដោយមានកំណត់នូវសិទ្ធិជាមូលដ្ឋានដែលត្រូវការពារជាសកល។[1] រដ្ឋទាំងអស់ដែលមានបំណងចង់ក្លាយជាសមាជិករបស់អង្គការសហប្រជាជាតិ ត្រូវតែគោរពតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

កាលពីឆ្នាំ១៩៦៦ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នេះ ត្រូវបានបញ្ជាក់ឡើងជាថ្មីម្តងទៀត ជាមួយនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលជាសិទ្ធិមូលដ្ឋានផ្សេងៗ នៅក្នុងឯកសារមួយផ្សេងទៀត ដែលអង្គការសហប្រជាជាតិបានអនុម័តៈ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបញ្ជាក់បន្ថែមទៀតអំពីសិទ្ធិផ្សេងៗ ដែលក្នុងនោះក៏មាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ។

បច្ចុប្បន្ន អង្គការសហប្រជាជាតិមានរដ្ឋជាសមាជិកចំនួន ១៩៣ ប្រទេស ដែលរដ្ឋសមាជិកទាំងអស់ត្រូវបានភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងត្រូវមានកាតព្វកិច្ចអន្តរជាតិក្នុងការគោរពសិទ្ធិជាមូលដ្ឋានដែលខ្លួនអនុម័តទទួលស្គាល់ រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទៀតផង។ លើសពីនេះទៅទៀត រដ្ឋសមាជិកចំនួន ១៧៣ រួមមានប្រទេសកម្ពុជាផងដែរដែលបានផ្តល់សច្ចាប័នទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ ដូចមានចែងនៅក្នុងបញ្ញត្តិនៃកតិកាសញ្ញានេះ ហើយត្រូវមានកាតព្វកិច្ចលើកតម្កើងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់ ដែលត្រូវបានទទួលស្គាល់នៅក្នុងសន្ធិសញ្ញានេះ។

ចាប់តាំងពីពេលនោះមក សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានទទួលស្គាល់ក្នុងលក្ខខណ្ឌស្រដៀងគ្នានេះ ដូចជានៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងនៅក្នុងសន្ធិសញ្ញាផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ក៏ដូចជាលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងតំបន់ផ្សេងទៀតផងដែរ រួមមាន អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៥០ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៦៩ ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ឆ្នាំ១៩៨១ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩ ឬ ធម្មនុញ្ញអឺរ៉ុបស្តីពីសិទ្ធិជាមូលដ្ឋានរបស់សហភាពអឺរ៉ុប ឆ្នាំ២០០០។

[1] អង្គការសហប្រជាជាតិ "សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ" https://www.un.org/en/about-us/universal-declaration-of-human-rights អង្គការសហប្រជាជាតិ "ប្រវត្តិនៃសេចក្តីប្រកាស" https://www.un.org/en/about-us/udhr/history-of-the-declaration។

## ៣ . ក្របខ័ណ្ឌច្បាប់

### ៣.១. ច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសិទ្ធិមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកលនៅក្នុងច្បាប់អន្តរជាតិ រួមមាន នៅក្នុង **សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** និង**អនុសញ្ញាស្តីពីសិទ្ធិកុមារ**។ លិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សអន្តរជាតិទាំងបីនេះ អាចអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់កម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញកម្ពុជា")។

មាត្រា ១០ នៃ **សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស៖** *"មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នា និងពេញលេញក្នុងការសុំឱ្យតុលាការឯករាជ្យ និងមិនលម្អៀង ត្រួតពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចបានលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់បទព្រហ្មទណ្ឌនានា។*





មាត្រា ១៤ (១) នៃ **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖** *"ជនគ្រប់រូបត្រូវមានសិទ្ធិស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបានបង្កើតឡើងដោយច្បាប់ [...]"។*

មាត្រា ៤០ (២)(ខ)(iii) នៃ **អនុសញ្ញាស្តីពីសិទ្ធិកុមារ៖** "[...] *ក្នុងទិសដៅនេះ និងដោយពិចារណាទៅលើបញ្ញត្តិនៃលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ រដ្ឋភាគីត្រូវធានា ជាពិសេសថា [...] (ខ) កុមារដែលជាប់សង្ស័យ ឬជាប់ចោទថាបានរំលោភច្បាប់ព្រហ្មទណ្ឌយ៉ាងហោចណាស់ ត្រូវទទួលបាននូវការធានាដូចតទៅ៖* [..] (iii) *ទទួលបានការដោះស្រាយដោយគ្មានការយឺតយ៉ាវពីសំណាក់អាជ្ញាធរ ឬស្ថាប័នតុលាការដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងនៅក្នុងការជំនុំជម្រះដ៏យុត្តិធម៌មួយ ស្របតាមច្បាប់ និងដោយមានជំនួយផ្នែកច្បាប់ ឬ ជំនួយសមស្របផ្សេងៗទៀត ហើយប្រសិនបើមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់កុមារនោះ ជាពិសេស ដោយយោងទៅលើអាយុ ឬស្ថានភាពរបស់កុមារ ដោយមានវត្តមានរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារផង* [...]"។



## ៣.២. ច្បាប់ជាតិ



សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក៏ត្រូវបានធានានៅក្នុងប្រទេសកម្ពុជាផងដែរ តាមរយៈបញ្ញត្តិទូទៅ និងជាក់លាក់ ដែលមានចែងនៅក្នុងលិខិតុបករណ៍មួយចំនួនដូចជា រដ្ឋធម្មនុញ្ញកម្ពុជា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (“ក្រមព្រហ្មទណ្ឌ”) ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ សិទ្ធិនេះក៏ត្រូវបានការពារក្រោមច្បាប់ស្ដីយុត្តិធម៌អនីតិជន ដែលបង្កើតនូវទម្លាប់ និងនីតិវិធីនៅក្នុងដោះស្រាយជាមួយកុមារទំនាស់នឹងច្បាប់។

- **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ៖** *“ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។*

  *ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។*

  *ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តដោយត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវបានហាមឃាត់មិនឱ្យធ្វើឡើយ។ អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់។*

  *ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្ដី តាមផ្លូវចិត្តក្ដី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។*

  *វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។*

  *ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។*

  *ជនគ្រប់រូប មិនសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។”*

- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងលម្អិតអំពីរបៀបប្រព្រឹត្តចំពោះជនសង្ស័យ។ ជាពិសេស ក្រមព្រហ្មទណ្ឌ មានចែងអំពីតួនាទី និងការទទួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្ដី ចាប់ពីពេលចាប់ផ្ដើមការស៊ើបអង្កេតរហូតដល់ពេលចាប់ខ្លួន និងការទទួលខុសត្រូវព្រហ្មទណ្ឌទាំងស្រុង និងគោលការណ៍នៃការកាត់ទោស។



- **មាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ៖ សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី៖** *"អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖*
    - *សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី*
    - *សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយចម្លើយដាក់បន្ទុកលើខ្លួនឯង*
    - *សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន*
    - *សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល*
    - *សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់*
    - *សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់តំណាងដែលច្បាប់បានកំណត់*
    - *សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី*
    - *សិទ្ធិឱ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តីប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន*
    - *សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់*



    - *សិទ្ធិបង្ហាញភស្តុតាង*
    - *សិទ្ធិស្នើសុំឱ្យហៅសាក្សី និងសួរសាក្សី*
    - *សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ*
    - *សិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ*
    - *សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស*
    - *សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។"*

## ៤. សារៈសំខាន់



ការជំនុំជម្រះដោយយុត្តិធម៌ គឺពិតជាមានសារៈសំខាន់ជាសារវន្តដើម្បីការពារសិទ្ធិជនជាប់ចោទនិងជនរងគ្រោះព្រមទាំង ដើម្បីជានាឱ្យបាននូវ**រដ្ឋបាលយុត្តិធម៌ប្រកប ដោយភាពត្រឹមត្រូវ**។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌គឺជាគន្លឹះក្នុងការ**ការពារសិទ្ធិមនុស្ស** និងនីតិរដ្ឋ។[2]

យោងតាមគោលការណ៍នីតិរដ្ឋ គ្មានជនណាម្នាក់អាចត្រូវបានផ្តន្ទាទោសបានឡើយ លុះត្រាតែតុលាការមានសមត្ថកិច្ច និងមិនលម្អៀងបានសម្រេចថាជននោះបានប្រព្រឹត្តល្មើសច្បាប់។ នីតិរដ្ឋតម្រូវឱ្យ

[2] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "សេចក្តីពន្យល់ទូទៅលេខ ៣២ – មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងអង្គជំនុំជម្រះ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (CCPR/C/GC/៣២ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧) កថាខណ្ឌ ២២ https://www.refworld.org/docid/478b2b2f2.html ។

តុលាការជានាថា ច្បាប់ត្រូវបានអនុវត្តដោយស្មើភាពគ្នា និងដោយគ្មានការរើសអើង នេះរួមបញ្ចូលទាំងការធានាថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានអនុវត្តនៅក្នុងគ្រប់សំណុំរឿងទាំងអស់។[3]

ភាពយុត្តិធ៌មត្រូវមាននៅគ្រប់ដំណើរការតុលាការទាំងអស់ ដោយធានាឱ្យបាននូវភាពយុត្តិធម៌ជាអាទិភាពចម្បង។ មានតែពិរុទ្ធជនប៉ុណ្ណោះដែលត្រូវបានផ្តន្ទាទោស និងកាត់ទោសឱ្យជាប់ពន្ធនាគារ ហើយជនគ្មានទោសត្រូវមានសិទ្ធិចូលរួមនៅក្នុងសង្គមដោយសេរីដោយគ្មានបុរេវិនិច្ឆ័យ។[4] ហេតុដូច្នេះ ការមិនគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ អាចនាំឱ្យមានការសម្រេចក្តីដោយអយុត្តិធម៌ ជាពិសេសការផ្តន្ទាទោសដោយមិនត្រឹមត្រូវ។

## ៥. ដែនកំណត់

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវតែអនុវត្តដោយគ្មានករណីលើកលែងឡើយ។ ជនគ្រប់រូបដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គ្រប់ពេលវេលា រួមទាំងនៅក្នុងអំឡុងស្ថានភាពនៃគ្រាអាសន្ន និងស្ថិតក្នុងស្ថានភាពមានជម្លោះប្រដាប់អាវុធ។[5]

យោងតាមគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ទោះបីជាមាត្រា ១៤ មិនស្ថិតនៅក្នុងចំណោមសិទ្ធិបដិប្បញ្ញត្តិ[6] ដែលមានចែងក្នុងមាត្រា៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (បដិប្បញ្ញត្តិនៅក្នុងអំឡុងពេលមានស្ថានភាពនៃគ្រាអាសន្ន) ក៏ដោយ ក៏ករណីលើកលែងទូទៅនូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌គឺមិនអាចបដិសេធបានឡើយ ហើយត្រូវតែអនុវត្តឱ្យស្របតាមគោលបំណងនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ អាស្រ័យហេតុនេះ ការអនុវត្តទាំងឡាយណា ដែលងាកចេញពីគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ត្រូវបានហាមឃាត់គ្រប់ពេលវេលា។[7]

---

[3] ម.ស.ម.ក "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រ ១០, https://sithi.org/medias/files/projects/tmp/publication/cchr-ftr-and-trial-monitoring-handbook-feb-eng2012-02-13.pdf ។

[4] ដូចខាងលើ។

[5] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ច្បាប់បោះពុម្ពផ្សាយលើកទីពីរ (ឆ្នាំ២០១៤) ទំព័រ xvi។

[6] សិទ្ធិដែលមិនអាចបដិប្បញ្ញត្តិ៖ សិទ្ធិដែលមិនអាចព្យួរទុកបានដោយរដ្ឋាភិបាលនៅក្នុងកាលៈទេសៈនៃ"រដ្ឋស្ថិតក្នុងគ្រាអាសន្នក្រោមមាត្រា ៤ នៃ ក.ស.អ.ព.ន។

[7] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "សេចក្តីពន្យល់ទូទៅលេខ ៣២ – មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងអង្គជំនុំជម្រះ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (CCPR/C/GC/៣២ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧) កថាខណ្ឌ

ទោះយ៉ាងណាក៏ដោយ ករណីលើកលែងចំពោះប្រការដាក់លាក់នៃមាត្រា១៤ អាចទទួលយកបាន។[8] ជាការពិត សិទ្ធិផ្សេងៗដែលមាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌គឺមិនដាច់ខាតនោះទេ ហើយអាចមានកម្រិតកំណត់នៅក្នុងកាលៈទេសៈមួយចំនួន។ កម្រងមេរៀនខាងក្រោមនេះគ្របដណ្តប់នូវសិទ្ធិសំខាន់ៗដែលមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងផ្តល់នូវព័ត៌មានលម្អិតបន្ថែមអំពីដែនកំណត់ដែលអាចអនុវត្តចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

---

៥ និង ៦ https://www.refworld.org/docid/478b2b2f2.html "គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "សេចក្តីពន្យល់ទូទៅលេខ ២៩–មាត្រា ៤៖ បដិប្បញ្ញត្តិក្នុងស្ថានភាពនៃគ្រាមានអាសន្ន" (CCPR/C/២១/កំណែប្រែ ១/សេចក្តីបន្ថែម ១១ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១) កថាខណ្ឌ ១១ https://www.refworld.org/docid/453883fd1f.html ។

[8] ដូចខាងលើ កថាខណ្ឌ ៥។

## ៦.សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាសិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិ ជាសសរស្តម្ភនៃប្រព័ន្ធយុត្តិធម៌។ សិទ្ធិនេះ មានសារៈសំខាន់ដើម្បីជានានីតិរដ្ឋ និងការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ។

☐ក. ត្រូវ ☐ខ. ខុស

២. ការជំនុំជម្រះដោយយុត្តិធម៌អនុវត្តបានតែចំពោះនីតិវិធីព្រហ្មទណ្ឌតែប៉ុណ្ណោះ។

☐ក. ខុស ☐ខ. ត្រូវ

៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវតែអនុវត្តដោយមានករណីលើកលែង ដូចជានៅអំឡុងស្ថានភាពនៃប្រទេសស្ថិតក្នុងគ្រាអាសន្ន និងស្ថិតក្នុងស្ថានភាពមានជម្លោះប្រដាប់អាវុធ។

☐ក. ខុស ☐ខ. ត្រូវ

៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គ្របដណ្តប់លើសិទ្ធិមួយចំនួនដូចខាងក្រោម៖

☐ក. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និង ☐ខ. សិទ្ធិទទួលសញ្ជាតិ

☐គ. សិទ្ធិទទួលបានការអប់រំ ☐ឃ. សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

☐ង. ចម្លើយ ក, ខ, និង គ ☐ច. ចម្លើយ ក និង ឃ

៥. តើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានចែងក្នុងច្បាប់ជាតិណាខ្លះ?

☐ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់សញ្ជាតិ

☐ខ. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ក្រមនីតិវិធីព្រហ្មទណ្ឌ, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងច្បាប់អប់រំ

☐គ. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ក្រមនីតិវិធីព្រហ្មទណ្ឌ, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, ក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា

៦. តើលិខិតុបករណ៍អន្តរជាតិណាដែលអះអាង និងទទួលស្គាល់ជាផ្លូវការលើកដំបូងចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលជាគោលការណ៍មូលដ្ឋាននៃសិទ្ធិមនុស្ស?

☐ក. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

☐ខ. អនុសញ្ញាស្តីពីសិទ្ធិកុមារ

☐គ. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

☐ឃ. សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស

៧. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានធានាចាប់តាំងពីដំណាក់កាលនីតិវិធីព្រហ្មទណ្ឌដំបូងនៃការឃាត់ខ្លួនជនសង្ស័យរហូតដល់ការប្តឹងតវ៉ាត្រូវបានបញ្ចប់។

☐ក. ត្រូវ ☐ខ. ខុស

# សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
# និង
# សិទ្ធិនៅស្ងៀម



# មាតិកា


១. និយមន័យ ........ 9
១.១. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........ 9
១.២. សិទ្ធិនៅស្ងៀម ........ 10
២. ក្របខ័ណ្ឌច្បាប់ ........ 11
២.១. ច្បាប់អន្តរជាតិ ........ 11
២.២. ច្បាប់ជាតិ ........ 12
៣. សារៈសំខាន់ ........ 12
៤. ដែនកំណត់ ........ 14
៥. សំណួរ ........ 15

# ១. និយមន័យ

## ១.១. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស មានន័យថាជនជាប់ចោទទាំងអស់ ត្រូវទទួលបានការសន្មតថា គ្មានទោសរហូតទាល់តែមានភស្តុតាងបញ្ជាក់ថាមានពិរុទ្ធភាពស្របតាមច្បាប់ និងតាមរយៈសេចក្តីសម្រេចបានចូលជាស្ថាពរ។

ការសន្មតទុកថាគ្មានទោស អនុវត្តនៅគ្រប់នីតិវិធីតុលាការទាំងអស់ពោលគឺ ចាប់ពីដំណាក់កាលឃាត់ខ្លួនដំបូងរហូតដល់រយៈពេលនៃការស៊ើបអង្កេតបទល្មើស និងដំណើរការសវនាការរហូតដល់ដំណើរការបញ្ចប់នៃការប្តឹងតវ៉ាជាស្ថាពរផងដែរ។[1]

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ចែងថា៖



- ចៅក្រមត្រូវមានភាពមិនលម្អៀង និងមិនត្រូវមានបុរេវិនិច្ឆ័យទៅលើសំណុំរឿងឡើយ។
- មន្ត្រីសាធារណៈ (រួមទាំងមន្ត្រីនគរបាល និងព្រះរាជអាជ្ញា) មិនត្រូវចេញសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងពិរុទ្ធភាព ឬការគ្មានទោសរបស់ជនជាប់ចោទនៅមុនពេលដែលសវនាការបានបញ្ចប់ឡើយ។
- អាជ្ញាធរមិនត្រូវអនុញ្ញាតឱ្យប្រព័ន្ធផ្សព្វផ្សាយមានឥទ្ធិពលទៅលើលទ្ធផល នៃសំណុំរឿងសម្រាប់ការវិនិច្ឆ័យទៅលើពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទឡើយ។
- គោលបំណងនៃបណ្តឹងអាជ្ញាគឺ ដើម្បីពិនិត្យរកមើលអត្ថិភាពបទល្មើស និងបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនល្មើស។ ប្រសិនបើមានវិមតិសង្ស័យទៅលើកំហុសរបស់ជនជាប់ចោទ ពួកគេត្រូវរកឃើញថាមិនមានកំហុស។
- មិនគួរសន្មតពិរុទ្ធភាពជនជាប់ចោទដោយឈរលើសូចនាករខាងក្រៅឡើយ។

ការហាមឃាត់ សូចនាករខាងក្រៅនៃពិរុទ្ធភាព រួមបញ្ចូលសិទ្ធិរបស់ជនជាប់ចោទក្នុងការស្លៀកសម្លៀកបំពាក់ស៊ីវិលនៅអំឡុងពេលដំណើរការសវនាការ និងមិនត្រូវដាក់ច្រវាក់ ឬជាប់ខ្នោះនៅពេលជំនុំជម្រះ។ ជនជាប់ចោទគ្រប់រូបមានសិទ្ធិត្រូវបាននាំខ្លួនទៅកាន់តុលាការក្នុងរូបភាព **សេចក្តីថ្លៃថ្នូរក្នុងនាមជាជនមានសេរីភាព និងគ្មានទោស។**

[1] ការិយាល័យឧត្តមស្នងការ "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី I), ជំពូកទី ៦" ទំព័រ ២១៩ https://www.ohchr.org/Documents/Publications/training9chapter6en.pdf; Amnesty International "សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌" (ឆ្នាំ១៩៩៨) ទំព័រ ១២៥ ផ្នែកទី ១៥.២ https://www.amnesty.org/download/Documents/8000/pol300022014en.pdf (អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌)។

ជាប់ចោទគ្រប់រូបមានសិទ្ធិត្រូវបាននាំខ្លួនទៅកាន់តុលាការក្នុងរូបភាព **សេចក្តីថ្លៃថ្នូរក្នុងនាមជាជនមានសេរីភាព និងគ្មានទោស។**



នៅពេលជនជាប់ចោទ ត្រូវបានគេបង្ខំឱ្យចូលខ្លួនក្នុងសវនាការក្នុងឯកសណ្ឋានពន្ធនាគារ ឬជាប់ខ្នោះ ឬជាប់ច្រវាក់ នោះអាចនាំឱ្យមានការយល់ថាជនជាប់ចោទមានទោស ឬជាឧក្រិដ្ឋជនដ៏គ្រោះថ្នាក់ ហើយអាចបង្កហានិភ័យ ដែលអាចជះឥទ្ធិពលដោយចេតនា ឬអចេតនា ដល់ការវិនិច្ឆ័យរបស់ចៅក្រមជំនុំជម្រះក្នុងនីតិវិធីជំនុំជម្រះ និងលទ្ធផលនៃសំណុំរឿង។

កត្តាផ្សេងទៀតដែលមិនគួរបង្កើតជាសូចនាករនៃពិរុទ្ធភាពគឺរយៈពេល និងកម្រិតនៃការឃុំខ្លួនបណ្តោះអាសន្ន។ នៅពេលការឃុំខ្លួនបណ្តោះអាសន្នមានរយៈយូរពេក នោះអាចប៉ះពាល់ទៅដល់ការសន្មតទុកថាគ្មានទោស។[2] នៅក្នុងន័យនេះ ការបដិសេធឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ឬការរកឃើញទំនួលខុសត្រូវនៅក្នុងដំណើរការសំណុំរឿងរដ្ឋប្បវេណីមិនត្រូវចាត់ទុកថាជាការបង្ហាញអំពីពិរុទ្ធភាពនោះទេ។[3]

### ១.២. សិទ្ធិនៅស្ងៀម



សិទ្ធិនៅស្ងៀម ផ្សារភ្ជាប់ជាមួយនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។[4] សិទ្ធិនេះជានាថាបុគ្គលម្នាក់ៗមានសិទ្ធិមិនឆ្លើយទៅនឹងសំណួររបស់មន្ត្រីអនុវត្តច្បាប់ ឬមន្ត្រីតុលាការ។ សិទ្ធិនេះ**ការពារពីការឆ្លើយដាក់បន្ទុកលើខ្លួនឯង។** សិទ្ធិនេះ ក៏មានបញ្ចូលនូវលក្ខខណ្ឌដែលថា ការផ្តល់មតិយោបល់ ឬការជៀតជ្រែកដែលគ្មានអំណោយផល មិនត្រូវធ្វើឡើងដោយតុលាការនោះទេ ដោយសារតែជនជាប់ចោទបានបដិសេធមិនឆ្លើយសំណួរនៅមុនពេល ឬនៅអំឡុងពេលសវនាការ។

បើទោះបីជាជនជាប់ចោទមិននិយាយអ្វីទាល់តែសោះ និងមិនបង្ហាញភស្តុតាងអ្វីក៏ដោយ ពួកគេត្រូវបានដោះលែង ប្រសិនបើអយ្យការមិនអាចបង្ហាញភស្តុតាង ដែលជាបន្ទុកភស្តុតាងចាំបាច់សម្រាប់ការចោទប្រកាន់ទេនោះ។ និយាយម្យ៉ាងទៀត ជនជាប់ចោទមិនចាំបាច់ត្រូវបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថា ពួកគេគ្មានទោសនោះទេ។

សិទ្ធិនៅស្ងៀមត្រូវតែគោរពនៅពេលដំណើរការនីតិវិធីផ្លូវច្បាប់ រួមទាំងដំណាក់កាលស៊ើបអង្កេតនៅពេលជនរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌត្រូវបានសាកសួរដោយនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ឬចៅក្រម

---

[2] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ៖ សេចក្តីពន្យល់ទូទៅ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី និងទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (CCPR/C/GC/32, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០២) កថាខណ្ឌ ៣០, https://www.refworld.org/docid/478b2b2f2.html ។ (គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅ ៣២)។

[3] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅ ៣២ កថាខណ្ឌ ៣០ ។

[4] ម.ស.ម.ក, "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រ ២៣ https://sithi.org/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook ។

ស៊ើបសួរ និងនៅក្នុងដំណាក់កាលសវនាការផងដែរ នៅពេលដែលជនរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌត្រូវបានចៅក្រម ឬព្រះរាជអាជ្ញាសួរសំណួរ។[5] ជនសង្ស័យត្រូវទទួលបានការប្រាប់អំពីសិទ្ធិនៅស្ងៀមរបស់ខ្លួននៅដំណាក់កាលនីតិវិធីផ្លូវច្បាប់ ពោលគឺ ចាប់តាំងពីពេលដែលពួកគេត្រូវបានឃាត់ ឬចាប់ខ្លួនតទៅ។

## ២. ក្របខ័ណ្ឌច្បាប់

### ២.១. ច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការសន្និតទុកជាមុនថាគ្មានទោសត្រូវបានការពារយ៉ាងច្បាស់ដោយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមមានដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ("ស.ស.ស.ម") កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") និងអនុសញ្ញាស្តីពីសិទ្ធិកុមារ("អ.ស.ក")ផងដែរ។ លិខិតបទដ្ឋានទាំងនេះគឺអនុវត្តដោយផ្ទាល់ទៅក្នុងច្បាប់នៃប្រទេសកម្ពុជា តាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទោះបីជាសិទ្ធិនៅស្ងៀមមិនត្រូវបានធានាដោយលិខិតបទដ្ឋានអន្តរជាតិក៏ដោយ ប៉ុន្តែសិទ្ធិនេះត្រូវបានទទួលស្គាល់ថាត្រូវបានបញ្ចូលនៅក្នុងការធានាចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាពិសេស សិទ្ធិទទួលបានការសន្និតទុកជាមុនថាគ្មានទោស និងសិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង។[6]



**មាត្រា ១១ នៃ ស.ស.ស.ម៖** *"ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនាការសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីការពារសិទ្ធិជនជាប់ចោទ ពីបទល្មើសព្រហ្មទណ្ឌ។"*



**មាត្រា ១៤ (២) នៃ ក.អ.ស.ព.ន៖** *"ជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតថាគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ដោយច្បាប់"។*



**មាត្រា ៤០ នៃ អ.ស.ក៖** *"ដើម្បីអនុវត្តចំណុចនេះបាន និងដោយយោងតាមបទប្បញ្ញត្តិអន្តរជាតិពាក់ព័ន្ធ ភាគីរដ្ឋ ជាពិសេស ត្រូវធានាថា [...] (i) ទទួលបានការសន្និតថាគ្មានទោសរហូតទាល់តែបទល្មើសនោះត្រូវបានបញ្ជាក់ស្របតាមច្បាប់"*

[5] មជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍន៍សង្គម (CSD) "របាយការណ៍ប្រចាំឆ្នាំស្តីពីគម្រោងឃ្លាំមើលតុលាការ" ខែកុម្ភៈ ឆ្នាំ២០០៧។

[6] សូមមើល គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "សេចក្តីសន្និដ្ឋានអំពីការអង្កេតការណ៍៖ ប្រទេសបារាំង (ឯកសារអង្គការសហប្រជាជាតិCCPR/C/FRA/CO/៤ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨) កថាខណ្ឌ ១៤ https://undocs.org/en/CCPR/C/FRA/CO/4។

## ២.២. ច្បាប់ជាតិ

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិនៅស្ងៀម ត្រូវបានការពារដោយមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") និងមាត្រា៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។



**រដ្ឋធម្មនុញ្ញ មាត្រា ៣៨៖** *"ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។*



**មាត្រា ៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន៖** *"គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជនត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ [...]សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។"*

## ៣. សារៈសំខាន់



**សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស** គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានទទួលស្គាល់ថាជាសិទ្ធិមូលដ្ឋាន និងបានកំណត់យ៉ាងច្បាស់[7] ហើយក៏ជាធាតុផ្សំដ៏សំខាន់នៃនីតិរដ្ឋផងដែរ។[8]

សិទ្ធិនេះធានាថា ពុំមាននរណាម្នាក់ត្រូវបានដាក់ទោសទណ្ឌតាមទំនើងចិត្ត ចំពោះអំពើ ដែលពួកគេមិនបានប្រព្រឹត្ត ដោយតម្រូវឱ្យបង្ហាញភស្តុតាងបញ្ជាក់ក្នុងតុលាការអំពីសកម្មភាពប្រព្រឹត្តមិនត្រឹមត្រូវដែលបានចោទប្រកាន់នោះ មុនពេលការដាក់ទោសទាន់ត្រូវបានធ្វើឡើង។[9]

---

[7] ម.ស.ម.ក "សៀវភៅណែនាំស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ២០១២) https://sithi.org/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook ។

[8] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្ដីពីការជំនុំជម្រះដោយយុត្តិធម៌ ការបោះពុម្ពផ្សាយលើកទីពីរ" (ឆ្នាំ២០១៤) ទំព័រ ១២៥, https://sithi.org/tmp/publication/view/2014-04-10-fair-trial-manual-published-by-amnesty-international ។

[9] ម.ស.ម.ក "សៀវភៅណែនាំស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រ ១២, https://sithi.org/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook។

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ជាបន្ទុករបស់ស្ថាប័នអយ្យការក្នុងការបង្ហាញពីមូលដ្ឋានក្នុងការចោទប្រកាន់[10] និងធានាថាពុំមានបទល្មើសណាមួយត្រូវបានសន្មតទុកនោះទេ រហូតទាល់តែការចោទប្រកាន់នោះត្រូវបានបញ្ជាក់ថាមានពិរុទ្ធភាពហួសពីវិមតិសង្ស័យ។ ប្រសិនបើអយ្យការមិនបានបញ្ជាក់ថាការចោទប្រកាន់នោះគឺត្រឹមត្រូវទេ បុគ្គលនោះគឺពុំមានកំហុសដូចការចោទប្រកាន់ឡើយ។ នៅក្នុងសំណុំរឿងភាគច្រើន អយ្យការត្រូវបញ្ជាក់ថា ជនជាប់ចោទគឺមានពិរុទ្ធភាពហួសពីវិមតិសង្ស័យ។ ប្រសិនបើនៅតែមានវិមតិសង្ស័យ នោះការសង្ស័យនោះនឹងផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ[11] ដែលត្រូវឱ្យរួចផុតពីការចោទ ប្រកាន់។



សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ក៏ជាប្រភពនៃសិទ្ធិផ្សេងៗទៀតផងដែរ ជាពិសេស សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង សិទ្ធិនៅស្ងៀម និងការធានាឱ្យនៅក្រៅឃុំ និងការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន។[12] ករណីលើកលែងអំពីការឃុំខ្លួនបណ្តោះអាសន្នមាននៅក្នុងការសន្មតទុកជាមុនថាគ្មានទោសដែរ ដែលទាមទារថា ការដកហូតសេរីភាពកើតឡើងតែនៅក្រោមកាលៈទេសៈចង្អៀត និងពេលមានការចាំបាច់តឹងរឹងប៉ុណ្ណោះ។

សិទ្ធិនៅស្ងៀម ពិតជាមានសារៈសំខាន់ក្នុងការការពារការសន្មតទុកជាមុនថាគ្មានទោស ដោយសារតែសិទ្ធិនេះការពារសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង (ឬសិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង) សិទ្ធិនេះ ក៏មានទំនាក់ទំនងជាមួយនឹងសិទ្ធិសន្មតទុកជាមុនថាគ្មានទោសផងដែរ ហើយសិទ្ធិនេះត្រូវបានបង្កើតឡើងដើម្បីការពារជនជាប់ចោទពីការបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង និង/ឬសារភាពថាមានពិរុទ្ធភាព។

ជាលទ្ធផល ការមិនគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ បានបង្កើតជាហានិភ័យសម្រាប់ជនជាប់ចោទ ដែរត្រូវបានគេមើលឃើញថាមានពិរុទ្ធ ឬជាជនដ៏គ្រោះថ្នាក់ និងអាចជះឥទ្ធិពលទាំងដោយចេតនា ឬអចេតនាទៅលើលក្ខណៈ ដំណើរការនីតិវិធីលើនីតិវិធី ការវិនិច្ឆ័យ និងលទ្ធផលនៃសំណុំរឿង។ ហើយបញ្ហានេះក៏អាចឈានទៅដល់ការចោទប្រកាន់មិនត្រឹមត្រូវផងដែរ។ ដូច្នេះការធានាថា សិទ្ធិទាំងអស់នេះត្រូវបានគោរព គឺជាមូលដ្ឋានក្នុងការធានានូវការជំនុំជម្រះដោយយុត្តិធម៌សម្រាប់ជនជាប់ចោទ។

[10] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ ៣២ កថាខណ្ឌ ៣០។

[11] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ ៣២ កថាខណ្ឌ ៣០, តុលាការអឺរ៉ុប៖ សំណុំរឿង Barberà, Messegué និង Jabardo ទល់នឹងប្រទេសអេស្ប៉ាញ (១០៥៩០/៨៣) (ឆ្នាំ១៩៨៨) ទ៧៧ សំណុំរឿង Telfner ទល់នឹងប្រទេសអូទ្រីស (៣៣៥០១/៩៦) (ឆ្នាំ២០០១) ទ១៥ សូមមើល សំណុំរឿង Ricardo Canese ទល់នឹងប្រទេសប៉ារ៉ាហ្គាយ, តុលាការអន្តរអាមេរិក (ឆ្នាំ២០០៤) ទទ១៥៣-១៥៤។

[12] ម.ស.ម.ក "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រ ១២។

## ៤. ដែនកំណត់

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសគឺ**មិនមានដែនកំណត់**នោះទេ។ ការសន្មតទុកជាមុនថាគ្មានទោស គឺជាបទដ្ឋាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិតាំងពីដើមមក ដែលអនុវត្តនៅគ្រប់ពេលវេលា និងគ្រប់កាលៈទេសៈទាំងអស់។[13] សិទ្ធិនេះមិនអាចមានករណីលើកលែងដោយត្រូវបានថែងក្នុងការរឹតត្បិតស្របច្បាប់នៅក្នុងពេលមានសង្គ្រាម ឬគ្រាមានគ្រោះអាសន្នសាធារណៈនោះទេ។[14]

ដូច្នេះ ការសន្មតទុកជាមុនថាគ្មានទោស ត្រូវគោរពតាមនៅគ្រប់សំណុំរឿងព្រហ្មទណ្ឌទាំងអស់ នៅគ្រប់ដំណាក់កាលនៃការអនុវត្តនីតិវិធីព្រហ្មទណ្ឌ និងនៅក្នុងការប្រព្រឹត្តរបស់ជនជាប់ចោទនៅគ្រប់ដំណាក់កាលនៃនីតិវិធីផ្លូវច្បាប់ទាំងមូល ដោយមិនមានករណីលើកលែងនោះទេ។

ទោះបីជាការសន្មតទុកជាមុនថាគ្មានទោស ត្រូវបានចាត់ទុកជាសិទ្ធិដាច់ខាត ដែលមិនមានដែនកំណត់ ប៉ុន្តែក៏មាន**ការមើលឃើញបែបផ្សេងទៅលើលក្ខណៈដាច់ខាតនៃសិទ្ធិនៅស្ងៀមផងដែរ**។

ប្រទេសមួយចំនួន អនុញ្ញាតឱ្យមានការដកហូតនូវសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទក្នុងអំឡុងពេលសួរចម្លើយដូចជា នៅចក្រភពអង់គ្លេសជាដើម។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានបង្ហាញនូវក្តីបារម្ភពាក់ព័ន្ធនឹងការដកយកនូវការសន្និដ្ឋានអវិជ្ជមានពីសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ និងបានណែនាំឱ្យប្រទេសទាំងអស់ដែលជាភាគីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ធ្វើការពិចារណាឡើងវិញចំពោះការអនុវត្តរបស់ខ្លួន ដើម្បីធានាថាពួកគេបានអនុលោមទៅតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[15] ប៉ុន្តែ តុលាការអឺរ៉ុបចាត់ទុកថា សិទ្ធិនៅស្ងៀម មិនមែនជាសិទ្ធិដាច់ខាតនោះទេ ហើយគេអាចដកហូតបានសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទបាននៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន។[16] ទោះបីជាយ៉ាងណា សេចក្តីសន្និដ្ឋានទាំងនេះ ត្រូវធ្វើឡើងដោយមានការប្រុងប្រយ័ត្នជានិច្ច។[17]

---

[13] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌ ការបោះពុម្ពផ្សាយលើកទីពីរ" (ឆ្នាំ២០១៤) ទំព័រ ១២៥ https://sithi.org/tmp/publication/view/2014-04-10-fair-trial-manual-published-by-amnesty-international ។

[14] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ ២៤ (CCPR/C/21/Rev.1/Add.6) កថាខណ្ឌ ៨ https://www.refworld.org/docid/453883fc11.html, គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ ២៩ - សិទ្ធិដែលមិនអាចបដិប្បញ្ញត្តិនៅពេលរដ្ឋស្ថិតក្នុងគ្រាអាសន្ន (CCPR/C/21/Rev.1/add.11) កថាខណ្ឌ ១១-១៦, https://www.refworld.org/docid/453883fd1f.html, គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ ៣២ កថាខណ្ឌ ៦។

[15] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "សេចក្តីសន្និដ្ឋានការអង្កេតការណ៍អំពីដែនដីចក្រភពអង់គ្លេស និងនៅក្រៅចក្រភពអង់គ្លេស" (ឯកសារអង្គការសហប្រជាជាតិ CCPR/CO/៧៣/UK CCPR/CO/៧៣/UKOT ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០១) កថាខណ្ឌ ១៧ https://www.refworld.org/docid/3cbbec3d2.html ។

[16] តុលាការអឺរ៉ុប សំណុំរឿង O'Halloran និង Francis ទល់នឹងចក្រភពអង់គ្លេស (ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧)។

[17] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌ ការបោះពុម្ពផ្សាយលើកទីពីរ" ទំព័រ ១៣១។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស សំដៅដល់ជនដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌទាំងអស់គឺត្រូវចាត់ទុកថាគ្មានទោស លុះត្រាតែមានសេចក្តីសម្រេចស្របតាមច្បាប់ និងចូលជាស្ថាពរ។

□ក. ត្រូវ □ខ. ខុស

២. ប្រសិនបើជនជាប់ចោទកំពុងដំណើរការនីតិវិធីជំនុំជម្រះស្ថិតក្នុងសម្លៀកបំពាក់ទណ្ឌិត តើករណីនេះបង្ហាញថាសិទ្ធិសន្មតទុកជាមុនថាគ្មានទោសត្រូវបានគោរពដែរឬទេ?

□ក. បាទ/ចាស □ខ. អត់ទេ

៣.សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស គឺសម្រាប់អនុវត្តតែនៅគ្រប់ដំណាក់កាលជំនុំជម្រះតែប៉ុណ្ណោះ។

□ក. ត្រូវ □ខ. ខុស

៤. ក្នុងចំណោមសកម្មភាពខាងក្រោមនេះ តើសកម្មភាពណាខ្លះដែលបានរំលោភបំពានលើសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស?

□ក.សារព័ត៌មានមិនត្រូវធ្វើវិនិច្ឆ័យណាមួយទាក់ទងនឹងភាពគ្មាន ឬមានពិរុទ្ធភាពរបស់ជនជាប់ចោទទេ

□ខ. មន្ត្រីសាធារណៈបានធ្វើសេចក្តីថ្លែងការណ៍ថាជនជាប់ចោទថាគ្មាន ឬមានពិរុទ្ធភាពមុនសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ។

□គ. ក និង ខ

៥. តើច្បាប់ជាតិ និងច្បាប់អន្តរជាតិណាខ្លះការពារ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស?

□ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

□ខ. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, អនុសញ្ញាស្តីពីសិទ្ធិកុមារ, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

□គ. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, អនុសញ្ញាស្តីពីសិទ្ធិកុមារ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

□ឃ. ក និង គ

៦. សិទ្ធិសន្មតទុកជាមុនថាគ្មានទោសអាចត្រូវបានដកហូតដែរឬទេ?

□ក. បាទ/ចាស □ខ. អត់ទេ

៧. សិទ្ធិនៅស្ងៀមសំដៅលើសិទ្ធិរបស់ជនដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌក្នុងការមិនឆ្លើយតប ចំពោះសំណួររបស់មន្ត្រីអនុវត្តច្បាប់(ឧទាហរណ៍នគរបាលយុត្តិធម៌) ឬក៏មន្ត្រីតុលាការ (ឧទាហរណ៍ អយ្យការ ឬចៅក្រម) នៅគ្រប់ដំណើរការនីតិវិធីព្រហ្មទណ្ឌ។

□ក. ត្រូវ □ខ. ខុស

៨. នៅពេលជនដែលរងការចោទប្រកាន់ព្រហ្មទណ្ឌបដិសេធមិនឆ្លើយតបទៅនឹងសំណួររបស់មន្ត្រី អនុវត្តច្បាប់ ឬមន្ត្រីតុលាការ មានន័យថា ខ្លួនបានប្រព្រឹត្តបទល្មើសពិតប្រាកដមែន។

□ក. ត្រូវ □ខ. ខុស

# សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល











# មាតិកា

I. សិទ្ធិមានសេរីភាព ........................................................................................................16
១.និយមន័យ ......................................................................................................................17
២.ក្របខ័ណ្ឌច្បាប់ . ..............................................................................................................16
២.១.ច្បាប់អន្តរជាតិ ...........................................................................................................16
២.២.ច្បាប់ជាតិ.....................................................................................................................17
៣ . សារៈសំខាន់.................................................................................................................18
៤ . ដែនកំណត់ ...................................................................................................................19
II. សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ........................................................................................................ 22
១. និយមន័យ ..................................................................................................................... 22
២ . ក្របខ័ណ្ឌច្បាប់ ............................................................................................................ 23
២.១.ច្បាប់អន្តរជាតិ ........................................................................................................... 23
២.២.ច្បាប់ជាតិ....................................................................................................................24
៣ . សារៈសំខាន់................................................................................................................ 25
៤. ដែនកំណត់ .................................................................................................................... 26
៥. សំណួរ ........................................................................................................................... 27

## I. សិទ្ធិមានសេរីភាព

### ១. និយមន័យ



សិទ្ធិមានសេរីភាពរបស់បុគ្គលម្នាក់ គឺជាសិទ្ធិមនុស្សយ៉ាងសំខាន់របស់បុគ្គលម្នាក់ៗក្នុងការទទួលបាន**សេរីភាពពីការឃុំខ្លួន**[1] មានន័យថា មិនត្រូវបានដកហូតសេរីភាពក្នុងការដើរហើរតាមអំពើចិត្ត។

ការដកហូតសេរីភាព អាចកើតឡើងនៅក្នុងបរិបទជាច្រើន។ ការដកហូតសេរីភាពក្នុងបរិបទនៃបទល្មើសព្រហ្មទណ្ឌជាទូទៅ រួមមាន **ការឃាត់ខ្លួន ការឃុំខ្លួនបណ្ដោះអាសន្ន ការជាប់ពន្ធនាគារបន្ទាប់ពីចោទប្រកាន់ ឬការឃុំខ្លួននៅក្នុងផ្ទះ**[2]។ ការដកហូតសេរីភាពនេះ ក៏រួមមាន ការរឹតត្បិតបន្ថែមទៅលើបុគ្គលដែលស្ថិតនៅក្រោមការឃុំខ្លួនរួចហើយ ដូចជា ការបង្ខាំងទុកឱ្យនៅដាច់ពីគេ ឬការប្រើប្រាស់ឧបករណ៍រឹតត្បិតទៅលើរូបរាងកាយ (ឧ. ខ្នោះដៃ ច្រវ៉ាក់)។

ការដកហូតសេរីភាព សំដៅដល់ការ**មិនមានការឯកភាព**។ បុគ្គលដែលត្រូវបានសង្ស័យ ឬចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានឃាត់ខ្លួន និងស្ថិតនៅក្នុងការឃាត់ខ្លួន ឬឃុំខ្លួនបណ្ដោះអាសន្នត្រូវបានដកហូតសេរីភាព។ ប៉ុន្តែ បុគ្គលដែលបង្ហាញខ្លួនដោយស្ម័គ្រចិត្តនៅប៉ុស្តិ៍នគរបាល ដើម្បីចូលរួមក្នុងការស៊ើបអង្កេត ហើយដឹងថាពួកគេអាចចាកចេញពេលណាក៏បាន គឺមិនត្រូវបានដកហូតសេរីភាពរបស់ពួកគេនោះទេ។

ជាវិធានទូទៅ និងដើម្បីការពារសិទ្ធិមានសេរីភាព បុគ្គលដែលត្រូវបានសង្ស័យ ឬចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មិនគួរត្រូវបានដកហូតសេរីភាពដោយរង់ចាំការជំនុំជម្រះនោះទេ។[3] ប៉ុន្តែ នៅក្នុងកាលៈទេសៈដែលបានរៀបរាប់ជាក់លាក់មួយចំនួន ការឃុំខ្លួនជនសង្ស័យ ឬជនត្រូវចោទប្រកាន់អាចមានលក្ខណៈស្របច្បាប់ *(សូមមើលផ្នែកដែនកំណត់)*។

### ២. ក្របខ័ណ្ឌច្បាប់

#### ២.១. ច្បាប់អន្តរជាតិ

**សិទ្ធិមានសេរីភាព** ត្រូវបានការពារយ៉ាងច្បាស់ ដោយសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដែលដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងច្បាប់នៃប្រទេសកម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

---

[1] គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣៥- មាត្រា៩៖ សេរីភាពនិងសន្តិសុខរបស់មនុស្ស (CCPR/C/GC/35, ខែធ្នូ ឆ្នាំ២០១៤) កថាខណ្ឌ៣ https://documents-dds-ny.un.org/doc/UNDOC/GEN/G14/244/51/PDF/G1424451.pdf?OpenElement ។

[2] ដូចខាងលើ កថាខណ្ឌ ៥។

[3] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ សំណៅលើកទីពីរ" (ខែមេសា ឆ្នាំ២០១៤)ទំព័រ ៣ https://www.amnesty.org/en/documents/pol30/002/2014/en/ ។

**មាត្រា ៣ នៃ ស.ស.ស.ម៖** *"បុគ្គលម្នាក់ៗមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។"*



**មាត្រា ៩ (១) នៃ ក.អ.ស.ព.ន៖** *"១. ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ត្រូវបានដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។ [..........]*



## ២.២. ច្បាប់ជាតិ

**រដ្ឋធម្មនុញ្ញកម្ពុជា** និង**ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** ("ក្រមនីតិវិធីព្រហ្មទណ្ឌ") ក៏ការពារសិទ្ធិមានសេរីភាពផងដែរ។ លើសពីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានចែងអំពីវិធានក្នុងការឃុំខ្លួនបុគ្គលនៅក្នុងបរិបទនៃដំណើរការព្រហ្មទណ្ឌផងដែរ។



- **មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ៖** *"ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន [...]."*
- **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ៖** "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។"

- **មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ជាគោលការណ៍ ជនត្រូវចោទត្រូវមាន សេរីភាព។ ក្នុងករណីពិសេសជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ។"*
- **មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ។*
- **មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ការឃុំខ្លួនបណ្ដោះអាសន្ន អាចត្រូវបានបង្គាប់កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះ ចាំបាច់៖*



  1. *ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។*
  2. *ដើម្បីរាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរាំងមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត*
  3. *ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារ។*
  4. *ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។*
  5. *ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស។"*
- **មាត្រា២០៨ ដល់២១៤នៃក្រមព្រហ្មទណ្ឌ៖** ចែងអំពីថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន រួមទាំងចុងចោទជានីតិជនផងដែរ។

## ៣. សារៈសំខាន់



ជាទូទៅសិទ្ធិមានសេរីភាពរបស់បុគ្គលម្នាក់ៗគឺជាសិទ្ធិដ៏សំខាន់បំផុតទាំងសម្រាប់បុគ្គល និងសង្គមទាំងមូល ដោយសារតែការដកហូតសេរីភាព ជាទម្លាប់បានក្លាយទៅជាមធ្យោបាយសំខាន់ក្នុងការកំណត់ការអនុវត្តសិទ្ធិសេរីភាពរបស់អ្នកដទៃទៀត។ នៅក្នុងបរិបទព្រហ្មទណ្ឌ សិទ្ធិមានសេរីភាពគឺជាសិទ្ធិដ៏សំខាន់ដែលត្រូវការពារ**សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ជនត្រូវចោទ** ជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានដែលតម្រូវថាគ្មានទោសចំពោះការចោទប្រកាន់លើពួកគេ រហូតទាល់តែពិរុទ្ធភាពត្រូវរកឃើញតាមច្បាប់ និងត្រូវបានផ្ដន្ទាទោសជាស្ថាពរដោយតុលាការ ដូច្នេះ ពួកគេបន្តទទួលបានសិទ្ធិសេរីភាពដូចជាបុគ្គលផ្សេងទៀតដែរ (*សូមមើលមេរៀនស្ដីពីសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសសម្រាប់ព័ត៌មានលម្អិត*)។

ដូច្នេះ ការដកហូតសេរីភាពរបស់ជនសង្ស័យ ឬជនត្រូវចោទ អាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងប៉ះពាល់ដល់ការជំនុំជម្រះដោយយុត្តិធម៌។

## ៤. ដែនកំណត់



សិទ្ធិមានសេរីភាពរបស់បុគ្គលម្នាក់គឺមិន**ដាច់ខាត**នោះទេ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុញ្ញាតឱ្យមានការដកហូតសេរីភាពរបស់បុគ្គលនៅក្នុងកាលៈទេសៈដែលមានហេតុផលគ្រប់គ្រាន់ តួយ៉ាង **ការអនុវត្តច្បាប់ព្រហ្មទណ្ឌ**។[4] ចំណុចនេះមានន័យថា បុគ្គលម្នាក់អាចត្រូវបានឃាត់ខ្លួន និងឃុំខ្លួនក្រោមការចោទប្រកាន់ករណីព្រហ្មទណ្ឌ។ ប៉ុន្តែ ការឃាត់ខ្លួន ឬការឃុំខ្លួនបែបនេះ **មិនមែនធ្វើឡើងតាមអំពើចិត្ត**នោះទេ មានន័យថាការឃុំខ្លួននេះមិនត្រូវមានលក្ខណៈមិនសមស្របអយុត្តិធម៌ ឬមិនអាចប៉ាន់ស្មានបាន ក៏ដូចជាគ្មានហេតុផល មិនចាំបាច់ ឬគ្មានសមាមាត្រនោះទេ។ ការឃាត់ខ្លួនឬការឃុំខ្លួនត្រូវតែស្របច្បាប់ មានន័យថា ការឃុំខ្លួននេះត្រូវធ្វើឡើងដោយស្របតាមនីតិវិធី ដែលបានបង្កើតឡើងដោយច្បាប់ និងដោយគោរពទៅតាមនីតិរដ្ឋ។[5] **ការធ្វើតាមអំពើចិត្តគឺមានន័យទូលំទូលាយជាងភាពស្របច្បាប់** នៅក្នុងន័យថា ការឃុំខ្លួនអាចអនុញ្ញាតដោយច្បាប់ជាតិ ប៉ុន្តែ ជាឧទាហរណ៍ អាចជាការធ្វើឡើងតាមអំពើចិត្តដោយសារតែការឃុំខ្លួននេះមិនសមស្របឬមិនមានមូលហេតុមិនសមាមាត្រ ឬមិនចាំបាច់។[6] ដូច្នេះ **ច្បាប់ជាតិ**ដែលអនុញ្ញាតឱ្យមានការឃាត់ខ្លួន និងឃុំខ្លួនលើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌត្រូវតែ**អនុលោមទៅតាមសិទ្ធិមនុស្សអន្តរជាតិ**។[7]

ឧទាហរណ៍អំពីការឃាត់ខ្លួន ឬការឃុំខ្លួនខុសច្បាប់ ប៉ុន្តែមិនត្រូវបានកម្រិត រួមមាន៖[8]

- បទល្មើសដែលច្បាប់ជាតិមិនអនុញ្ញាតឱ្យឃាត់ខ្លួន
- ការឃាត់ខ្លួនដោយគ្មានដីកា ប្រសិនបើច្បាប់ជាតិតម្រូវឱ្យមានដីកា
- ការឃាត់ខ្លួនជនណាម្នាក់យូរជាងរយៈពេលអតិបរមាដែលបានអនុញ្ញាតដោយច្បាប់ជាតិ
- ការឃាត់ខ្លួន និងការឃុំខ្លួនដោយផ្អែកលើមូលដ្ឋាននៃការរើសអើង

ឧទាហរណ៍នៃការឃុំខ្លួន និងការឃុំខ្លួនតាមអំពើចិត្ត ប៉ុន្តែមិនត្រូវបានកម្រិត រួមមាន៖[9]

- ការឃាត់ខ្លួន ឬការឃុំខ្លួនដោយមិនមានមូលដ្ឋានច្បាប់

---

[4] ដូចខាងលើ កថាខណ្ឌ ១០។

[5] ដូចខាងលើ កថាខណ្ឌ ១០។

[6] ដូចខាងលើ កថាខណ្ឌ ១២។

[7] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ ការបោះពុម្ពផ្សាយលើកទីពីរ" (ខែមេសា ឆ្នាំ២០១៤) ទំព័រ ៣១ https://www.amnesty.org/en/documents/pol30/002/2014/en/ ។

[8] ដូចខាងលើ ទំព័រទី ៣៣ និង៣៤។

[9] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣៥ កថាខណ្ឌ ១៦-១៨; អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤) ទំព័រ ៣៣-៣៤ ។

- ការឃាត់ខ្លួន ឬការឃុំខ្លួនដែលអនុញ្ញាតដោយច្បាប់ជាតិ ប៉ុន្តែមិនត្រូវតាមបទដ្ឋានអន្តរជាតិ (ឧ. ច្បាប់បានបំពានលើសិទ្ធិផ្សេងៗដូចជាសេរីភាពក្នុងការបញ្ចេញមតិ ប្រមូលផ្តុំ ជាដើម)
- ប្រសិនបើការឃាត់ខ្លួន ឬការឃុំខ្លួនបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់អ្នកជាប់ឃុំ
- ការបាត់ខ្លួនដោយបង្ខំ ឬការឃុំខ្លួនដោយសម្ងាត់ណាមួយ

ការឃាត់ខ្លួន ឬការឃុំខ្លួនត្រូវធ្វើឡើងដោយអ្នកដែលមានសិទ្ធិអំណាចផ្លូវច្បាប់ក្នុងការអនុវត្ត ដែលជាអ្នកដែលអាចកំណត់អត្តសញ្ញាណ។[10] ជារួម ការឃុំខ្លួនណាមួយត្រូវតែធ្វើឡើងសម្រាប់តែពេលវេលាដែលចាំបាច់ប៉ុណ្ណោះ (ឧ. **ពេលវេលាមានកំណត់**) ហើយត្រូវ**វាយតម្លៃឡើងវិញតាមកាលកំណត់**ទៅលើភាពចាំបាច់នោះ។[11]

ច្បាប់សិទ្ធិមនុស្សអន្តរជាតិក៏មានចែងដែរថា ការដកហូតសេរីភាពដែលការឃុំខ្លួនបុគ្គលត្រូវចោទដែលកំពុងរង់ចាំការជំនុំជម្រះ (ការឃុំខ្លួនបណ្តោះអាសន្ន) **ត្រូវតែជាករណីលើកលែង និង មិនមែនជាទម្លាប់**នោះទេ។ ការឃុំខ្លួនបណ្តោះអាសន្នលើបុគ្គលត្រូវចោទ ត្រូវផ្អែកលើ**ការកំណត់របស់បុគ្គលរៀងៗខ្លួន** ដែលថាការឃុំខ្លួននោះសមហេតុផល និងចាំបាច់ ដោយពិចារណាអំពី**កត្តាដែលមានបញ្ជាក់យ៉ាងច្បាស់នៅក្នុងច្បាប់** ដូចជា ការបញ្ចៀសនៃការរត់ទៅបរទេស ការធ្វើឱ្យប៉ះពាល់ដល់ភស្តុតាង ឬការប្រព្រឹត្តបទល្មើសម្តងទៀត ដែលរឿងទាំងនេះអាចកើតមានឡើង ប្រសិនបើអនុញ្ញាតឱ្យជនត្រូវចោទមានសេរីភាព។ តុលាការត្រូវទទួលខុសត្រូវក្នុងការពិនិត្យលើលទ្ធភាពនៃ**ជម្រើសផ្សេងទៀត**ក្រៅពីការឃុំខ្លួនបណ្តោះអាសន្ន មុនពេលធ្វើការសម្រេចចិត្តឃុំខ្លួននៅក្នុងករណីនីមួយៗ រួមមានដូចជាការតម្កល់ប្រាក់ធានាដើម្បីនៅក្រៅឃុំ ការតាមដានទីតាំងរបស់ជនត្រូវចោទដោយខ្សែដៃអេឡិចត្រូនិច ជាដើម ប្រសិនបើជម្រើសផ្សេងទៀតទាំងនេះ នឹងជំនួសឱ្យការឃុំខ្លួនមិនចាំបាច់។ ការឃុំខ្លួនបណ្តោះអាសន្នលើកុមារទំនាស់នឹងច្បាប់ ក៏ត្រូវតែជៀសវាងឱ្យអស់ពីលទ្ធភាពដែរ។[12]

ឧទាហរណ៍ នៅក្នុង**ប្រទេសកម្ពុជា** ច្បាប់ជាតិអនុញ្ញាតឱ្យមានការឃុំខ្លួនបណ្តោះអាសន្នតែក្នុងសំណុំរឿងបទឧក្រិដ្ឋ និងមជ្ឈិម ដែលពាក់ព័ន្ធនឹងការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីមួយឆ្នាំឡើងទៅ និងហេតុផលចំនួនប្រាំមួយ ដែលជាមូលដ្ឋានក្នុងការឃុំខ្លួនបណ្តោះអាសន្ន។ ច្បាប់នេះក៏បានកំណត់អំពីអាជ្ញាយុកាលយ៉ាងច្បាស់ និងតឹងរឹងសម្រាប់ឃុំខ្លួនបណ្តោះអាសន្នផងដែរ។ *(សូមមើលផ្នែកក្របខ័ណ្ឌច្បាប់សម្រាប់ព័ត៌មានលម្អិតបន្ថែម)* អ្នកដែលត្រូវបានដកហូតសេរីភាពតាមរយៈការឃាត់ខ្លួន ឬឃុំខ្លួនត្រូវតែអាច**តវ៉ាបានតាមច្បាប់ពីការដកហូតសិទ្ធិសេរីភាពនេះ នៅចំពោះមុខតុលាការ**។[13]

[10] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ កថាខណ្ឌ ២៣។

[11] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ កថាខណ្ឌ ១២។

[12] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ កថាខណ្ឌ ៣៨។

[13] ដូចខាងលើ កថាខណ្ឌ ៣៩។

ជនរងគ្រោះពីការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់ ឬតាមអំពើចិត្តត្រូវតែមាន**សិទ្ធិស្នើសុំទាមទារសំណង**[14] បុគ្គលត្រូវចោទដែលបានឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែ**ទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប ឬត្រូវដោះលែង។** (សូមមើលផ្នែកទី II សម្រាប់ព័ត៌មានលម្អិតបន្ថែម)។

ជាចុងក្រោយ ទោះបីជាមាត្រា ៩ នៃ ក.អ.ស.ព.ន ដែលធានានូវសិទ្ធិមានសេរីភាពមិនស្ថិតនៅក្នុងបញ្ជីដែលមិនអនុញ្ញាតឱ្យមានបដិប្បញ្ញត្តិសិទ្ធិ[15]នៃមាត្រា ៤ (២) នៃ ក.អ.ស.ព.ន (ការដាក់ប្រទេសស្ថិតក្នុងគ្រាអាសន្ន) ហើយអាចជាបដិប្បញ្ញត្តិក្នុងបរិបទនៃប្រទេសស្ថិតក្នុងគ្រាអាសន្ន **ការធានាពីការឃុំខ្លួនតាមអំពើចិត្ត**មានចែងនៅមាត្រា ៩ **មិនអាចបដិប្បញ្ញត្តិបានទេ។** ចំណុចនេះមានន័យថា រដ្ឋមិនអាចធ្វើការឃាត់ខ្លួន ឬឃុំខ្លួនបុគ្គលតាមអំពើចិត្តក្នុងអំឡុងពេលនៃការដាក់ប្រទេសស្ថិតក្នុងគ្រាអាសន្ន។[16]

---

14 ដូចខាងលើ កថាខណ្ឌទី ៤៩។

15 សិទ្ធិមិនអាចបដិបញ្ញត្តិ៖ សិទ្ធិដែលមិនអាចអនុញ្ញាតិឱ្យមានការដកហូតដោយរដ្ឋាភិបាលនៅក្នុងកាលៈទេសៈនៃ"រដ្ឋក្នុងគ្រាអាសន្ន ក្រោមមាត្រា៤ នៃ ក.ស.អ.ព.ន។

16 ដូចខាងលើ កថាខណ្ឌ ៦៥ និង ៦៨។

## II. សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

### ១. និយមន័យ



សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលតម្រូវឱ្យមានដំណើរការនីតិវិធីព្រហ្មទណ្ឌដែលត្រូវធ្វើឡើងនៅក្នុងរយៈពេលសមស្រប។[17] ប៉ុន្តែ តុលាការព្រហ្មទណ្ឌអន្តរជាតិបានព្រមានថា តម្រូវការអនុវត្តនីតិវិធីរហ័ស មិនអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាទូទៅឡើយ។

**សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប** (ឬត្រូវដោះលែង) អនុវត្តតែ**ចំពោះបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងត្រូវបានឃុំខ្លួនបណ្ដោះអាសន្នប៉ុណ្ណោះ** បើទោះបីជា**សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល**មានវិសាលភាពទូលំទូលាយជាងនេះ។ សិទ្ធិនេះអនុវត្តចំពោះបុគ្គលគ្រប់រូបដែលត្រូវចោទពីបទព្រហ្មទណ្ឌ **មិនថាឃុំខ្លួន ឬអត់នោះទេ។**

សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប (ឬត្រូវដោះលែង) អនុវត្តជាក់លាក់ចំពោះ**រយៈពេលឃុំខ្លួនបណ្ដោះអាសន្ន** ឧ. ការឃុំខ្លួននៅចន្លោះពេលចាប់ខ្លួន និងការចេញសេចក្ដីសម្រេចនៅសាលា ដំបូង។[18] សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល **មានវិសាលភាពក្នុងការអនុវត្តយ៉ាងទូលំទូលាយ។** ការធានានេះអនុវត្ត**ចាប់ពីពេលដែលមានការចោទប្រកាន់ជាផ្លូវការរហូតដល់សេចក្ដីសម្រេចជាស្ថាពរបិទផ្លូវតវ៉ា។** ទាំងដំណាក់កាលសាលាដំបូង និងតុលាការជាន់ខ្ពស់ ត្រូវតែធ្វើឡើងដោយមិនមានការពន្យារ ពេល។[19]**ពុំមានថិរវេលាកំណត់ជាក់លាក់** ដែលបានកំណត់ថាតើពេលវេលាប៉ុណ្ណាដែលជាពេលវេលាសមស្រប ឬមិនមានការពន្យារពេលនោះទេ។ ភាពសមស្របនៃពេលវេលាក្នុងការនាំយកជនត្រូវចោទដែលត្រូវបានឃុំខ្លួនមកជំនុំជម្រះ ឬការពន្យារពេលណាមួយក្នុងការដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវថ្លែងកាត់ការវាយតម្លៃ**ទៅតាមករណីនីមួយៗ**ដោយត្រូវធ្វើការពិចារណាទៅលើកាលៈទេសៈនៃសំណុំរឿងនីមួយៗ រួមទាំង **ភាពស្មុគស្មាញ**នៃសំណុំរឿងផងដែរ (ឧ. ចំនួនមនុស្សដែលពាក់ព័ន្ធនឹងបទល្មើសដែលបានចោទប្រកាន់ ចំនួនបទចោទ ប្រភេទនៃការស៊ើបអង្កេតដែលត្រូវការជាដើម[20])





---

[17] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤) ទំព័រ ១៤៣ ។

[18] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៧។

[19] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្ដីពន្យល់ទូទៅលេខ ៣២ ស្ដីពីមាត្រា ១៤, CPPR/C/GC/៣២, (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧) កថាខណ្ឌ ៣៥ https://www.refworld.org/docid/478b2b2f2.html ។

[20] អង្គការលើកលែងទោសអន្តរជាតិ, សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤) ទំព័រទី ១៤៥។

**ការប្រព្រឹត្តរបស់ជនជាប់ចោទក្នុងអំឡុងពេលដំណើរការនីតិវិធី** (ឧ.ប្រសិនបើជនជាប់ចោទរត់គេចខ្លួនជាដើម) និង**របៀបដែលអាជ្ញាធរប្រតិបត្តិ និងតុលាការដោះស្រាយសំណុំរឿង**នោះ[21] (ឧ.ការធ្វេសប្រហែលរបស់អាជ្ញា ធរបានធ្វើឱ្យយឺតយ៉ាវដល់ដំណើរការស៊ើបអង្កេតជាដើម[22])។

អាជ្ញាធរក្នុងប្រទេសមានតួនាទីក្នុងការធានាថា ជនជាប់ចោទត្រូវបាននាំយកមកសវនាការទាន់ពេលវេលា។ ចំណុចនេះមានន័យថា ពួកគេត្រូវតែរៀបចំ និងធ្វើយ៉ាងណាផ្តល់ធនធានឱ្យបានគ្រប់គ្រាន់សម្រាប់ប្រព័ន្ធច្បាប់[23] ដើម្បីធានាឱ្យមានយុត្តិធម៌ឆាប់រហ័ស។ ប្រសិនបើអាជ្ញាធរមិនបាននាំជនជាប់ចោទដែលកំពុងស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នមកកាន់សវនាការនៅក្នុងពេលវេលាសមស្របទេនោះ ពួកគេត្រូវតែដោះលែងជនជាប់ចោទនោះ។

ចំណុចនេះមិនមានន័យថា ការចោទប្រកាន់ត្រូវបានទម្លាក់ចោលនោះទេ ប៉ុន្តែជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យរង់ចាំសវនាការដោយមានសេរីភាព។ ប្រសិនបើមានការពន្យារពេលនីតិវិធីនៅក្នុងអំឡុងពេលដំណើរការនីតិវិធីព្រហ្មទណ្ឌ អាជ្ញាធរត្រូវតែធានាថាពួកគេត្រូវបានផ្តល់មូលហេតុសមស្រប។[24]

# ២. ក្របខ័ណ្ឌច្បាប់

## ២.១. ច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប (ឬត្រូវដោះលែង) សម្រាប់ជនត្រូវចោទដែលស្ថិតនៅក្រោមការឃុំខ្លួន និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលសម្រាប់បុគ្គលដែលត្រូវបានចោទប្រកាន់ទាំងអស់ ត្រូវបានធានាយ៉ាងច្បាស់នៅមាត្រា ៩ និង ១៤ នៃ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** (“ក.អ.ស.ព.ន”)។

**មាត្រា ៩ (៣) នៃ ក.អ.ស.ព.ន៖** **“បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ** នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការ និង**ត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។”**

**មាត្រា ១៤ (៣)(គ) នៃក.អ.ស.ព.ន៖** “ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូប មានសិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេលយូរហួសហេតុ។”



[21] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៦; គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣៥ កថាខណ្ឌ ៣៧ ។

[22] អង្គការលើកលែងទោសអន្តរជាតិ, សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤) ទំព័រទី ១៤៦ ។

[23] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ២៧; អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤) ទំព័រទី ១៤៤។

[24] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤) ទំព័រ ១៤៣ ។

## ២.២. ច្បាប់ជាតិ

**ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសកម្ពុជា** (**"ក្រមនីតិវិធីព្រហ្មទណ្ឌ"**) ធានានូវសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប ឬត្រូវដោះលែង និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលនៅក្នុងបញ្ញត្តិមួយចំនួន។

- **មាត្រា ២៤៩ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"[...]* សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្តោះអាសន្ន លែងអាចមានអានុភាពក្នុងរយៈពេលបួនខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅក្នុងតុលាការក្នុងរយៈពេលបួនខែនោះទេ ជនត្រូវចោទនេះត្រូវបានដោះលែងដោយស្វ័យប្រវត្តិ *[...]."*
- **មាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"[...] ប្រធានសភាស៊ើបសួរ រ៉ាប់រងកុំឱ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវដោយមិនសមហេតុផលក្នុងការអនុវត្តនីតិវិធី [...]."។*

- **មាត្រា ៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"[...] យោងតាមមាត្រា ២៤៩ [...] នៃក្រមនេះ សេចក្តីសម្រេចរក្សាទុកខ្លួនជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ត្រូវអស់សុពលភាពនៅពេលផុតថិរវេលាបួនខែ។ ប្រសិនបើជនជាប់ចោទមិនត្រូវបានឱ្យចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេលនេះទេ ជនជាប់ចោទ ត្រូវតែបានដោះលែងឱ្យមានសេរីភាពដោយឯកឯង។ សាលក្រមលើអង្គសេចក្តីត្រូវធ្វើឡើងនៅក្នុងរយៈពេលសមហេតុផល។*
- **មាត្រា ៣៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"[...] សាលាឧទ្ធរណ៍ ត្រូវសម្រេចនៅក្នុងរយៈពេលសមស្រប។ ក្នុងករណីប្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង ស្តីពីការឃុំខ្លួនជនជាប់ចោទ សាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿង។"*
- **មាត្រា ៤៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"តុលាការកំពូល ត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរប្រាំមួយខែ គិតពីពេលទទួលសំណុំរឿង លើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន។"*

## ៣. សារៈសំខាន់



សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលអាចជួយ**ការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋាន**បាន។ សិទ្ធិទាំងពីរនេះមានសារៈសំខាន់ណាស់ក្នុងការរក្សា**សិទ្ធិមានសេរីភាព** និង**ការសន្មតទុកជាមុនថាគ្មានទោស** ដោយសារតែសិទ្ធិនេះ បញ្ចៀសនូវការឃុំខ្លួន បណ្តោះអាសន្នរយៈពេលយូរហួសហេតុពេក ហើយការឃុំខ្លួនបុគ្គលរយៈពេលយូរជាងភាពចាំបាច់នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ (*សូមមើលមេរៀនស្តីពីសិទ្ធិមានសេរីភាព និងសន្មតទុកជាមុនថាគ្មានទោសសម្រាប់ព័ត៌មានលម្អិតបន្ថែម*)។

សិទ្ធិទាំងពីរនេះជួយឱ្យ**ដំណើរការផ្តល់យុត្តិធម៌មានភាពរហ័ស** ដែលជាគំនិតដ៏សំខាន់នៃ**ការជំនុំជម្រះដោយយុត្តិធម៌**[25] ដោយសារតែដំណើរការយុត្តិធម៌រហ័សគឺចៀសវាងការឃុំខ្លួនបុគ្គលក្នុងរយៈពេលយូរពេក ក្នុងស្ថានភាពមិនច្បាស់លាស់អំពីជោគវាសនារបស់ពួកគេ[26] និងស្នាមរបួសផ្លូវចិត្តពាក់ព័ន្ធនឹងការចោទប្រកាន់មកលើពួកគេ។[27] ដំណើរការយុត្តិធម៌រហ័ស ដែលមានការធានាដោយសិទ្ធិទាំងពីរនេះ ធានាថា**ផលប្រយោជន៍យុត្តិធម៌គឺត្រូវបានផ្តល់ជូន**។[28] ការពន្យារពេលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាព ឬអត្ថិភាពនៃភស្តុតាង (ឧ. ការបាត់ ការខូចគុណភាព ឬការបំផ្លាញភស្តុតាង) ការផ្តល់សក្ខីកម្មរបស់សាក្សី ឬអត្ថិភាពរបស់ពួកគេ (ឧ. ពួកគាត់អាចភ្លេចហេតុការណ៍) ដូច្នេះ បង្កើនឱកាសក្នុងការកាត់ក្តីដោយភាន់ច្រឡំ ឬការកាត់ទោសខុស។[29] ទោះបីជាយ៉ាងនេះក្តី តុល្យភាពត្រូវតែនៅចន្លោះរវាងភាពចាំបាច់នៃដំណើរការយុត្តិធម៌រហ័ស និងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្សេងទៀត ដូចជា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានពេលវេលា (និងមធ្យោបាយ) គ្រប់គ្រាន់ ដើម្បីរៀបចំការការពារក្តី។ *(សូមមើលមេរៀនស្តីពីសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីសម្រាប់ព័ត៌មានលម្អិតបន្ថែម)*។

ដូច្នេះ ការបំពានសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងប៉ះពាល់ដល់ការគ្រប់គ្រងយុត្តិធម៌ដ៏សមស្រប។

[25] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ២៧។
[26] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៥។
[27] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤) ទំព័រ ១៤៤។
[28] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ កថាខណ្ឌ ៣៥។
[29] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤) ទំព័រ ១៤៤។

## ៤. ដែនកំណត់[30]

សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល**មិនហាមឃាត់ចំពោះការពន្យារពេលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ**នោះទេ។ ការពន្យារពេលមួយចំនួនអាចមានហេតុផលថាដោយសារតែភាពស្មុគស្មាញនៃសំណុំរឿង ឬការប្រព្រឹត្តរបស់ជនជាប់ចោទ។ ប៉ុន្តែ ការពន្យារពេលដែលបង្កឡើងដោយការស្ទះដំណើរការនីតិវិធីតុលាការ ខ្វះខាតធនធានមនុស្ស (ឧ. កង្វះចៅក្រម)[31] ឬការធ្វេសប្រហែសរបស់អាជ្ញាធរ មិនអាចទទួលយកបានជាមូលហេតុចំពោះការពន្យារពេលដំណើរការនីតិវិធីព្រហ្មទណ្ឌបាននោះទេ។

[30] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤) ទំព័រ ១៤៥-១៤៦។

[31] ដូចខាងលើ, ទំព័រទី ១៤៤។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល និងសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ សំដៅទៅលើរយៈពេលនៃដំណើរការនីតិវិធីក្នុងការស្វែងរកយុត្តិធម៌ក្នុងរយៈពេលសមរម្យ ។

☐ក. ត្រូវ ☐ខ. ខុស

២. សិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងរយៈពេលសមរម្យ(ឬដោះលែង)គឺអនុវត្តតែចំពោះបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ។

☐ក. ខុស ☐ខ. ត្រូវ

៣. សិទ្ធិមានសេរីភាព គឺជាសិទ្ធិដែលគេ៖

☐ក. អាចដកហូតបានក្នុងកាលៈទេសៈជាក់ស្តែង

☐ខ. មិនអាចដកហូតបានក្នុងកាលៈទេសៈមួយចំនួន

៤. តើសកម្មភាពណាខ្លះដែលបានបញ្ជាក់ថា សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលត្រូវបានរំលោភបំពាន?

☐ក. តុលាការបន្តឃុំខ្លួនជនរងការចោទប្រកាន់ដោយប្រើពេលយូរ មិនបានកំណត់រយៈពេលជំនុំជម្រះ និងដាក់ពួកគេស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់

☐ខ. តុលាការបានពន្យារពេលសវនាការដោយលើកមូលហេតុថាភាគីម្ខាងទៀតឈឺមិនអាចមកចូលរួមសវនាការបាន

☐គ. តុលាការបានលើកពេលជំនុំជម្រះរឿងក្តីទៅថ្ងៃក្រោយដោយហេតុថាភាពស្មុគស្មាញនៃសំណុំរឿង។

☐ឃ. ក, ខ និងគ

៥. តើការពន្យារពេលសវនាការអាចប៉ះពាល់ដល់អ្វីខ្លះ?

☐ក. គុណភាពនៃភស្តុតាង ឬភាពអាចរកបាននៃភស្តុតាង

☐ខ. ភាពជឿជាក់លើសាក្សី ឬវត្តមានរបស់សាក្សី

☐គ. ផលប្រយោជន៍នៃយុត្តិធម៌

☐ឃ. ក, ខ និង គ

៦. សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាសមរម្យ និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល មានន័យថាក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌមិនអាចពន្យារពេលបានទេ។

☐ក. ខុស ☐ខ. ត្រូវ

៧. ការដកហូតសេរីភាពរបស់បុគ្គលតាមរយៈការឃុំខ្លួនរង់ចាំការជំនុំជម្រះ គឺអាចប៉ះពាល់ដល់សិទ្ធិ៖

☐ក.សិទ្ធិទទួលបានការសន្និតទុកជាមុនថាគ្មានទោស

☐ខ. សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីឯករាជ្យ និងមិនលម្អៀង

# សិទ្ធិយល់ដឹងអំពីប្រភេទ និង មូលហេតុនៃការចោទប្រកាន់









# មាតិកា


១ .និយមន័យ ........ 28
២. ក្របខ័ណ្ឌច្បាប់ ........ 29
២.១. ច្បាប់អន្តរជាតិ ........ 29
២.២. ច្បាប់ជាតិ ........ 29
៣. សារៈសំខាន់ ........ 30
៤. ដែនកំណត់ ........ 31
៥. សំណួរ ........ 32

## ១. និយមន័យ

**សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់** ធានាថាជនជាប់ចោទ និងមេធាវីរបស់ពួកគេទទួលបានការជូនដំណឹងភ្លាមៗ ដោយមានបញ្ជាក់នូវព័ត៌មានលម្អិតដូចជា៖

- **ប្រភេទនៃការចោទប្រកាន់៖** ច្បាប់ដែលប្រើសម្រាប់ចោទប្រកាន់ទៅលើជនជាប់ចោទ។
- **មូលហេតុនៃការចោទប្រកាន់៖** អង្គហេតុនៃបទចោទប្រកាន់ ដែលជាមូលដ្ឋានសម្រាប់ចោទប្រកាន់ទៅលើជនជាប់ចោទ[1]។



ជនជាប់ចោទត្រូវតែទទួលបានការជូនដំណឹងភ្លាមៗ នៅពេលដែលពួកគេត្រូវបានចោទប្រកាន់ជាផ្លូវការស្របតាមច្បាប់ជាតិ ឬនៅពេលដែលជននោះត្រូវបានចោទប្រកាន់ជាសាធារណៈ។[2]

សិទ្ធិនេះអនុវត្តចំពោះសំណុំរឿងព្រហ្មទណ្ឌទាំងអស់ រួមទាំងសំណុំរឿងជនជាប់ចោទដែលមិនត្រូវបានឃុំខ្លួនក៏ដោយ។[3]

ព័ត៌មានដែលផ្តល់ជូនជនជាប់ចោទត្រូវតែមានភាពលម្អិតគ្រប់គ្រាន់ ដើម្បីអាចឱ្យពួកគេមានសមត្ថភាពរៀបចំមេធាវីការពារក្តីរបស់ខ្លួន ហើយត្រូវជូនដំណឹងឱ្យបានត្រឹមត្រូវដល់មេធាវីរបស់ពួកគេអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើពួកគេ។ ព័ត៌មានអំពីការចោទប្រកាន់អាចផ្តល់ជូនទាំងជាលាយលក្ខណ៍អក្សរផង និងដោយផ្ទាល់មាត់ផង ទោះបីជាសិទ្ធិនេះពីដំបូងបានផ្តល់ជូនដោយផ្ទាល់មាត់ហើយក៏ដោយ ក៏ត្រូវតែបញ្ជាក់ជាលាយលក្ខណ៍អក្សរតាមក្រោយផងដែរ។[4]

ប្រការដ៏សំខាន់ផងដែរនោះគឺ ជនជាប់ចោទត្រូវទទួលបានព័ត៌មានអំពីការចោទប្រកាន់នេះ ជាភាសាដែលពួកគេចេះ នេះមានន័យថា ជនជាប់ចោទដែលមិនចេះភាសាដែលអាជ្ញាធរប្រើ ត្រូវតែទទួលបានជំនួយពីអ្នកបកប្រែដោយឥតគិតថ្លៃ។ លើសពីនេះទៅទៀត ព័ត៌មានពាក់ព័ន្ធគួរតែផ្តល់ឱ្យជនជាប់ចោទជាភាសាសាមញ្ញ និងមិនមែនក្នុងទម្រង់បច្ចេកទេស ដើម្បីធានាថាជនជាប់ចោទអាចយល់ពីការចោទប្រកាន់នោះបាន។[5]
ខណៈពេលជនជាប់ចោទត្រូវមានសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ឱ្យបានឆាប់បំផុត



នៅក្នុងដំណើរការនីតិវិធីផ្លូវច្បាប់ ចៅក្រមក៏ត្រូវមានកាតព្វកិច្ច រំឭកជនជាប់ចោទក្នុងសវនា

[1] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ការបោះពុម្ពផ្សាយលើកទីពីរ (ខែមេសា ឆ្នាំ២០១៤) ទំព័រ ៧៦ https://www.amnesty.org/en/documents/pol30/002/2014/en/ ។

[2] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "សេចក្តីពន្យល់ទូទៅលេខ ៣២--មាត្រា១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ,(CPPR/C/GC/32, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ៣១ https://www.refworld.org/docid/478b2b2f2.html ។

[3] ដូចខាងលើ។

[4] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣១។

[5] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ទំព័រ ៣៨។

ការដោយផ្តល់ការពន្យល់ឱ្យបានគ្រប់គ្រាន់ដើម្បីជានាថា ពួកគេយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើពួកគាត់។[6]

ចៅក្រមត្រូវធានាអំពីចំណុចនេះដោយៈ

- ធ្វើការប្រកាសសំណុំរឿងឱ្យភាគីបានស្តាប់។
- ពន្យល់ពីបទចោទប្រកាន់ ពេលវេលា កាលបរិច្ឆេទ និងទីកន្លែងប្រព្រឹត្តិនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់។
- លើកឡើងអំពីភាគីពាក់ព័ន្ធ។[7]

## ២. ក្របខ័ណ្ឌច្បាប់



### ២.១. ច្បាប់អន្តរជាតិ

**សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់**មានចែងការពារយ៉ាងច្បាស់ដោយ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")** ដែលអាចអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់ជាតិកម្ពុជាស្របតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

### ២.២. ច្បាប់ជាតិ

**ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** ("ក្រមនីតិវិធីព្រហ្មទណ្ឌ") និង**ច្បាប់ស្តីពីយុត្តិធម៌អនីតិជន** ក៏ធានានូវសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ជនជាប់ចោទជាមនុស្សធំពេញវ័យ និងកុមារ។

- **មាត្រា១៤(៣)(ក) នៃក.អ.ស.ព.នៈ** *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ។"*
- **មាត្រា១៤(៣)(ច) នៃក.អ.ស.ព.នៈ** *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានជំនួយពី អ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬ មិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ។"*

---

[6] ម.ស.ម.ក "ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ៈ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ និងសេចក្តីពន្យល់អំពីសិទ្ធិសម្រាប់ជនជាប់ចោទជាស្ត្រី" (ខែមីនា ឆ្នាំ២០២១) https://docs.google.com/viewerng/viewer?url=https://cchrcambodia.org/admin/media/newsletter/newsletter/english/CCHR+Fair+Trial+Rights+Newsletter+on+Right-EN.pdf។

[7] ម.ស.ម.ក "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រ ១៨ https://sithi.org/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook។

- **មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន"។*
- **មាត្រា ៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ក្នុងករណីចាំបាច់ ប្រធានអាចហៅកអ្នកបកប្រែ។"*
- **មាត្រា ៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"កាលណាសំណួរត្រូវសួរដល់ជនគ និងថ្លង់ ក្រឡាបញ្ជីត្រូវសរសេរសំណួរ ហើយឱ្យសាមីខ្លួនអាន និងឆ្លើយជាលក្ខណ៍អក្សរ។ ក្នុងករណីដែលសាមីជនមិនចេះអាន ឬមិនចេះអក្សរ ប្រធានត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៣០ [...] ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជនគ និងថ្លង់នោះ មកបកប្រែ។"*
- **មាត្រា ៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"វិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូង ក៏ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍។"*
- **មាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន៖** *"អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖[...] សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី [...] សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់[...]"*
- **មាត្រា ៥១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន៖** *" "នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនយល់បានអំពីសិទ្ធិដូចខាងក្រោម៖ សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ [...]។""*

## ៣. សារៈសំខាន់

សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ នៅដំណាក់កាលមុនពេលជំនុំជម្រះ និងដំណាក់កាលនៃការជំនុំជម្រះមានសារៈសំខាន់ណាស់ដើម្បី៖



- ធានាថាជនជាប់ចោទដឹងអំពីមូលហេតុដែលខ្លួនត្រូវបានចោទប្រកាន់។
- ធានាថាជនជាប់ចោទអាចជំទាស់នឹងការឃុំឃាំងណាមួយដែលខ្លួនត្រូវទទួលរងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

- ធានាថាជនជាប់ចោទមានឱកាសការពារក្ដីបានល្អបំផុត។ ដូច្នេះ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់គឺជាផ្នែកដ៏សំខាន់មួយនៃ**សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី**។[8]
- ដើម្បីការពារជនជាប់ចោទពីបទចោទប្រកាន់ព្រហ្មទណ្ឌដែលគ្មានមូលដ្ឋាន។[9]

អាស្រ័យហេតុនេះ ប្រការដែលអាជ្ញាធរមិនគោរពសិទ្ធិនេះអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ជនជាប់ចោទនៅក្នុងការការពារក្ដីរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ពីការចោទប្រកាន់មកលើខ្លួន និងដែលនាំឱ្យមានការផ្ដន្ទាទោសខុស។

## ៤. ដែនកំណត់

សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មានចែងនៅក្នុងមាត្រា ១៤ នៃ ក.អ.ស.ព.ន។ មាត្រា ១៤ មិនមានចែងនៅបញ្ជីសិទ្ធិមិនអាចត្រូវបានដកហូតបាន[10] ដែលមានចែងនៅក្នុងមាត្រា ៤ នៃ ក.អ.ស.ព.ន (ការដកហូតក្នុងគ្រាអាសន្ន)។ ទោះយ៉ាងណាក៏ដោយ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានលើកឡើងថា ការរក្សាសិទ្ធិទូទៅចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺមិនស្របតាមកម្មវត្ថុ និងគោលបំណងនៃ ក.អ.ស.ព.ន នោះទេ។ ដូច្នេះ ការអនុវត្តទាំងឡាយណាដែលងាកចេញពីគោលការណ៍មូលដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌គឺត្រូវបានហាមឃាត់គ្រប់ពេលទាំងអស់។[11]



សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ អាចអនុវត្តបានតែពេលមានការសម្រេចចោទប្រកាន់ជនជាប់ចោទប៉ុណ្ណោះ ពោលគឺមិនមែននៅក្នុងដំណើរការនីតិវិធីស៊ើបអង្កេតព្រហ្មទណ្ឌដែលធ្វើការចោទប្រកាន់នោះទេ។[12] សិទ្ធិទទួលបានការជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួននៅក្នុងអំឡុងពេលស៊ើបអង្កេតឧក្រិដ្ឋកម្ម និងនៅមុនពេលការចោទប្រកាន់ជាផ្លូវការ គឺត្រូវបានធានានៅក្នុងមាត្រាមួយផ្សេងទៀតនៃ ក.អ.ស.ព.ន (មាត្រា ៩ (២))។

[8] OSCE, "ធាតុចូលផ្លូវច្បាប់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ" ទំព័រ ១១៦ https://www.osce.org/odihr/94214#:~:text=The%20Legal%20Digest%20of%20International,of%20OSCE%20trial%20monitoring%20operations ។

[9] ម.ស.ម.ក "សៀវភៅណែនាំស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" ទំព័រ ១៧

[10] សិទ្ធិមិនអាចដកហូតបាន៖ ជាសិទ្ធិដែលការអនុវត្តនូវសិទ្ធិនេះមិនអាចព្យួរដោយរដ្ឋាភិបាលនៅក្នុងស្ថានភាពនៃ "រដ្ឋក្នុងគ្រាមានអាសន្ននៅក្រោម" មាត្រា ៤ នៃ ក.អ.ស.ព.ន.។

[11] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "សេចក្ដីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៥ និង ៦ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "សេចក្ដីពន្យល់ទូទៅលេខ ២៩ មាត្រា ៤៖ ការដកហូតសិទ្ធិនៅគ្រាមានអាសន្ន" (CCPR/C/២១/កំណែ ១/សេចក្ដីបន្ថែម ១១ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១) កថាខណ្ឌ ១១, https://www.refworld.org/docid/453883fd1f.html ។

[12] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "សេចក្ដីពន្យល់ទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងអង្គជំនុំជម្រះ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (CCPR/C/GC/32 ខែសីហា ឆ្នាំ២០០៧) កថាខណ្ឌ ៣១។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់តម្រូវឱ្យជនរងការចោទប្រកាន់ និងមេធាវីរបស់គេទទួលបាននូវព័ត៌មានឆាប់រហ័សដូចខាងក្រោម៖

☐ក. ដឹងអំពីច្បាប់ដែលត្រូវបានយកមកចោទប្រកាន់

☐ខ. ដឹងអំពីអង្គហេតុដែលជាមូលដ្ឋាននៃការចោទប្រកាន់

☐គ. ក និង ខ

២. ព័ត៌មានលម្អិតទាក់ទងនឹងមូលហេតុនៃការចោទប្រកាន់អាចត្រូវបានផ្តល់ឱ្យជនជាប់ចោទតាមរយៈ៖

☐ក. ជាលាយលក្ខណ៍អក្សរ

☐ខ. ដោយផ្ទាល់មាត់

☐គ. ដោយផ្ទាល់មាត់ និងសរសេរជាលាយលក្ខណ៍អក្សរ

☐ឃ. ក និង គ

៣. សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ គឺមានសារៈសំខាន់ណាស់សម្រាប់ជនរងការចោទប្រកាន់ មានពេលវេលាគ្រប់គ្រាន់ និងងាយស្រួលក្នុងការត្រៀមការពារខ្លួនបានល្អ។

☐ក. ត្រូវ

☐ខ. ខុស

៤. តុលាការមានសិទ្ធិក្នុងការមិនផ្តល់អ្នកបកប្រែ ក្នុងករណីជនជាប់ចោទជាជនបរទេស ដោយសារតែគាត់បានប្រព្រឹត្តបទល្មើសច្រើនដង។

☐ក. ត្រូវ

☐ខ. ខុស

៥. បើសិនជាជនជាប់ចោទជាជនជាតិដើមភាគតិច ដែលមិនសូវចេះភាសាខ្មែរ តើតុលាការត្រូវផ្តល់អ្នកបកប្រែដោយឥតគិតថ្លៃដល់ជនជាប់ចោទដែលអាចឱ្យពួកគេអាចយល់ពីបទចោទប្រឆាំងពួកគេនោះដែរ ឬទេ?

☐ក. មិនចាំបាច់ទេ

☐ខ. ត្រូវតែផ្តល់ឱ្យ

៦. នៅពេលសវនាការ ចៅក្រមមិនបានរំលឹកជនរងការចោទប្រកាន់អំពីបទចោទប្រកាន់ និងមិនពន្យល់អំពីការចោទប្រកាន់ទៅពួកគេគ្រប់គ្រាន់ តើចៅក្រមបំពានលើសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ដែរ ឬទេ?

☐ក. បាទ/ចាស

☐ខ. ទេ

៧. សមត្ថកិច្ចបានអះអាងថា ជនដែលរងការចោទប្រកាន់ជាជនកម្សោយក្នុងការស្តាប់ និងនិយាយ មិនចាំបាច់ត្រូវជូនព័ត៌មានពីមូលហេតុ និងប្រភេទនៃការចោទប្រកាន់នោះទេ។

☐ក. ត្រូវតែជូនដំណឹង

☐ខ. មិនត្រូវជូនដំណឹងទេ

☐គ. ត្រូវជូនដំណឹងទាំងជនកម្សោយក្នុងការស្តាប់ និងនិយាយ និង/ឬជនធម្មតា

# សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង






# មាតិកា


១. និយមន័យ ..... 33
២. ក្របខ័ណ្ឌច្បាប់ ..... 34
 ២.១. ច្បាប់អន្តរជាតិ ..... 34
 ២.២. ច្បាប់ជាតិ ..... 35
៣. សារៈសំខាន់ ..... 36
៤. ដែនកំណត់ ..... 36
៥. សំណួរ ..... 38

## ១. និយមន័យ



បុគ្គលគ្រប់រូប ដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង (ឬសិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង)។ សិទ្ធិនេះអនុវត្តមុនដំណាក់កាលជំនុំជម្រះ និងនៅពេលជំនុំជម្រះ[1] និងមានទិដ្ឋភាពពីរ៖

- ជនដែររងការចោទប្រកាន់ **មិនអាចត្រូវបានបង្ខិតបង្ខំ ឬបង្ខំឱ្យផ្តល់ភស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ**។

ក្នុងការអនុវត្ត នេះមានន័យថា នៅពេលដែលជនរងការចោទប្រកាន់ ធ្វើការសារភាព គឺត្រូវធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ មិនថាដោយផ្ទាល់ ឬដោយប្រយោល តាមផ្លូវកាយ ឬផ្លូវចិត្ត។

- ជនជាប់ចោទ**មិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯងតាមរយៈការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង**ឡើយ។ សិទ្ធិប្រឆាំងនឹងការឆ្លើយដាក់បន្ទុកលើខ្លួនឯង គឺជាធាតុផ្សំយ៉ាងសំខាន់នៃដំណើរការនីតិវិធីតុលាការ ដោយសារតែពិបាកក្នុងការស្រមៃថាការជំនុំជម្រះដោយយុត្តិធម៌ ដែលក្នុងនោះជនជាប់ចោទត្រូវបានបង្ខំឱ្យផ្តល់ភស្តុតាងដាក់បន្ទុកលើខ្លួនឯង។

ហេតុដូច្នេះ សិទ្ធិនេះត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងការទទួលស្គាល់ជាអន្តរជាតិលើ**ការហាមឃាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប** ដែលមានចែងក្នុងមាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ("ក.អ.ស.ព.ន")។ ប្រសិនបើការសារភាព ឬចម្លើយណាមួយត្រូវបានទទួលតាមរយៈការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬទម្រង់ផ្សេងៗទៀតនៃការធ្វើឱ្យមានការឈឺចាប់ ដែលវាមិនត្រូវបានចាត់ជាភស្តុតាងឡើយ លើកលែងតែត្រូវបានប្រើជាភស្តុតាងដែលបានបញ្ជាក់ពីការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬទម្រង់ផ្សេងៗទៀតនៃការប្រព្រឹត្តបានកើតឡើង។[2]នេះគឺមានសារៈសំខាន់ណាស់ដើម្បីបែងចែកសិទ្ធិនេះពីការសម្រេចចិត្តរបស់ជនដែររងការចោទប្រកាន់ក្នុងការផ្តល់ការសារភាពដោយស្ម័គ្រចិត្ត។ កត្តាចម្បងក្នុងការបែងចែកនេះ គឺជាធាតុផ្សំនៃការជ្រើសរើស ថាតើភាគីមួយជ្រើសរើសក្នុងការ



[1] អង្គការលើកលែងទោសអន្តរជាតិ, "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (ឆ្នាំ២០១៤) ទំព័រ ១២៩, https://sithi.org/tmp/publication/view/2014-04-10-fair-trial-manual-published-by-amnesty-international។

[2] ម.ស.ម.ក "ព្រឹត្តិបត្រព័ត៌មានស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង" លេខ១១ (ឆ្នាំ ២០២០) https://cchrcambodia.org/admin/media/newsletter/newsletter/khmer/CCHR%20Fair%20Trial%20Rights%20Newsletter%20on%20the%20right%20not%20to%20be%20compelled%20to%20confess%20guilt%20or%20to%20testify%20against%20oneself_KH.pdf ។

ផ្តល់ចម្លើយដាក់បន្ទុកលើខ្លួនឯង ឬការសារភាព ឬថាតើពួកគេត្រូវបានបង្ខំដោយអង្គភាពខាងក្រៅឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង។[3] ហេតុដូច្នេះ ជាការសំខាន់ដែលចៅក្រមផ្ទៀងផ្ទាត់ថាតើការសារភាពដោយស្ម័គ្រចិត្ត ដូចជាការសារភាពទោស ត្រូវបានទទួលយកដោយជនជាប់ចោទដោយគ្មានសម្ពាធណាមួយ និងដែលជនជាប់ចោទយល់ពីមូលហេតុនៃការចោទប្រកាន់ និងលទ្ធផលនៃការសារភាពដោយស្ម័គ្រចិត្តបែបនេះ។[4]

សរុបមក ដើម្បីធានាថា សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងត្រូវបានគោរព និងថា ជនជាប់ចោទត្រូវបានការពារពីការបង្ខិតបង្ខំដោយអាជ្ញាធរស៊ើបអង្កេត នេះជាការសំខាន់ ដែលជនជាប់ចោទទទួលបានមេធាវី[5] ដែលនឹងមានវត្តមាននៅអំឡុងពេលនៃការសួរចម្លើយ។ វត្តមានរបស់មេធាវីអាចរារាំងនគរបាលយុត្តិធម៌ពីការមិនគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទបាន។[6]

# ២. ក្របខ័ណ្ឌច្បាប់

## ២.១. ច្បាប់អន្តរជាតិ

**សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង** មានចែងយ៉ាងច្បាស់ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ("ក.អ.ស.ព.ន") និងអនុសញ្ញាស្តីពីសិទ្ធិកុមារ("អ.ស.ក")។ បន្ថែមលើនេះ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងអនុញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ហាមឃាត់ទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតណាមួយ ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលសំខាន់ក្នុងការការពារសិទ្ធិនេះ។

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដាក់បញ្ចូលសន្ធិសញ្ញាទាំងនេះក្នុងការអនុវត្តដោយផ្ទាល់ទៅក្នុងច្បាប់ជាតិកម្ពុជា។

---

[3] ម.ស.ម.ក. "សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រ ២៤ https://sithi.org/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook។

[4] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ទំព័រ១៣០។

[5] ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "សេចក្តីសន្និដ្ឋាន ការសង្កេត៖ ប្រទេសបារាំង" (UN Doc ក.អ.ស.ព.ន/C/FRA/CO/៤ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨) កថាខណ្ឌ១៤ https://undocs.org/en/CCPR/C/FRA/CO/4។

[6] ម.ស.ម.ក "ព្រឹត្តិបត្រព័ត៌មានស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង" លេខ១១, (ឆ្នាំ២០២០)។

**មាត្រា ១៤ កថាខណ្ឌ ៣ (ឆ) នៃ ក.អ.ស.ព.ន៖** "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមាដោយស្មើភាពគ្នាយ៉ាងពេញលេញ [...]

- (ឆ) មិនត្រូវបានបង្ខិតបង្ខំ ឬសារភាពថាមានពិរុទ្ធ" ។

**មាត្រា ៧នៃ ក.អ.ស.ព.ន៖** "គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឱ្យថោកទាបឡើយ។ ជាពិសេស ហាមយកជនណាម្នាក់ មកធ្វើការពិសោធន៍ខាងពិសោធន៍ខាងវេជ្ជសាស្រ្ត ឬវិទ្យាសាស្រ្ត ដោយគ្មានការយល់ព្រមដោយសេរីពីសាម៉ីខ្លួនឡើយ។"

**មាត្រា ៤០ (២)(iv) នៃ អ.ស.ក៖** "[...] ក្នុងទិសដៅនេះ និងដោយគិតទៅនឹងបទប្បញ្ញត្តិនៃលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ រដ្ឋភាគីត្រូវធានា: [...]

- (iv) មិនត្រូវទទួលរងការបង្ខិតបង្ខំឱ្យផ្តល់សក្ខីកម្ម ឬសារភាពកំហុសឡើយ [...] ។"

**មាត្រា ៥ នៃ ស.ស.ស.ម៖** "គ្មាននរណាធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើឃោរឃៅ ឬផ្តន្ទាទោសឱ្យយើងបាត់តម្លៃជាមនុស្សនោះឡើយ"។

**មាត្រា ១ នៃអនុសញ្ញាប្រឆាំងទារុណកម្ម៖** "ដើម្បីគោលបំណងនៃអនុសញ្ញានេះពាក្យ "ទារុណកម្ម" មានន័យថា អំពើទាំងឡាយណា ដែលនាំឱ្យមានការឈឺចាប់ ឬរងទុកយ៉ាងខ្លាំង ទោះផ្លូវកាយក្តី ឬផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយណាដូចជាទាញយកព័ត៌មានពីជននោះ ឬតតិយជនណាម្នាក់ [...]"។







## ២.២. ច្បាប់ជាតិ

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង និងការហាមឃាត់ទារុណកម្ម និងទម្រង់ផ្សេងទៀតនៃការធ្វើបាប ក៏ត្រូវបានធានាដោយច្បាប់ជាតិផងដែរ រួមមាននៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ក្រមនីតិព្រហ្មទណ្ឌ") និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

**មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ៖** "ច្បាប់ការពារមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ [...] ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយ តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ [...]។"



## ៣. សារៈសំខាន់



សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺជាជាតុផ្សំជាមូលដ្ឋាននៃគោលការណ៍**សន្មតទុកជាមុនថាគ្មានទោស** ដែលដាក់បន្ទុកភស្តុតាងទៅលើអយ្យការ។[7] ការសន្មតទុកជាមុនថាគ្មានទោសគឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មូលដ្ឋានសំខាន់ និងដែលត្រូវបានបង្កើតឡើងដោយល្អ[8] ព្រមទាំងជាធាតុផ្សំសំខាន់នៃនីតិរដ្ឋ។[9] ចំណែកក្នុងការ**ជៀសវាងការខុសឆ្គងក្នុងការជម្រះក្តីកាន់ប្រឡំរបស់តុលាការ**ផងដែរ[10] ដោយការពារជនជាប់ចោទពីការបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ដោយមិនគិតពីពិរុទ្ធភាព ឬភាពគ្មានទោស តាមរយៈការប្រើប្រាស់ការបង្ខិតបង្ខំ ឬទារុណកម្ម។

អាស្រ័យហេតុនេះ ការមិនគោរពសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់ការសន្មតទុកជាមុនថាគ្មានទោស និងអាចឈានទៅដល់ការផ្តន្ទាទោសខុស ដោយផ្អែកលើការសារភាពដែលទទួលបានតាមរយៈការបង្ខិតបង្ខំ ឬទារុណកម្ម។

## ៤. ដែនកំណត់



ការហាមឃាត់ការធ្វើទារុណកម្ម ដែលរួមបញ្ចូលក្នុងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺមានលក្ខណៈដាច់ខាត។ មាត្រា ៧ នៃ ក.អ.ស.ព.ន ដែលហាមឃាត់ទារុណកម្ម និងទម្រង់ផ្សេងទៀតនៃការធ្វើបាប មិនត្រូវបានដកហូតគ្រប់ដំណាក់កាលទាំងអស់។[11] គ្មានកាលៈទេសៈ ឬហេតុផលណាមួយអាចកែតម្រូវការប្រើប្រាស់ទារុណកម្ម ឬការធ្វើបាបផ្សេងទៀត ដើម្បីទទួលបានការសារភាពពីនរណាម្នាក់ឡើយ។ ហេតុដូច្នេះហើយ គ្មានចម្លើយ ឬការសារភាពណា ឬជាគោលការណ៍ ភស្តុតាងផ្សេងទៀតដែលទទួលបានពីការរំលោភបំពានលើបទប្បញ្ញត្តិនេះ អាចត្រូវបានយកមកធ្វើជាភស្តុតាងនៅក្នុងដំណើរការនីតិវិធីណាមួយដែលគ្របដណ្តប់ដោយមាត្រា ១៤ នៃ ក.អ.ស.ព.ន រួម



[7] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជ្រះដោយយុត្តិធម៌" ទំព័រ ១២៩។
[8] ម.ស.ម.ក "សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ។
[9] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌" ការបោះពុម្ពផ្សាយលើកទី២ (ឆ្នាំ២០១៤) ទំព័រ ១២៥ ។
[10] OSCE "សេចក្តីសង្ខេបផ្លូវច្បាប់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ" (ឆ្នាំ២០១២) ទំព័រ ៩៩។ https://www.osce.org/odihr/94214។
[11] សិទ្ធិមិនអាចបដិប្បញ្ញត្តិ: សិទ្ធិដែលមិនអាចព្យួរបានដោយរដ្ឋាភិបាលនៅក្នុងកាលៈទេសៈនៃ"រដ្ឋស្ថិតក្នុងភាពអាសន្ន" តាមមាត្រា ៤ នៃ ក.អ.ស.ព.ន។

ទាំងនៅអំឡុងពេលប្រទេសស្ថិតក្នុងគ្រាអាសន្ន។[12] ហេតុដូចនេះ ចម្លើយដាក់បន្ទុកលើខ្លួនឯង ឬការសារភាពណាមួយដែលទទួលបានដោយមិនស្ម័គ្រចិត្ត មិនមានតម្លៃជាភស្តុតាងឡើយ។ លើកលែងតែករណីមួយគត់ផ្អែកលើចម្លើយ ឬការសារភាពដែលទទួលបានដោយរំលោភបំពានលើមាត្រា ៧ ប្រសិនបើត្រូវបានប្រើប្រាស់ជាភស្តុតាងដែលទារុណកម្ម ឬការប្រព្រឹត្តផ្សេងទៀតត្រូវបានហាមឃាត់តាមមាត្រានេះបានកើតឡើង។[13] ហេតុដូចនេះ ជនសង្ស័យ/ជនជាប់ចោទប្រើប្រាស់សិទ្ធិមិនផ្តល់ភស្តុតាងដែលអាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងពួកគេដោយមិនមានការរារាំង។[14] ទោះបីជាយ៉ាងនេះក្តី សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង បានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹង**សិទ្ធិនៅស្ងៀម** ដែលមានចរិតលក្ខណៈដាច់ខាត ជាកម្មវត្ថុនៃការយល់ឃើញខុសគ្នា ដោយសារតែប្រទេសមួយចំនួនអនុញ្ញាតឱ្យមានការសន្និដ្ឋានជំទាស់ ដើម្បីទាញចេញពីភាពស្ងៀមស្ងាត់របស់ជនជាប់ចោទនៅអំឡុងពេលសាកសួរ។



គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានបង្ហាញពីការព្រួយបារម្ភរបស់ខ្លួនទាក់ទងនឹងការទាញការសន្និដ្ឋានបែបអវិជ្ជមានពីការនៅស្ងៀមស្ងាត់របស់ជនជាប់ចោទ និងបានផ្តល់ជំបូន្មានដល់រដ្ឋដែលជាភាគីនៃ ក.អ.ស.ព.ន ឱ្យពិចារណាឡើងវិញនូវការអនុវត្តបែបនេះ ដើម្បីធានាថាពួកគេគោរពតាមមាត្រា ១៤ នៃ ក.អ.ស.ព.ន។[15] ទោះជាយ៉ាងនេះក្តី តុលាការអឺរ៉ុបពិចារណាថា សិទ្ធិនៅស្ងៀម គឺមិនមានលក្ខណៈដាច់ខាតទេ និងថាការសន្និដ្ឋានជំទាស់អាចត្រូវបានដកចេញពីភាពស្ងៀមស្ងាត់របស់ជនជាប់ចោទក្នុងកាលៈទេសៈជាក់លាក់។[16] យ៉ាងណាមិញ ការសន្និដ្ឋានបែបនេះត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្ន។[17] លើសពីនេះទៀត សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងត្រូវបានកម្រិតចំពោះសិទ្ធិនៅស្ងៀម ដែលការពារជនជាប់ចោទពីការឆ្លើយដាក់បន្ទុកលើខ្លួនឯង និងមិនបានរារាំងអយ្យការពីការបង្កើតភស្តុតាងជាសម្ភារៈនៅពេលជំនុំជម្រះ ដូចជាឯកសារ ឈាម ឬសំណាករាងកាយផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ជនជាប់ចោទ និងដែលអាចដាក់បន្ទុកលើពួកគេ។[18]

---

[12] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ៣២-- *មាត្រា ១៤ សិទ្ធិស្មើភាពគ្នានៅមុនពេលជំនុំជម្រះ និងក្នុងពេលជំនុំជម្រះ នៃការជំនុំជម្រះដោយយុត្តិធម៌* (UN Doc CCPR/C/GC/៣២, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧), កថាខណ្ឌ៦ https://www.refworld.org/docid/478b2b2f2.html ។

[13] ដូចខាងលើ។

[14] ម.ស.ម.ក "របាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ (ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ថ្ងៃ៣១ ខែតុលាការ ឆ្នាំ២០២០)" ខែតុលា ឆ្នាំ២០២០ ទំព័រ ១៩។

[15] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ «សេចក្តីសន្និដ្ឋានការសង្កេតលើចក្រភពអង់គ្លេស និងទឹកដីបរទេសរបស់ចក្រភពអង់គ្លេស» (UN Doc CCPR/CO/73/UK CCPR/CO/73/UKOT, ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០១) កថាខណ្ឌ ១៧ https://www.refworld.org/docid/3cbbec3d2.html។

[16] តុលាការអឺរ៉ុប O'Halloran and Francis ទល់នឹងចក្រភពអង់គ្លេស (ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧)។

[17] សូមមើល "សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌" អង្គការលើកលែងទោសអន្តរជាតិ (ឆ្នាំ២០១៤) ទំព័រ ១៣១។

[18] OSCE, "សេចក្តីសង្ខេបផ្លូវច្បាប់នៃសិទ្ធិជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ" (ឆ្នាំ២០១២) ទំព័រ ៩៩។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាពឬការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងសំដៅដល់ការឆ្លើយសារភាពរបស់ជនរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌដែលបានធ្វើឡើងដោយមិនមានការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯងតាមរយៈការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងឡើយ។

□ក. ត្រូវ □ខ. ខុស

២. តើបម្រាមណាមួយដែលត្រូវជាមួយនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព និងផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង?

□ក. ការហាមឃាត់ការវិនិច្ឆ័យទោស២ដងចំពោះអំពើដដែល

□ខ. ការហាមការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប

□គ. ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

□ឃ. មិនមាន

៣. តុលាការអាចយកចម្លើយសារភាពដែលបានតាមរយៈការគំរាមកំហែង ឬការធ្វើទារុណកម្ម ដើម្បីធ្វើជាភស្តុតាងក្នុងតុលាការសម្រាប់ការពិចារណាក្នុងការផ្តន្ទាទោសលើជនជាប់ចោទបាន។

□ក. ត្រូវ □ខ. ខុស

៤. តើបទដ្ឋានច្បាប់ជាតិណាខ្លះដែលធានាដល់សិទ្ធិមិនត្រូវបានបង្ខំឱ្យសារភាព ឬផ្តល់សក្ខីកម្មប្រឆាំងលើខ្លួនឯង?

□ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

□ខ. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

□គ. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

□ឃ. ក និង គ

៥. តើសកម្មភាពណាខ្លះ ដែលជាសកម្មភាពរំលោភបំពានលើសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង?

□ក. មន្ត្រីនគរបាលយុត្តិធម៌ឱ្យជនសង្ស័យផ្តិតមេដៃលើកំណត់ហេតុស្តាប់ចម្លើយ ដោយមិនបានឱ្យជនសង្ស័យអាន ឬអានឱ្យជនសង្ស័យស្តាប់។

□ខ. ជនសង្ស័យត្រូវបានប៉ូលីសវាយដំពេលសួរចម្លើយ

□គ. ក និង ខ

៦. តើច្បាប់អន្តរជាតិណាខ្លះដែលបានចែងពីសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាពឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង?

□ក. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

□ខ. អនុសញ្ញាស្តីពីសិទ្ធិកុមារ

□គ. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

☐ឃ. អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទារុណកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

☐ង. ក និង ខ

៧. តើសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាពត្រូវបានគោរពនៅដំណាក់កាលណា?

☐ក. នៅមុនពេលជំនុំជម្រះ (ឧ. នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា...)

☐ខ. នៅពេលជំនុំជម្រះ

☐គ. ក និង ខ

៨. ការហាមឃាត់នៃការធ្វើទារុណកម្មគ្របដណ្តប់លើសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង ជាសិទ្ធិមួយដែលអនុញ្ញាតឱ្យមានការដកហូតបាន។

☐ក. ត្រូវ

☐ខ. ខុស

# សិទ្ធិមានមធ្យោបាយ និងពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និង សិទ្ធិនិយាយជាមួយមេធាវី



# មាតិកា

១ . និយមន័យ. ........................................................................................................ 40
១ .១. សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី...................................... 40
១. ២. សិទ្ធិនិយាយជាមួយមេធាវី ..................................................................................41
២ . ក្របខ័ណ្ឌច្បាប់ ....................................................................................................... 42
២.១.ច្បាប់អន្តរជាតិ ...................................................................................................... 42
២.២.ច្បាប់ជាតិ ........................................................................................................... 42
៣ . សារៈសំខាន់.......................................................................................................... 43
៤ . ដែនកំណត់ ............................................................................................................ 43
៥.សំណួរ ................................................................................................................ 45

# ១. និយមន័យ

## ១.១. សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី

សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីមានចែងអំពីលក្ខណៈវិនិច្ឆ័យដែលត្រូវការ ដើម្បីធានាថាជនជាប់ចោទមានមធ្យោបាយអាចរៀបចំការពារក្តីបានត្រឹមត្រូវ។ សិទ្ធិនេះអនុវត្តនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីផ្លូវច្បាប់ទាំងអស់ និងចំពោះការចោទប្រកាន់រឿងព្រហ្មទណ្ឌទាំងអស់ដោយមិនគិតអំពីភាពធ្ងន់ធ្ងរនោះទេ។[1]

- ពេលវេលាគ្រប់គ្រាន់៖ រយៈពេលដែល "គ្រប់គ្រាន់" អាស្រ័យទៅលើ**កាលៈទេសៈនៃសំណុំរឿងនីមួយៗ**។[2] កត្តាដែលពាក់ព័ន្ធរួមមាន ភាពស្មុគស្មាញនៃសំណុំរឿង ការទទួលបានព័ត៌មានរបស់ជនជាប់ចោទនូវភស្តុតាង និងពេលវេលាកំណត់ ដែលមានចែងនៅក្នុងច្បាប់ជាតិ ទោះបីជាកត្តាទាំងនេះតែមួយគត់មិនមែនជាសេចក្តីសម្រេចក៏ដោយ។ គោលការណ៍ណែនាំនៃលក្ខខណ្ឌតម្រូវនៃ "ពេលវេលាគ្រប់គ្រាន់" គឺដើម្បីធានាថាជនជាប់ចោទអាចរៀបចំបានត្រឹមត្រូវក្នុងការការពារក្តីទល់ នឹងភស្តុតាងរបស់អយ្យការ ការស៊ើបអង្កេត និងការបង្ហាញសាក្សីការពារក្តី។[3] ប្រសិនបើមេធាវីការពារក្តីយល់ថាពួកគេពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តីឱ្យបានគ្រប់គ្រាន់ទេនោះ ពួកគេអាចស្នើសុំការពន្យារពេលសវនាការ នេះគឺជាតួនាទីរបស់ពួកគេក្នុងការស្នើសុំការពន្យារពេលនេះ។[4] តុល្យភាពត្រូវតែមានរវាងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅក្នុង រយៈពេលមួយដែលសមហេតុផល និងសិទ្ធិមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី។[5]



- **មធ្យោបាយគ្រប់គ្រាន់៖** មធ្យោបាយចាំបាច់ដែលមេធាវីការពារក្តីត្រូវការរួមមាន៖[6]

---

[1] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ការបោះពុម្ពផ្សាយលើកទីពីរ (ខែមេសា ឆ្នាំ២០១៤) ទំព័រ ៧៤ /https://www.amnesty.org/en/documents/pol30/002/2014/en។

[2] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២--មាត្រា១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ,(CPPR/C/GC/32 ២៣ ខែសីហា ,ឆ្នាំ២០០៧ ,(កថាខណ្ឌ ៣២ និង ៤៩, https://www.refworld.org/docid/478b2b2f2.html (គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២)។

[3] ម.ស.ម.ក "ការឃ្លាំមើលសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅប្រទេសកម្ពុជានៅ សាលាឧទ្ធរណ៍៖ របាយការណ៍ប្រចាំឆ្នាំ ខែវិច្ឆិកា ឆ្នាំ២០១៩ – ខែធ្នូ ឆ្នាំ២០២០" (ខែវិច្ឆិកា ឆ្នាំ២០២១) ទំព័រ ២៣ https://docs.google.com/viewerng/viewer?url=https://www.cchrcambodia.org/admin/media/report/report/english/FTR-Annual-Report-English-2019-2020.pdf ។

[4] សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣២។

[5] ម.ស.ម.ក "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការឃ្លាំមើលការជំនុំជម្រះ" (ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រ ១៦ https://cchrcambodia.org/admin/media/report/report/english/CCHR_FTR_and_Trial_Monitoring_Handbook_Feb%202012 ENG.pdf_។

[6] សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣២ និង ៣៣ https://www.refworld.org/docid/478b2b2f2.html។

- ការទទួលបានឯកសារសំណុំរឿង និងភស្តុតាងដើម្បីឱ្យជនជាប់ចោទអាចដឹងច្បាស់អំពីការចោទប្រកាន់មកលើពួកគេ និងអាចផ្តល់ការណែនាំពេញលេញដល់មេធាវីរបស់ពួកគេ។ ដូច្នេះសិទ្ធិនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ភ្លាមៗ។ (សូមមើលមេរៀនអំពីសិទ្ធិយល់ដឹងឲ្យកាន់តែច្បាស់អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់)។
- **ការទទួលបានឯកសារទាំងអស់ដែលតំណាងអយ្យការគ្រោងនឹងបង្ហាញនៅក្នុងតុលាការ ឬដែលមានលក្ខណៈដោះបន្ទុក** ដែលមានន័យថាជាឯកសារដែលបង្ហាញពីភាពគ្មានទោស និងភស្តុតាង ដែលអាចជួយដល់ការការពារក្តី។



- នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ការទទួលបាន**សេចក្តីសម្រេចដោយមានមូលហេតុត្រឹមត្រូវជាលាយលក្ខណ៍អក្សរ** និង**ការពណ៌នាអំពីការជំនុំជម្រះរបស់ពួកគេ**។ សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ គឺមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យជនជាប់ចោទអាចរៀបចំការការពារក្តីប្រកបដោយប្រសិទ្ធភាព *(សូមមើលមេរៀនអំពីសិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ សម្រាប់ព័ត៌មានលម្អិតបន្ថែម)*។

## ១.២. សិទ្ធិនិយាយជាមួយមេធាវី

ដើម្បីរៀបចំការពារក្តី ជនជាប់ចោទត្រូវមានពេលវេលាក្នុងការទំនាក់ទំនងជាមួយមេធាវីដែលខ្លួនបានជ្រើសរើស ដូច្នេះ ពួកគេត្រូវទទួលបានការអនុញ្ញាតឱ្យមានមេធាវីការពារក្តីភ្លាមៗ។ សិទ្ធិនេះផ្តល់ជូនចំពោះជនជាប់ចោទទាំងអស់ ប៉ុន្តែគឺកាន់តែមានសារៈសំខាន់នៅពេលដែលជនជាប់ចោទស្ថិតនៅក្រោមការឃុំខ្លួន ឬជាប់ពន្ធនាគារ។[7]



មធ្យោបាយអាចឱ្យការប្រាស្រ័យទាក់ទងដោយសម្ងាត់រវាងជនជាប់ចោទ និងមេធាវីរបស់ពួកគេត្រូវតែមាន[8] ជាពិសេស នៅពេលដែលជនជាប់ចោទកំពុងស្ថិតក្រោមការឃុំខ្លួន។ ដើម្បីឱ្យសិទ្ធិនេះអាចអនុវត្តដោយប្រសិទ្ធភាព ជនជាប់ចោទត្រូវតែអាចធ្វើការប្រាស្រ័យទាក់ទងជាមួយមេធាវីរបស់ពួកគេដោយសម្ងាត់ និងគ្មានការរឹតត្បិត អំណាច ឬការជ្រៀតជ្រែកហួសហេតុ។[9]

---

[7] OSCE "អត្ថបទច្បាប់ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (ឆ្នាំ២០១២) ទំព័រ ១២០ https://www.osce.org/odihr/94214#:~:text=The%20Legal%20Digest%20of%20International,of%20OSCE%20trial%20monitoring%20operations។

[8] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៤ https://www.refworld.org/docid/478b2b2f2.html។

[9] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ការបោះពុម្ពផ្សាយលើកទីពីរ (ខែមេសា ឆ្នាំ២០១៤) ទំព័រ ៧៥ /https://www.amnesty.org/en/documents/pol30/002/2014/en ។

## ២. ក្របខ័ណ្ឌច្បាប់

សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិនិយាយជាមួយមេធាវី ត្រូវបានការពារយ៉ាងច្បាស់ដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដែលអាចអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់ជាតិកម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

### ២.១. ច្បាប់អន្តរជាតិ

- **មាត្រា ១៤(៣)(ខ) នៃ ក.អ.ស.ព.ន៖**
  *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងការប្រាស្រ័យទាក់ទងជាមួយមេធាវីដែលខ្លួនបានជ្រើសរើស"។*



### ២.២. ច្បាប់ជាតិ

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក៏ជានានូវសិទ្ធិទាំងនេះចំពោះជនជាប់ចោទពេញវ័យ និងកុមារទំនាស់នឹងច្បាប់។

- មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ៖ *"[...] ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅសវនាការក្រោយ [...]"*
- មាត្រា ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ *"កាលណាជនជាប់ចោទមានមេធាវីអមចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃមុនការសាកសួរចម្លើយ។ ក្នុងចំរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី [...]"*
- មាត្រា ២៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ *អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវី អាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ។ អគ្គព្រះរាជអាជ្ញាអមសាលា ឧទ្ធរណ៍ត្រូវប្រគល់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយូរបំផុត ១ (មួយ) ថ្ងៃមុនពេលសវនាការ។*
- មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ *មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿង នៅការិយាល័យក្រឡាបញ្ជីនៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។*
- មាត្រា ២៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន៖ *"ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់ របស់ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងភ្លាមៗដោយផ្ទាល់ និងដោយលាយលក្ខណ៍អក្សរទៅកាន់ អនីតិជន ហើយប្រសិនបើសមស្រប ត្រូវឱ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជនដើម្បីរៀបចំមធ្យោបាយការពារអនីតិជន។*

## ៣. សារៈសំខាន់



សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិនិយាយជាមួយមេធាវី គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការធានានូវការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការអនុវត្តគោលការណ៍ជាមូលដ្ឋាននៃសមភាពមធ្យោបាយ ដែលអនុញ្ញាតឱ្យទាំងតំណាងអយ្យការ និងមេធាវីការពារក្តីមានឱកាសស្មើគ្នាក្នុងការរៀបចំ និងបង្ហាញការពារសំណុំរឿងរបស់ពួកគេ។[10]

ការធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌មានវិសាលភាពហួសពីនៅក្នុងបន្ទប់សវនាការហើយបើមិនអនុញ្ញាតឱ្យជនជាប់ចោទមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី អាចមានហានិភ័យនាំឱ្យមានការផ្តន្ទាទោសខុស និងការមិនបានផ្តល់យុត្តិធម៌។

## ៤. ដែនកំណត់



សិទ្ធិរបស់ជនជាប់ចោទក្នុងការមានមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី ដែលផ្តល់សិទ្ធិឱ្យពួកគេទទួល បានឯកសារភស្តុតាងទាំងអស់ដែលតំណាងអយ្យការគ្រោងនឹងបង្ហាញនៅក្នុងតុលាការ ឬ ដែលជាការដោះបន្ទុក គឺមិនមែនជាសិទ្ធិដាច់ខាត ហើយដូច្នេះអាចរឹតត្បិតនៅក្នុងករណីពិសេស។

ក្នុងករណីខ្លះ តុលាការអាចអនុញ្ញាតឱ្យតំណាងអយ្យការដកយកនូវការបង្ហាញឯកសារមួយចំនួនពីមេធាវីការពារក្តី។ ទោះជាយ៉ាងណាក៏ដោយ ប្រការនេះអនុវត្តតែនៅក្នុងកាលៈទេសៈលើកលែងប៉ុណ្ណោះ ហើយត្រូវមានគោលបំណងស្របច្បាប់ ដូចជា ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់បុគ្គលផ្សេងទៀត (ឧ. ដើម្បីការពារសាក្សី មិនឱ្យមានហានិភ័យពីការសងសឹក)ដើម្បីការពារសន្តិសុខជាតិ ឬការពារផលប្រយោជន៍សាធារណៈសំខាន់ៗ (ឧ. ដើម្បីរក្សាការសម្ងាត់នៃការស៊ើបអង្កេតដើម្បីធានានូវប្រសិទ្ធភាព)។ ការរឹតត្បិតដែលអនុវត្ត ត្រូវមានភាពចាំបំផុត និងសមាមាត្រស្របតាមគោលបំណងស្របច្បាប់។[11]លើសពីនេះ ការរឹតត្បិតលើសិទ្ធិការពារក្តីក្នុងការទទួលបានឯកសារភស្តុតាងពាក់ព័ន្ធទាំងអស់ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃសវនាការនោះទេ។ ការរឹតត្បិតត្រូវមានការសម្រេចដោយតុលាការ ពោលគឺមិនមែនដោយតំណាងអយ្យការនោះទេ។ដើម្បីធ្វើ

---

[10] សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣២, អង្គការលើកលែងទោសអន្តរជាតិ, 'សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌'ការបោះពុម្ពផ្សាយលើកទីពីរ(ខែមេសាឆ្នាំ២០១៤)ទំព័រ៧៥
/https://www.amnesty.org/en/documents/pol30/002/2014/en។

[11] [11] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌ បោះពុម្ពផ្សាយលើកទីពីរ (ខែមេសា ឆ្នាំ ២០១៤) ទំព័រ ៧៨-៨៩ /https://www.amnesty.org/en/documents/pol30/002/2014/en OSCE "អត្ថបទច្បាប់ស្តីពីសិទ្ធិទទួលបានការជំនុំ ជម្រះដោយយុត្តិធម៌អន្តរជាតិ"(ឆ្នាំ២០១២)ទំព័រ១២៣-១២៤
https:www.osce.org/odihr/94214#:~:text=Date&text=The%20Legal%20Digest%20of%20International,of%20OSCE%20trial 20monitoring%20operations%។

ដូច្នេះបាន តុលាការត្រូវតែធានាថាគោលការណ៍សមភាពមធ្យោបាយត្រូវបានការពារ ហើយថាភាពយុត្តិធម៌នៃការជំនុំជម្រះត្រូវបានការពារ។[12]



**សិទ្ធិនិយាយជាមួយមេធាវី**របស់ជនស្ថិតនៅក្រោមការឃុំខ្លួន ឬជាប់ពន្ធនាគារអាចរឹតត្បិត ឬព្យួរនៅក្នុងកាលៈទេសៈលើកលែង។ កាលៈទេសៈទាំងនេះត្រូវតែមានបញ្ញាក់ដោយច្បាប់ ឬបទប្បញ្ញត្តិច្បាប់ ហើយតុលាការ ឬអាជ្ញាធរផ្សេងទៀតត្រូវចាត់ទុកថាមិនអាចខ្វះបានដើម្បីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ល្អ។[13] មិនថានៅក្នុងកាលៈទេសៈណាក៏ដោយ ការប្រាស្រ័យទាក់ទងជាមួយមេធាវីរបស់ជនស្ថិតនៅក្រោមការឃុំខ្លួន ឬជាប់ពន្ធនាគារមិនអាចបដិសេធឱ្យលើសពីពីរបីថ្ងៃបានឡើយ។[14]

---

[12] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយ, ទំព័រ ៧៨-៧៩។

[13] មហាសន្និបាតអង្គការសហប្រជាជាតិ " អង្គភាពទទួលបន្ទុកគោលការណ៍សម្រាប់ការការពារជនគ្រប់រូបដែលកំពុងស្ថិតនៅក្រោមការ ឃុំខ្លួន ឬជាប់ពន្ធនាគារ" សេចក្តីសម្រេចលេខ ៤៣/១៧៣ (ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៨៨) គោលការណ៍ ១៨ https://www.ohchr.org/sites/default/files/Documents/ProfessionalInterest/bodyprinciples.pdf។

[14] ដូចខាងលើ គោលការណ៍១៥។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិទទួលបានមធ្យោបាយ និងពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ធានាថាបុគ្គលដែលរងការចោទប្រកាន់មានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការការពារខ្លួនបានសមរម្យ។

☐ក. ត្រូវ ☐ខ. ខុស

២. សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី គឺត្រូវអនុវត្តគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ។

☐ក. ខុស ☐ខ. ត្រូវ

៣. តើសកម្មភាពណាខ្លះ ដែលបង្ហាញថាសិទ្ធិទទួលបានមធ្យោបាយ និងពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួនត្រូវបានរំលោភបំពាន?

☐ក. នៅថ្ងៃសវនាការ ចៅក្រមបានចាត់តាំងមេធាវីឱ្យការពារសិទ្ធិដល់ជនជាប់ចោទ

☐ខ. នៅថ្ងៃសវនាការ មេធាវីរបស់ជនជាប់ចោទបានលើកឡើងថា ខ្លួនមិនទាន់មានពេលគ្រប់គ្រាន់ដើម្បីការពារកូនក្តីខ្លួន និងស្នើទៅតុលាការដើម្បីពន្យារពេលមួយរយៈ ប៉ុន្តែតុលាការបដិសេធ។

☐គ. នៅថ្ងៃសវនាការ ជនជាប់ចោទមិនមានមេធាវីការពារ

☐ឃ. ខ និង គ

☐ង. ក និង គ

៤. តើសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់អនុញ្ញាតឱ្យជនជាប់ចោទអាចទទួលបានឯកសារ និងភស្តុតាងដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿងរបស់ពួកគេបានដែរឬទេ?

☐ក. បាទ/ចាស ☐ខ. មិនបានទេ

៥. ជនដែលរងការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌមានសិទ្ធិនិយាយជាមួយមេធាវីភ្លាមៗដើម្បីរៀបចំការពារក្តី ហើយកិច្ចសន្ទនារវាងមេធាវី និងកូនក្តី ត្រូវតែធ្វើជាសម្ងាត់។

☐ក. ខុស ☐ខ. ត្រូវ

៦. សិទ្ធិមានមធ្យោបាយ និងពេលវេលាគ្រប់គ្រាន់សម្រាប់ការពារក្តី និងសិទ្ធិនិយាយជាមួយមេធាវីមានសារៈសំខាន់ក្នុងការអនុវត្តចំពោះ៖

☐ក. គោលការណ៍នីត្យានុកូលភាព

☐ខ. គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់

☐គ.គោលការណ៍បែងចែកអំណាចដាច់ពីគ្នា

☐ឃ. មិនមែនទាំងអស់

៧. សិទ្ធិនិយាយជាមួយមេធាវីជាសិទ្ធិដាច់ខាត មានន័យថាមិនអាចជាកម្មវត្ថុនៃការលើកលែងបានទេ។

☐ក. ខុស ☐ខ. ត្រូវ

# សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬសិទ្ធិមានមេធាវី និងសិទ្ធិមានវត្តមាននៅពេលសវនាការ



# មាតិកា


I. សិទ្ធិមានមេធាវី ....................................................................................................46
១ .និយមន័យ ..........................................................................................................46
២ .ក្របខ័ណ្ឌច្បាប់ .....................................................................................................47
  ២ .១.ច្បាប់អន្តរជាតិ ...............................................................................................47
  ២.២. ច្បាប់ជាតិ.......................................................................................................48
៣.សារៈសំខាន់ ..........................................................................................................49
៤ . ដែនកំណត់ ..........................................................................................................49
II. សិទ្ធិមានវត្តមាននៅពេលសវនាការ.......................................................................51
១.និយមន័យ...............................................................................................................51
២.ក្របខ័ណ្ឌច្បាប់ .......................................................................................................52
  ២.១.ច្បាប់អន្តរជាតិ. ..............................................................................................52
  ២.២.ច្បាប់ជាតិ.........................................................................................................52
៣.សារៈសំខាន់...........................................................................................................53
៤.ដែនកំណត់ .............................................................................................................53
៥.សំណួរ ...................................................................................................................56

## I. សិទ្ធិមានមេធាវី

### ១. និយមន័យ



ជនជាប់ចោទបទល្មើសព្រហ្មទណ្ឌទាំងអស់**មានសិទ្ធិការពារខ្លួនដោយខ្លួនឯងផ្ទាល់** ឬ **ទទួលបានការការពារពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន**។[1] ការការពារខ្លួនទាំងពីរប្រភេទនេះគឺមិនមែនផ្តាច់មុខនោះទេ មានន័យថា ជនជាប់ចោទដែលសម្រេចចិត្តសុំពឹងពាក់មេធាវីមានសិទ្ធិក្នុងការផ្តល់ការណែនាំជូនមេធាវីរបស់ខ្លួនអំពីការអនុវត្តសំណុំរឿងរបស់ខ្លួន នៅក្នុងដែនកំណត់នៃការទទួលខុសត្រូវវិជ្ជាជីវៈ និងឱ្យមេធាវីផ្តល់សក្ខីកម្មជំនួសខ្លួន។[2]

សិទ្ធិការពារខ្លួនដោយខ្លួនឯងផ្ទាល់ ចំពោះបុគ្គលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានន័យថា ពួកគេមាន **សិទ្ធិបដិសេធមិនទទួលជំនួយពីមេធាវី** ក្នុងវិសាលភាពជាក់លាក់ណាមួយ*(សូមមើលផ្នែកដែនកំណត់)*។ ដើម្បីមានលទ្ធភាពការពារខ្លួនឯងដោយផ្ទាល់ ឬមានមេធាវីក្នុងការរៀបចំការពារក្តីរបស់ពួកគេ ជនជាប់ចោទត្រូវតែ**អនុញ្ញាតឱ្យមានវត្តមាននៅក្នុងសវនាការ**។*(សូមមើលមេរៀនស្តីពីសិទ្ធិមានវត្តមាននៅពេល សវនាការសម្រាប់ព័ត៌មានលម្អិតបន្ថែម)*។

ដើម្បីឱ្យសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬការពារខ្លួនដោយមេធាវីឱ្យមានប្រសិទ្ធភាព បុគ្គលដែលត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌ ត្រូវតែ**ទទួលបានការជូនដំណឹង**អំពីសិទ្ធិនេះ[3] ឱ្យបានគ្រប់គ្រាន់ជាមុនសិន មុននឹងផ្តល់ឱ្យពួកគេនូវ**ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់**ដើម្បីរៀបចំការពារក្តីដោយខ្លួនឯង ឬមានមេធាវី។[4] *(សូមមើលមេរៀនអំពីសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីសម្រាប់ព័ត៌មានលម្អិតបន្ថែម)*។ ជនជាប់ចោទមានសិទ្ធិ**ពឹងពាក់មេធាវី** ប្រសិនបើពួកគេមិនចង់ការពារខ្លួនដោយខ្លួនឯង។ សិទ្ធិនេះ អនុវត្តនៅ**គ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ** ពោលគឺចាប់តាំងពីការស៊ើបអង្កេតបឋម រហូតដល់ការជំនុំជម្រះក្តី និងដំណាក់កាលប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់។ ជនជាប់ចោទមានសិទ្ធិ**ជ្រើសរើសអ្នកប្រឹក្សាផ្លូវ ច្បាប់**ដែលនឹងតំណាងឱ្យខ្លួន។ ចំណុចនេះមានសារៈសំខាន់ដើម្បីធានាបាននូវការជឿជាក់ និងទំនុកចិត្ត រវាងជនជាប់ចោទ និងមេធាវីរបស់ពួកគេ និងនាំឱ្យមាន**ការការពារក្តីប្រកបដោយប្រសិទ្ធភាព**។

---

[1] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៨ --មាត្រា១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ,(CPPR/C/GC/32, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ៣៧) , https://www.refworld.org/docid/478b2b2f2.html (គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់ទូទៅលេខ ៣២)។

[2] ដូចខាងលើ។

[3] ដូចខាងលើ។

[4] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ការបោះពុម្ពផ្សាយលើកទី២ (ឆ្នាំ ២០១៤) ទំព័រ ១៤៦ - ១៤៨, /https://www.amnesty.org/en/documents/pol30/002/2014/en (សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌)។

ប្រសិនបើជនជាប់ចោទមិនមានលទ្ធភាពពឹងពាក់មេធាវីទេ ជនជាប់ចោទនោះមានសិទ្ធិទទួលបានមេធាវីចាត់តាំងដោយឥតគិតថ្លៃនៅពេលដែល**ផលប្រយោជន៍យុត្តិធម៌**តម្រូវ។ ឧទាហរណ៍ ស្ថានទម្ងន់បទល្មើស និងអត្ថិភាពនៃការផ្លាស់ប្តូរគោលបំណងសម្រាប់ការជោគជ័យនៅដំណាក់កាលបណ្តឹងតវ៉ានៅតុលាការជាន់ខ្ពស់ គឺជាកត្តាសំខាន់ដែលត្រូវការពិចារណាសម្រាប់ការចាត់តាំង**អ្នកប្រឹក្សាច្បាប់ដោយឥតគិតថ្លៃ**។[5] កាតព្វកិច្ចក្នុងការផ្តល់**អ្នកប្រឹក្សាច្បាប់ដោយឥតគិតថ្លៃ**ដល់ជនជាប់ចោទដែលគ្មានលទ្ធភាព គឺជា**ទំនួលខុសត្រូវរបស់អាជ្ញាធររដ្ឋ**។ អាជ្ញាធររដ្ឋក៏ត្រូវតែធានាថា ការតំណាងដោយមេធាវីចាត់តាំង ត្រូវ**មានប្រសិទ្ធភាព**។ ចំណុចនេះមានន័យថា រដ្ឋអាចទទួលបន្ទុកចំពោះការប្រព្រឹត្តខុសឆ្គង ឬអសមត្ថភាពរបស់មេធាវីចាត់តាំង ប្រសិនបើតុលាការមើលឃើញយ៉ាងច្បាស់ថាឥរិយាបថរបស់មេធាវី គឺមិនត្រូវគ្នាជាមួយនឹងផលប្រយោជន៍យុត្តិធម៌ ឬប្រសិនបើអាជ្ញាធរពាក់ព័ន្ធ ឬតុលាការរារាំងមេធាវីចាត់តាំងមិនឱ្យបំពេញកិច្ចការរបស់ពួកគេឱ្យមានប្រសិទ្ធភាព។[6]



នៅពេលចាត់តាំងមេធាវី អាជ្ញាធររដ្ឋក៏ត្រូវតែផ្តល់អាទិភាពដល់មេធាវីដែលបានជ្រើសរើសដោយជនជាប់ចោទផងដែរ ជាពិសេសនៅក្នុងសំណុំរឿងប្រហារជីវិត ដើម្បីធានាបាននូវការផ្តល់ជំនួយគ្រប់គ្រាន់ និងមានប្រសិទ្ធភាព។[7]

## ២. ក្របខ័ណ្ឌច្បាប់

### ២.១. ច្បាប់អន្តរជាតិ

សិទ្ធិមានមេធាវីត្រូវបានការពារយ៉ាងច្បាស់លាស់ដោយ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")** ដែលដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងច្បាប់កម្ពុជា តាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

- **មាត្រា ១៤(៣)(ឃ) នៃ ក.អ.ស.ព.ន៖** *"ក្នុងការសម្រេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិ៖ ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន នឹងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវបានទទួលជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជនយុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះនិងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។"*



[5] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៨។

[6] ដូចខាងលើ។

[7] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "Daniel Pinto ទល់នឹងប្រទេសទ្រីនីដាត និងតូបាហ្គោ," ឯកសារផ្សព្វផ្សាយលេខ ២៣២/១៩៨៧, CCPR/C/៣៩/D/២៣២/១៩៨៧, (១៩៩០) http://hrlibrary.umn.edu/undocs/session39/232-1987.html ។

## ២.២.ច្បាប់ជាតិ

**រដ្ឋធម្មនុញ្ញកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន** ក៏ធានានូវសិទ្ធិមានមេធាវីផងដែរ។



- **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា៖** *"ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"*

- **មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ជនត្រូវចោទជាអនីតិជន នៅពេលដែលចូលបង្ហាញខ្លួនជាលើកទីមួយ ត្រូវតែមានមេធាវីអមជានិច្ច។ ប្រសិនបើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។"*
- **មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ជនជាប់ចោទត្រូវតែចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនបានដែរនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។"*
- **មាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ជំនួយពីមេធាវីត្រូវតែមានជាចំខាត ក្នុងករណីដូចតទៅ (i) ករណីបទឧក្រិដ្ឋ ឬ (ii) កាលណាជនជាប់ចោទជាអនីតិជន។"*



- **មាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន៖** *"អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [...] សិទ្ធិទទួលបានជំនួយពីមេធាវី [...]"*



- **មាត្រា ៥០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន៖** *"ជំនួយរបស់មេធាវីត្រូវតែមានជាចំខាតនៅក្នុងសវនាការ [...]"*

## ៣. សារៈសំខាន់

ទោះបីតាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈមេធាវីក៏ដោយ សិទ្ធិការពារខ្លួនមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធានាបាននូវ**ការជំនុំជម្រះដោយយុត្តិធម៌**។ ជនជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានអនុញ្ញាតឱ្យតទល់នឹងការចោទប្រកាន់មកលើខ្លួន។ សិទ្ធិមានមេធាវីគឺជាសសរស្តម្ភមួយដែលប្រកាន់ខ្ជាប់នូវ**សិទ្ធិស្មើភាពគ្នា** រវាងភាគីជនជាប់ចោទ និងអយ្យការ ដែលជាគោលការណ៍សំខាន់នៃការជំនុំជម្រះដោយយុត្តិធម៌។ មេធាវីតំណាងជួយឱ្យជនជាប់ចោទរៀបចំការពារក្តីបានល្អប្រសើរ និងមានប្រសិទ្ធភាពបំផុតដោយមានជំនួយពីបុគ្គលដែលមានជំនាញផ្នែកច្បាប់គ្រប់គ្រាន់ ដែលមានលទ្ធភាពពន្យល់បានគ្រប់គ្រាន់អំពីខ្លឹមសារច្បាប់នៃការចោទប្រកាន់ និងដើម្បីការពារផលប្រយោជន៍របស់ជនជាប់ចោទនៅក្នុងតុលាការ ក៏ដូចជាធានាថា ជនជាប់ចោទទាំងអស់មានលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់ស្មើគ្នា ហើយជំនួយផ្នែកច្បាប់នោះផ្តល់ជូនដោយមិនមានការរើសអើង។[8] ការបដិសេធសិទ្ធិជនជាប់ចោទក្នុងការការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមានមេធាវីតំណាងធ្វើឱ្យខូចខាតដល់គោលការណ៍ស្មើភាពគ្នា ភាពស្របច្បាប់នៃការជំនុំជម្រះ និងយុត្តិធម៌នៃសេចក្តីសម្រេច ហេតុដូច្នេះ វាអាចបង្កើនហានិភ័យនៃការកាត់ទោសខុស។

## ៤. ដែនកំណត់

ផ្អែកតាមសិទ្ធិការពារខ្លួនដោយខ្លួនឯង សិទ្ធិមានមេធាវីអាច**លះបង់**បាន ប្រសិនបើជនជាប់ចោទមានបំណងការពារក្តីដោយខ្លួនឯង។ ប៉ុន្តែការលះបង់សិទ្ធិនេះត្រូវតែធ្វើឡើងដោយ**ការមានសមត្ថភាពគ្រប់គ្រាន់ និងច្បាស់លាស់**។ ជាពិសេស ចំណុចនេះត្រូវធានាថា ជនជាប់ចោទណាមួយដែលសម្រេចចិត្តលះបង់សិទ្ធិមានមេធាវី បានយល់ដឹងអំពីផលវិបាកនៃការសម្រេចចិត្តបែបនេះ។ ជនជាប់ចោទក៏ត្រូវមានសិទ្ធិ**លុបចោលការលះបង់សិទ្ធិរបស់ខ្លួន** នៅអំឡុងពេលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌបានផងដែរ ប្រសិនបើពួកគេផ្លាស់ប្តូរចិត្ត។[9]



លើសពីនេះ សិទ្ធិការពារខ្លួនដោយខ្លួនឯងគឺ**មិនមែនជាសិទ្ធិដាច់ខាត**នោះទេ។ ជនជាប់ចោទអាចត្រូវបានចាត់តាំងមេធាវីដែលខុសពីបំណងរបស់ខ្លួន នៅពេលដែល**ផលប្រយោជន៍យុត្តិធម៌**តម្រូវ។ ឧទាហរណ៍ ក្នុងករណីៈ

- ប្រសិនបើជនជាប់ចោទទទួលរងការចោទប្រកាន់ធ្ងន់ធ្ងរ ហើយតុលាការសម្រេចថាជនជាប់ចោទមិនអាចបំពេញតួនាទីស្របតាមឧត្តមប្រយោជន៍របស់ខ្លួនបានទេ

[8] ម.ស.ម.ក "សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" ( ឆ្នាំ២០១២) ទំព័រ ១៥, file:///C:/Users/carol/Downloads/cchr-ftr-and-trial-monitoring-handbook-feb-eng2012-02-13%20(7).pdf ។

[9] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ការបោះពុម្ពផ្សាយលើកទី២ (ឆ្នាំ ២០១៤) ទំព័រ ៤៩-៥០, /https://www.amnesty.org/en/documents/pol30/002/2014/en ។

- ប្រសិនបើជនជាប់ចោទទទួលរងការចោទប្រកាន់ធ្ងន់ធ្ងរ ហើយតុលាការសម្រេចថាជនជាប់ចោទមិនអាចបំពេញតួនាទីស្របតាមឧត្តមប្រយោជន៍របស់ខ្លួនបានទេ
- ប្រសិនបើជនជាប់ចោទតែងតែរារាំង ឬរំខានដល់ដំណើរការនីតិវិធីជំនុំជម្រះ ឬ
- នៅពេលដែលមានការចាំបាច់ត្រូវការពារសាក្សីងាយរងគ្រោះពីសម្ពាធ ឬការបំភិតបំភ័យនៃការសាកសួរតទល់គ្នាដោយជនជាប់ចោទ។[10]

ច្បាប់ក្នុងប្រទេស**កម្ពុជា** ចែងអំពីសិទ្ធិមាន**មេធាវីតំណាងត្រូវមានជាដាច់ខាត**សម្រាប់ជនជាប់ចោទប្រសិនបើជនជាប់ចោទជាកុមារ និងការចោទប្រកាន់នោះគឺជា**បទឧក្រិដ្ឋ**។

ជារួមការរឹតត្បិតណាមួយទៅលើសិទ្ធិការពារខ្លួនដោយខ្លួនឯង ត្រូវតែមានកត្តា**សត្យានុម័ត និងគោលបំណងម៉ឺងម៉ាត់គ្រប់គ្រាន់** និងមិនឱ្យហួសពីអ្វីដែល**ចាំបាច់** ដើម្បីរក្សាផលប្រយោជន៍យុត្តិធម៌ឡើយ។ រដ្ឋត្រូវតែចៀសវាងការហាមឃាត់ដាច់ខាតទៅលើសិទ្ធិរបស់បុគ្គល ដែលទទួលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌក្នុងការការពារក្តីដោយខ្លួនឯងដោយមិនចាំបាច់ពឹងពាក់មេធាវី។[11]



ទោះបីជាសំខាន់ចំពោះជនជាប់ចោទក្នុងការជ្រើសរើសមេធាវីដែលពួកគេទុកចិត្តដើម្បីតំណាងយ៉ាងណាក្តី **សិទ្ធិក្នុងការជ្រើសរើស**នេះក៏មិនមែនជា**សិទ្ធិដាច់ខាត**ដែរ និងអាចត្រូវបានរឹតត្បិតដោយ**ហេតុផលសមស្រប និងសត្យានុម័ត** ជាពិសេសប្រសិនបើរដ្ឋជាអ្នកបង់ថ្លៃសេវាមេធាវីនោះតែម្តង។ គោលបំណងរបស់ជនជាប់ចោទត្រូវតែយកមកពិចារណាជានិច្ច ប៉ុន្តែនៅពេលខ្លះអាចនឹងលុបលើផលប្រយោជន៍យុត្តិធម៌។[12] ប៉ុន្តែការគោរពដល់ជម្រើសរបស់ជនជាប់ចោទក្នុងការជ្រើសរើសមេធាវី គឺមានសារៈសំខាន់ ជាពិសេសនៅក្នុង**រឿងក្តីប្រហារជីវិត** ដើម្បីជានានូវជំនួយផ្នែកច្បាប់ដែលមានប្រសិទ្ធភាព និងគ្រប់គ្រាន់។[13]

---

[10] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៧ ។

[11] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៧ ។

[12] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌ ការបោះពុម្ពផ្សាយលើកទី២ (ខែមេសា ឆ្នាំ២០១៤) ទំព័រ ១៥០, /https://www.amnesty.org/en/documents/pol30/002/2014/en ។

[13] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ការពិនិត្យមើលទៅលើសំណុំរឿងរបស់ "Daniel Pinto ទល់នឹង ប្រទេសទ្រីនីដាត និងតូបាហ្គោ", ឯកសារផ្សព្វផ្សាយលេខ ២៣២/១៩៨៧, CCPR/C/២៩/D/២៣២/១៩៨៧, (ថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩០), http://hrlibrary.umn.edu/undocs/session39/232-1987.html ។

## II. សិទ្ធិមានវត្តមាននៅពេលសវនាការ

### ១. និយមន័យ



**សិទ្ធិមានវត្តមាននៅពេលសវនាការ**មានន័យថា បុគ្គលណាមួយដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិមានវត្តមាននៅអំឡុងពេលសវនាការរបស់ខ្លួន។ សិទ្ធិមានវត្តមាននៅពេលសវនាការរបស់ខ្លួនអនុញ្ញាតឱ្យជនជាប់ចោទបាន **ដឹងឮអំពីការចោទប្រកាន់មកលើខ្លួនតទល់ទៅនឹងទឡ្ហីករណ៍របស់តំណាងអយ្យការ និងបង្ហាញភស្តុតាងការពារក្តី**។[14] សិទ្ធិនេះក៏ជួយឱ្យជនជាប់ចោទ**បានចូលរួមសវនាការ** ជាពិសេសតាមរយៈការឆ្លើយនៅសវនាការរបស់ខ្លួន ប្រសិនបើពួកគេមានបំណងឆ្លើយ ដោយមិនមានការបង្ខំឱ្យធ្វើដូច្នោះឡើយ។[15] ដូច្នេះសិទ្ធិនេះគឺជាផ្នែកដ៏សំខាន់មួយនៃសិទ្ធិការពារខ្លួនដោយខ្លួនឯងឬតាមរយៈមេធាវី[16] (សូមមើលមេរៀនស្តីពីសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬសិទ្ធិមានមេធាវីសម្រាប់ព័ត៌មានលម្អិតបន្ថែម) និងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ[17]*(សូមមើលមេរៀនស្តីពីសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈសម្រាប់ព័ត៌មានលម្អិត)*។

ដើម្បីធានាថាសិទ្ធិមានវត្តមាននៅពេលសវនាការត្រូវបានគោរព**អាជ្ញាធររដ្ឋ**ត្រូវទទួលខុសត្រូវចំពោះការជូនដំណឹងដល់ជនជាប់ចោទ និងមេធាវីរបស់ពួកគេតាមរយៈការជូនដំណឹងដល់ពួកគេអំពីពេលវេលាកាលបរិច្ឆេទ និងទីកន្លែងសវនាការជាមុន។[18] អាជ្ញាធររដ្ឋក៏ត្រូវចៀសវាងពីការរារាំងដោយខុសច្បាប់ ឬការដកជនជាប់ចោទចេញពីបញ្ជីវត្តមាននៅពេលសវនាការ។[19]

[14] ម.ស.ម.ក " របាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩- ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ " ខែវិច្ឆិកា ឆ្នាំ២០២១, https://cchrcambodia.org/admin/media/report/report/english/FTR-Annual-Report-English-2019- pdf.2020។

[15] OSCE "អត្ថបទច្បាប់ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (ឆ្នាំ២០១២) ទំព័រ ១៣៣, https://www.osce.org/files/f/documents/1/f/94214.pdf ។

[16] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ការបោះពុម្ពផ្សាយលើកទីពីរ (ឆ្នាំ២០១៤) ទំព័រ ១៥៧, /https://www.amnesty.org/en/documents/pol30/002/2014/en ។

[17] OSCE "អត្ថបទច្បាប់ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (ឆ្នាំ២០១២) ទំព័រ ១៣៣, https://www.osce.org/files/f/documents/1/f/94214.pdf ។

[18] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ ៣២, CPPR/C/GC/៣២, ថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៦, https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CCPR2FC%2FGC%2F32&Lang=en% ។

[19] ម.ស.ម.ក "សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" ទំព័រទី២១។

ចំពោះកុមារដែលទំនាស់នឹងច្បាប់វិញ សិទ្ធិមានវត្តមាននៅពេលសវនាការទាមទារឱ្យមានវត្តមានរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់ពួកគេ លើកលែងតែវត្តមានរបស់បុគ្គលទាំងនោះត្រូវបានចាត់ទុកថាមិនផ្តល់ឧត្តមប្រយោជន៍ដល់ជនជាប់ចោទ។[20]

## ២. ក្របខ័ណ្ឌច្បាប់

### ២.១. ច្បាប់អន្តរជាតិ

សិទ្ធិមានវត្តមាននៅពេលសវនាការ គឺត្រូវបានការពារយ៉ាងច្បាស់ដោយ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** (**"ក.អ.ស.ព.ន"**) ដែលបញ្ចូលដោយផ្ទាល់ទៅក្នុងច្បាប់កម្ពុជា តាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។



**មាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖** *"ក្នុងការសម្រេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិ៖ ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន..."*

### ២.២. ច្បាប់ជាតិ

**ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ")** និង**ច្បាប់ស្តីពីយុត្តិធម៌អនីតិជន**ក៏ធានានូវសិទ្ធិមានវត្តមាននៅពេលសវនាការផងដែរ។ ក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ញត្តិដើម្បីសម្របសម្រួលដល់វត្តមានរបស់ជនជាប់ចោទនៅពេលសវនាការរបស់ខ្លួនផងដែរ។

- **មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ជនជាប់ចោទត្រូវតែចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនបានដែរនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។"*
- ក្រមនីតិវិធីព្រហ្មទណ្ឌ ក៏មានបញ្ញត្តិជាច្រើនផងដែរក្នុងការសម្របសម្រួលវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការរបស់ខ្លួន ដូចជា **មាត្រា ៣៨៨** ស្តីពីកាតព្វកិច្ចរបស់មហាអយ្យការក្នុងការកោះហៅជនជាប់ចោទឱ្យចូលមកក្នុងសវនាការ **មាត្រា ៣៨៩** ស្តីពីកាតព្វកិច្ចក្នុងការផ្ទេរជនជាប់ចោទដែលជាប់ឃុំទៅកាន់ពន្ធនាគារឬមណ្ឌលឃុំខ្លួនដែលនៅជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍ ឬ **មាត្រា ៤៥៧ និងមាត្រា ៤៦៦** ស្តីពីរយៈពេលដែលតុលាការត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងដីកាកោះហៅឱ្យចូលបង្ហាញខ្លួន និងកាលបរិច្ឆេទចូលបង្ហាញខ្លួន។

[20] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ ៣២, កថាខណ្ឌ ៤២។

- **មាត្រា៣៦៥**នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏មានចែងអំពីលទ្ធភាពសម្រាប់ពិរុទ្ធជនក្នុងការធ្វើបណ្តឹងទាស់នឹងសាលក្រមដែលប្រកាសដោយកំបាំងមុខខ្លួនបាន។ **មាត្រា ៣៦២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់និយមន័យសាលក្រមកំបាំងមុខថាជា សាលក្រមដែលចេញដោយមិនមានវត្តមានរបស់ជនជាប់ចោទ ប្រសិនបើជនជាប់ចោទមិនបានចូលបង្ហាញខ្លួន ដោយសារតែមិនបានដឹងអំពីសវនាការរបស់ខ្លួន។





- **មាត្រា ៥១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន៖** *"នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បានអំពីសិទ្ធិដូចខាងក្រោម៖ [...] សិទ្ធិមានវត្តមាននៅពេលសវនាការ [...]"*

## ៣. សារៈសំខាន់

សិទ្ធិមានវត្តមាននៅពេលសវនាការ និងនៅពេលជំនុំជម្រះ គឺជា**សមាសធាតុដ៏សំខាន់មួយនៃសិទ្ធិការពារខ្លួនដោយខ្លួនឯងផ្ទាល់ និងតាមរយៈមេធាវី** ហើយហេតុដូច្នេះ សិទ្ធិនេះមានសារៈសំខាន់ណាស់ក្នុងការធានានូវការជំនុំជម្រះដោយយុត្តិធម៌។ វត្តមានរបស់ជនជាប់ចោទអនុញ្ញាតឱ្យជនជាប់ចោទអាចដឹងឮ និងតទល់ភស្តុតាងចោទប្រកាន់មកលើខ្លួន និងបង្ហាញភស្តុតាងការពារក្តីតាមរយៈការកោះហៅសាក្សី និងការផ្តល់សក្ខីកម្មដោយខ្លួនឯងនៅពេលសវនាការរបស់ខ្លួន ប្រសិនបើខ្លួនមានបំណងដូច្នោះ។

ដូច្នេះ ការបើកសវនាការកំបាំងមុខជនជាប់ចោទ ធ្វើឱ្យខូចខាតដល់សិទ្ធិជាមូលដ្ឋានរបស់ពួកគេក្នុងការការពារខ្លួន និងជំរុញឱ្យមានការជំនុំជម្រះដោយមិនស្របច្បាប់។

## ៤. ដែនកំណត់

សិទ្ធិមានវត្តមាននៅពេលសវនាការ **គឺមិនមែនជាសិទ្ធិដាច់ខាត**នោះទេ។ សវនាការកំបាំងមុខជនជាប់ចោទគឺត្រូវបានអនុញ្ញាតឱ្យធ្វើឡើងនៅក្នុងកាលៈទេសៈមួយចំនួន ប្រសិនបើសវនាការនេះផ្តល់ផលប្រយោជន៍ដល់ការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ។ នៅក្នុងករណីដែលស្ថិតក្រោមលក្ខខណ្ឌខាងក្រោមនេះ សិទ្ធិមានវត្តមាននៅពេលសវនាការត្រូវបានបដិប្បញ្ញត្តិ ឬរឹតត្បិតជាបណ្តោះអាសន្ន៖

- ប្រសិនបើជនជាប់ចោទជ្រើសរើសលះបង់សិទ្ធិមានវត្តមានរបស់ខ្លួន។[21] ការលះបង់សិទ្ធិនេះត្រូវតែធ្វើឡើងដោយជាក់ច្បាស់ ជាលាយលក្ខណ៍អក្សរ និងដោយមានការការពារគ្រប់គ្រាន់។[22]

---

[21]គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ ៣២ កថាខណ្ឌ ៣៦។

[22] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ទំព័រ ១៥៧។

- ប្រសិនបើជនជាប់ចោទរំខានដល់ដំណើរការនីតិវិធីតុលាការ ដែលត្រូវបានចាត់ទុកថាមិនអាចបន្តដំណើរការនីតិវិធីបានដោយមានវត្តមានរបស់ជនជាប់ចោទ។ នៅក្នុងករណីនេះ តុលាការគឺត្រូវបានអនុញ្ញាតឱ្យដកជនជាប់ចោទចេញពីបន្ទប់សវនាការជាបណ្ដោះអាសន្នបាន។ ប៉ុន្តែ វិធានការចាំបាច់ទាំងអស់ក្នុងការធានានូវការការពារសិទ្ធិការពារខ្លួន ជាពិសេសតាមរយៈការរក្សាវត្តមានមេធាវីរបស់ជនជាប់ចោទនៅសវនាការ ធ្វើដូច្នេះទើបមេធាវីអាចបន្តការការពារក្ដីរបស់កូនក្ដីខ្លួនបាន[23] ឬ



- ប្រសិនបើមិនអាចរកអាសយដ្ឋានរបស់ជនជាប់ចោទឃើញ ឬជនជាប់ចោទបដិសេធក្នុងការចូលខ្លួនក្នុងសវនាការ ក្រោយពីបានជូនដំណឹងគ្រប់គ្រាន់ហើយក៏ដោយ។[24]



នៅក្នុងកាលៈទេសៈដែលជនជាប់ចោទលះបង់សិទ្ធិរបស់ខ្លួន ឬមិនអាចចូលសវនាការបាន ទោះបីជាមានការជូនដំណឹងគ្រប់គ្រាន់រួចហើយក៏ដោយ សវនាការអាចធ្វើឡើងដោយ***កំបាំងមុខ*** មានន័យថាធ្វើឡើងដោយ**មិនមានវត្តមានរបស់ជនជាប់ចោទ**។ ចំពោះសវនាការ*កំបាំងមុខ* តុលាការត្រូវតែដំណើរការដោយមានការប្រុងប្រយ័ត្នបន្ថែមទៀត ធ្វើយ៉ាងណាឱ្យ សវនាការនោះចាត់ទុកថាមានយុត្តិធម៌នៅក្រោមច្បាប់អន្តរជាតិ។ តុលាការត្រូវពិចារណាមើលថាតើអ្វីជាស្ថានភាពដែលបង្ហាញថាជនជាប់ចោទអវត្តមានពីការចូលខ្លួនមកក្នុងសវនាការ។ តុលាការមានទំនួលខុសត្រូវក្នុងការបញ្ជាក់ពីភស្តុតាងអំពីករណីនេះ ហើយករណីនេះគឺមិនមែនជាបន្ទុកដែលត្រូវទម្លាក់ទៅលើជនជាប់ចោទនោះទេ។ តុលាការគួរតែបញ្ជាក់អំពីករណីទាំងនេះនៅមុនពេលចាប់ផ្ដើមសវនាការ។[25]

ដើម្បីឱ្យសវនាការ*កំបាំងមុខ* ចាត់ទុកថាមានយុត្តិធម៌នៅក្រោមច្បាប់អន្តរជាតិ តុលាការត្រូវតែធានាថា៖[26]

- បញ្ញត្តិចាំបាច់ទាំងអស់គឺត្រូវបានអនុវត្តដើម្បីជូនដំណឹងដល់ជនជាប់ចោទអំពីការចោទប្រកាន់ និងដំណើរការនីតិវិធីដែលនឹងត្រូវធ្វើឡើង។
- បញ្ញត្តិចាំបាច់ទាំងអស់គឺត្រូវបានអនុវត្តដើម្បីធានាថា ជនជាប់ចោទទទួលបានការជូនដំណឹងក្នុងពេលវេលាគ្រប់គ្រាន់អំពីទីកន្លែង និងកាលបរិច្ឆេទនៃសវនាការរបស់ពួកគេ ព្រមទាំងសំណើឱ្យមានវត្តមានរបស់ខ្លួនផងដែរ។

---

[23] ដូចខាងលើ។

[24] ម.ស.ម.ក "សៀវភៅណែនាំស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" ទំព័រ ២១។

[25] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ទំព័រ ១៥៨ ។

[26] ម.ស.ម.ក "សៀវភៅណែនាំស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រ ២១, https://sithi.org/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook ។

- បញ្ញត្តិចាំបាច់ទាំងអស់គឺត្រូវបានអនុវត្ត ដើម្បីធានានូវការការពារសិទ្ធិការពារខ្លួននៅសវនាការរបស់ជនជាប់ចោទ ជាពិសេសធានាថា ជនជាប់ចោទត្រូវបានតំណាងដោយមេធាវី ទោះបីជាខ្លួន អវត្តមានក៏ដោយ។
- ធានាថា ជនជាប់ចោទដែលត្រូវបានផ្តន្ទាទោសដោយកំបាំងមុខ មានលទ្ធភាពទទួលបានសិទ្ធិប្តឹងតវ៉ា រួមទាំងការជំនុំជម្រះសារឡើងវិញអំពីសំណុំរឿងរបស់ខ្លួនដោយមានវត្តមានរបស់ពួកគេ។

នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីបណ្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ សិទ្ធិមានវត្តមាននៅពេលសវនាការរបស់ជនជាប់ចោទអាស្រ័យលើលក្ខណៈនៃបណ្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ស្របតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECHR")។ ឧទាហរណ៍ ប្រសិនបើសវនាការលើបណ្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ពិចារណាទៅលើអង្គច្បាប់ និងអង្គហេតុ ចាំបាច់ត្រូវមានវត្តមានរបស់ជនជាប់ចោទ និងមេធាវីរបស់ពួកគេ។ ប្រសិនបើសាលាឧទ្ធរណ៍ពិចារណាទៅលើតែបញ្ហាច្បាប់តែម្យ៉ាង នោះជនជាប់ចោទមិនចាំបាច់មានសិទ្ធិមានវត្តមាននោះទេ។ ប៉ុន្តែ ប្រសិនបើតំណាងអយ្យការមានវត្តមាន ហើយជជែកលើបញ្ហាច្បាប់ នោះយ៉ាងហោចណាស់ក៏ចាំបាច់ត្រូវមានវត្តមានមេធាវីការពារក្តីដែរ ធ្វើយ៉ាងនេះដើម្បីការពារគោលការណ៍ស្មើភាពគ្នា។ តុលាការសិទ្ធិមនុស្សអឺរ៉ុប ត្រូវពិចារណាទៅលើកត្តាផ្សេងៗជាច្រើនផងដែរក្នុងការសម្រេចថាតើវត្តមានរបស់ជនជាប់ចោទគឺចាំបាច់ដែរឬទេនៅដំណាក់កាលបណ្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ ឧទាហរណ៍រួមទាំងថាតើមានការជំនុំជម្រះជាសាធារណៈដែរឬទេនៅអំឡុងពេលសវនាការ ថាតើជនជាប់ចោទបានទទួលការជូនដំណឹងអំពីសវនាការលើបណ្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ និងស្នើសុំឱ្យមានវត្តមានដែរឬទេ ឬថាតើសេរីភាពរបស់ជនជាប់ចោទប្រឈមនឹងហានិភ័យដែរឬទេ។[27]

[27] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ទំព័រ ១៥៨ - ១៥៩។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិមានវត្តមាននៅពេលសវនាការ សំដៅដល់ជនរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិមានវត្តមានអំឡុងពេលជំនុំជម្រះទាំងមូល។

☐ក. ត្រូវ ☐ខ. ខុស

២. តើតុលាការអាចលើកពេលសវនាការបានដែរឬទេ នៅពេលជនជាប់ចោទអវត្តមាន?

☐ក. បាន ☐ខ. មិនបាន

៣. តើច្បាប់អន្តរជាតិណាមួយដែលមានចែងការពារសិទ្ធិមានវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ?

☐ក. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

☐ខ. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

☐គ. អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទារុណកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

៤. សិទ្ធិការពារខ្លួនឯងផ្ទាល់ ឬតាមរយៈមេធាវី សំដៅដល់សិទ្ធិរបស់ជនរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិការពារខ្លួនឯងផ្ទាល់ ឬការពារខ្លួនដោយមេធាវីជាជម្រើសរបស់ពួកគេ។

☐ក. ត្រូវ ☐ខ. ខុស

៥. យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ តើប្រភេទបទល្មើសណាដែលជនរងការចោទប្រកាន់ជានីតិជនត្រូវតែមានមេធាវីការពារក្នុងពេលជំនុំជម្រះ?

☐ក. បទលហុ, មជ្ឈិម និងឧក្រិដ្ឋ ☐ខ. បទឧក្រិដ្ឋ និងលហុ

☐គ. បទមជ្ឈិម និងឧក្រិដ្ឋ ☐ឃ. បទឧក្រិដ្ឋ

៦. យោងតាមច្បាប់យុត្តិធម៌អនីតិជន តើកុមារដែលរងការចោទប្រកាន់រឿងព្រហ្មទណ្ឌចាំបាច់ត្រូវមានជំនួយពីមេធាវីនៅដំណាក់កាលណាខ្លះក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ?

☐ក. ដំណាក់កាលជំនុំជម្រះ ☐ខ. គ្រប់ដំណាក់កាលទាំងអស់

៧. តើគោលការណ៍មូលដ្ឋានអ្វី ដែលអាចធានាសិទ្ធិមានមេធាវី?

☐ក. គោលការណ៍បែងចែកអំណាចដាច់ពីគ្នា

☐ខ. គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់រវាងជនរងការចោទប្រកាន់ និងព្រះរាជអាជ្ញា

☐គ. គោលការណ៍សន្មតជាមុនថាគ្មានទោស

☐ឃ. គោលការណ៍នីត្យានុកូល

# សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង









# មាតិកា


១. និយមន័យ ........................................ 57

២. ក្របខ័ណ្ឌច្បាប់ ........................................ 58

២.១. ច្បាប់អន្តរជាតិ ........................................ 58

២.២. ច្បាប់ជាតិ ........................................ 59

៣. សារៈសំខាន់ ........................................ 61

៤.ដែនកំណត់ ........................................ 62

៥. សំណួរ ........................................ 63

## ១.និយមន័យ



ក្នុងបរិបទនៃបទល្មើសព្រហ្មទណ្ឌ[1]ជនណាដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះលើសំណុំរឿងរបស់ខ្លួនដោយ**សាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងដែលបង្កើតឡើងដោយច្បាប់។**[2]



**សាលាជម្រះក្តី** មានន័យថា*ស្ថាប័នមួយដែលបង្កើតឡើងដោយច្បាប់ ឯករាជ្យពីអង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ឬមានឯករាជ្យភាពខាងយុត្តាធិការលើរឿងក្តីជាក់លាក់នានាក្នុងការសម្រេចសេចក្តីលើបញ្ហាច្បាប់នៅក្នុងដំណើរការនៃរឿងក្តីដែលមានចរិកលក្ខណៈជាការវិនិច្ឆ័យ។*[3]

សាលាជម្រះក្តីត្រូវតែ**បង្កើតឡើងដោយច្បាប់**ដើម្បីអាចជម្រះក្តីនានាផ្អែក តាមរដ្ឋធម្មនុញ្ញ ឬច្បាប់ផ្សេងៗដែលបានអនុម័តដោយអ្នកបង្កើតច្បាប់។[4]

លើសពីនេះ សាលាជម្រះក្តីត្រូវតែបំពេញតាម**លក្ខខណ្ឌតម្រូវចំនួនបីខាងក្រោម** ដើម្បីអាចមានសិទ្ធិជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌ៖

- **សាលាជម្រះក្តីត្រូវតែមានសមត្ថកិច្ច។** សាលាជម្រះក្តីមានសមត្ថកិច្ចគឺជាសាលាជម្រះក្តីដែល**មានដែនយុត្តាធិការក្នុងការជម្រះក្តី** មានន័យថា សាលាជម្រះក្តី**ទទួលសិទ្ធិអំណាច**ក្នុងការធ្វើសេចក្តីសម្រេចទៅលើកម្មវត្ថុដែលបានកំណត់**ដោយច្បាប់**។[5] ប្រសិនបើកម្មវត្ថុនោះមិនស្ថិតនៅក្រោមដែនយុត្តាធិការនៃសាលាជម្រះក្តីដែលមានស្រាប់នោះទេ រដ្ឋត្រូវតែបង្កើតសាលាជម្រះក្តីមានសមត្ថកិច្ច ឬពង្រីកដែនយុត្តាធិការនៃសាលាជម្រះក្តីដែលមានស្រាប់ដើម្បីអាចការពារសិទ្ធិរបស់បុគ្គលក្នុងការទទួលបានការជម្រះក្តីនៅសាលាជម្រះក្តី។[6] សាលាជម្រះក្តីត្រូវតែអាចមានសមត្ថភាព**ធ្វើសេចក្តីសម្រេចរួម** ដែលមិនអាចកែប្រែបានដោយអាជ្ញាធរមិនមែនតុលាការ។[7] ជាចុងក្រោយ សាលាជម្រះក្តីត្រូវតែ**មានមន្ត្រីដែលជាបុគ្គលមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់**។[8] ដើម្បីធានាថាមន្ត្រីទទួលបន្ទុកស្វែងរកយុត្តិធម៌ត្រូវមានសមត្ថភាព គឺត្រូវតែមាននីតិវិធីត្រឹមត្រូវពាក់ព័ន្ធនឹងការវិនិច្ឆ័យលើលក្ខណៈសម្បត្តិ ការតែងតាំង ការជ្រើសរើស ការដំឡើងតំណែង និងការចូល

---

[1] សូមមើល គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ --មាត្រា១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ,(CPPR/C/GC/32, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ទំព័រទី ៥៧ (CPPR/C/GC/32, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧), កថាខណ្ឌ១៦,សម្រាប់ព័ត៌មានលម្អិត https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CCPR%2FC%2FGC%2F32&Lang=en ) គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២) ។

[2] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ១៥។

[3] ដូចខាងលើ កថាខណ្ឌ ១៨។

[4] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ការបោះពុម្ពផ្សាយលើកទី ២ (ឆ្នាំ ២០១៤) ទំព័រ ១០៩, https://www.amnesty.org/en/documents/pol30/002/2014/en/ ។

[5] ដូចខាងលើ ទំព័រ ១១០។

[6] OSCE, "អត្ថបទច្បាប់ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (ឆ្នាំ២០១២) ទំព័រ ៥៧ , https://www.osce.org/files/f/documents/1/f/94214.pdf (OSCE, អត្ថបទច្បាប់ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌)។

[7] ដូចខាងលើ ទំព័រ ៥៧។

[8] ដូចខាងលើ ទំព័រ ៥៦។

និវត្តន៍នៃមន្ត្រីទាំងនោះ។ **ការអប់រំផ្នែកច្បាប់សម្រាប់មន្ត្រីតុលាការ** ក៏ត្រូវតែជានាបាននូវការអប់រំជាបន្តបន្ទាប់ផងដែរ៖ ដើម្បីរក្សាសមត្ថភាពរបស់មន្ត្រីទាំងនោះ។

- **សាលាជម្រះក្ដីត្រូវតែឯករាជ្យ។** ចំណុចនេះមានន័យថា អំណាចតុលាការត្រូវតែទទួលបាន**ការការពារ ការជៀតជៀកផ្នែកនយោបាយពីអង្គនីតិប្រតិបត្តិ ឬអង្គនីតិបញ្ញត្តិ** នៅក្នុងដំណើរការនីតិវិធី និងការធ្វើសេចក្ដីសម្រេចរបស់តុលាការ។ ការការពារនេះត្រូវតែធានាតាមរយៈរដ្ឋធម្មនុញ្ញ ឬការអនុម័តច្បាប់**ដែលបង្កើតនីតិវិធីច្បាស់លាស់ និងលក្ខណៈវិនិច្ឆ័យដោយសត្យានុម័ត** សម្រាប់**ការតែងតាំង ប្រាក់បំណាច់ ការដំឡើងតំណែង ការព្យួរការងារ** និង**ការបញ្ឈប់មន្ត្រីតុលាការ** ព្រមទាំង**ការដាក់ទណ្ឌកម្មវិន័យ** ទៅលើមន្ត្រីតុលាការផងដែរ។[10] មុខងារ និងសមត្ថកិច្ចនៃអំណាចតុលាការត្រូវតែបែងចែកឱ្យដាច់ពីមុខងារ និងសមត្ថកិច្ចរបស់អង្គនីតិប្រតិបត្តិ និងអង្គនីតិបញ្ញត្តិ ហើយមន្ត្រីតុលាការត្រូវតែ**រួចផុតពីការគ្រប់គ្រង ឬការបញ្ជាពីសំណាក់អង្គនីតិប្រតិបត្តិ ឬអង្គនីតិបញ្ញត្តិ**។

ជាចុងក្រោយ ចៅក្រមក៏ត្រូវតែទទួលបានការ**ការពារពីទំនាស់ផលប្រយោជន៍ និងការគំរាមកំហែង** ហើយ**ស្ថានភាពផ្សេងៗទៀត** (ឧទាហរណ៍ អាណត្តិកាន់តំណែង ឯករាជ្យភាព សន្តិសុខ ប្រាក់បំណាច់ លក្ខខណ្ឌបម្រើការងារ សោធននិវត្តន៍ និងអាយុ ឬការចូលនិវត្តន៍) ត្រូវតែទទួលបានការ**ការពារគ្រប់គ្រាន់ដោយច្បាប់** ដើម្បីការពារឯករាជ្យភាពនៃចៅក្រម។

- **សាលាជម្រះក្ដីត្រូវតែមិនលម្អៀង។** លក្ខខណ្ឌតម្រូវនៃភាពមិនលម្អៀងមាន**ពីរ**គឺ **១.** ចៅក្រមដាច់ខាតមិនត្រូវ**ឱ្យការកាត់ក្ដីរបស់ខ្លួនបែរទៅរកភាពលម្អៀង ឬបុរេវិនិច្ឆ័យផ្ទាល់ខ្លួន ដែលបុរេវិនិច្ឆ័យ**ទៅលើសំណុំរឿងដែលខ្លួនជម្រះក្ដី ឬប្រព្រឹត្តតាមវិធីដែលផ្ដល់ផលប្រយោជន៍ដល់ភាគីម្ខាង ហើយធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ភាគីម្ខាងទៀត។ **២.** សាលាជម្រះក្ដីដាច់ខាតត្រូវតែ**បង្ហាញឱ្យឃើញអំពីភាពមិនលម្អៀងរបស់ខ្លួនឱ្យអ្នកដទៃបានមើល**ផងដែរ។[11]



# ២.ក្របខ័ណ្ឌច្បាប់

## ២.១. ច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងមានចែងនៅក្នុង**សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ("ស.ស.ស.ម")** និង**កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")** ដែលអនុវត្តដោយផ្ទាល់ទៅក្នុងច្បាប់របស់កម្ពុជាតាមរយៈមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

- **មាត្រា ១០ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស៖** *"មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យនិងមិនលម្អៀង ពិនិត្យរឿងក្ដីរបស់ខ្លួនជាសាធារណៈនិងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ ។"*



[9] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ទំព័រ ១០៨ ។

[10] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ១៩ ។

[11] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្ដីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ២១។

- មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ *"ជនគ្រប់រូប ត្រូវមានសិទ្ធិឱ្យសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែល បង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី"*



## ២.២. ច្បាប់ជាតិ

លក្ខខណ្ឌតម្រូវនៃសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងនៃសាលាជម្រះក្តីក៏មានចែងនៅក្នុង**រដ្ឋធម្មនុញ្ញកម្ពុជា** និងនៅក្នុងបញ្ញត្តិជាច្រើននៃ **ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ")** និង **ក្រមសីលធម៌ចៅក្រមកម្ពុជា**។



**មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញ៖** *"អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិអំណាចតុលាការជាអំណាចឯករាជ្យ សេរីភាពរបស់ប្រជាពលរដ្ឋ [...]។"*

**មាត្រា ១២៩ នៃរដ្ឋធម្មនុញ្ញ៖** *"[...] មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។"*

**មាត្រា ១៣០ និង ១៣១ នៃរដ្ឋធម្មនុញ្ញ៖** *"គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ។"* និង *"មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។"*

**មាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញ៖** *"ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។"*



**មាត្រា ៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"សមាជិកនៃសភាស៊ើបសួរពុំអាចចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដែលខ្លួនបានចាត់ការ ក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើមិនដូច្នេះទេ សាលដីកានោះត្រូវចាត់ទុកជាមោឃៈ។"*

**មាត្រា ២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ចៅក្រមណាដែលបានបំពេញមុខងារក្នុង ឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួររឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ។"*

**មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"តុលាការថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាដើម្បីសម្រេច។ គ្មានបណ្តឹងសុំណាមួយអាចត្រូវដាក់ ជូនតុលាការ បានទៀតទេ។ គ្មានទឡ្ហីករណ៍ណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានឡើយ។ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការពិភាក្សាសម្រេចនេះទេ។"*

**ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ៖** ច្បាប់នេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ដែលជាសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា និងកំណត់អំពីសមត្ថកិច្ចរបស់តុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ទៅតាមជំនាញ។

- **មាត្រា ១** នៃច្បាប់នេះចែងថា ច្បាប់នេះមានគោលបំណង *"ធានាឯករាជ្យនៃអំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ធានាឱ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការ និងអង្គការអយ្យការ លើកកម្ពស់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព និងឆាប់រហ័សធានាក្នុងការផ្តល់យុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម"*។
- **មាត្រា ៦** ក៏ចែងផងដែរថា មានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ *"ដោយឯករាជ្យ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន"*។

**ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម៖** ច្បាប់នេះបង្កើតឡើង និងកំណត់អំពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យនៃអំណាចតុលាការ ធានាវិន័យរបស់ចៅក្រម និងធានាការប្រព្រឹត្តទៅនៃសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជាឱ្យដំណើរការបានល្អប្រសើរ (មាត្រា ១)។ ច្បាប់នៃអនុវត្តចំពោះគ្រប់ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់នៅក្នុងប្រទេសកម្ពុជា (មាត្រា ២)។

**ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា៖** ច្បាប់នេះកំណត់ពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំងគោលការណ៍ផ្សេងៗទៀតទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញាក្នុងគោលបំណងធានាឯករាជ្យនៃអំណាចតុលាការ។

- ឧទាហរណ៍ **មាត្រា ៨** ចែងថា *"ចៅក្រមទាំងឡាយត្រូវសម្រេចសេចក្តីដោយមិនលម្អៀង ដោយឈរលើគោលការណ៍គោរពច្បាប់ដោយ មិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោល ពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ ។"*
- ស្រដៀងគ្នានេះដែរ **មាត្រា ៧៧** ចែងថា *"ព្រះរាជអាជ្ញាទាំងឡាយត្រូវអនុវត្តមុខងារ និងតួនាទីរបស់ខ្លួន ដោយឈរលើគោលការណ៍គោរព ច្បាប់ដោយមិនទទួល ការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬ ដោយប្រយោល ពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ។"*

**<u>សម្គាល់៖</u>** ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានអនុម័តនៅឆ្នាំ២០១៤ ក្នុងគោលបំណងធានានូវឯករាជ្យភាពនៃអំណាចតុលាការ។ ប៉ុន្តែ ច្បាប់ទាំងនេះត្រូវបានធ្វើសេចក្តីព្រាងដោយមិនមានការចែកផ្សាយ ឬពិគ្រោះយោបល់ជាមុនជាមួយនឹងសង្គមស៊ីវិល សាធារណជន ឬភាគីពាក់ព័ន្ធផ្សេងៗឡើយ ហើយ

ទទួលបានការរិះគន់ថាធ្វើឱ្យចុះខ្សោយដល់ការបែងចែកអំណាច និងឯករាជ្យភាពនៃអំណាចតុលាការ។ ច្បាប់ទាំងនេះផ្តល់ឱ្យអង្គនីតិប្រតិបត្តិនូវការគ្រប់គ្រងផ្ទាល់ទៅលើអំណាចតុលាការបានយ៉ាងមានប្រសិទ្ធភាព តាមរយៈការបង្កើនកម្រិតនៃឥទ្ធិពលរបស់ក្រសួងយុត្តិធម៌ទៅលើចៅក្រម និងព្រះរាជអាជ្ញាតាមរយៈការចូលរួមរបស់ក្រសួងនៅក្នុងការធ្វើដំណើរការថវិកា ក្នុងប្រព័ន្ធយុត្តិធម៌ការតែង តាំង ការដំឡើងតំណែងការកាន់កាប់មុខតំណែងការងារនិងការដកមន្ត្រីតុលាការចេញពីតំណង។ក្រសួងនៅក្នុងការធ្វើដំណើរការថវិកាក្នុងប្រព័ន្ធយុត្តិធម៌ការតែង តាំង ការដំឡើងតំណែងការកាន់កាប់មុខតំណែងការងារ និងការដកមន្ត្រីតុលាការចេញពីតំណែង។[12]

**ក្រមសីលធម៌ចៅក្រមកម្ពុជា៖** ក្រមសីលធម៌នេះបំពេញបន្ថែមទៅលើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។ បញ្ញត្តិនៃក្រមសីលធម៌នេះមានគោលបំណងពង្រឹងនូវឯករាជ្យភាព និងសេចក្តីថ្លៃថ្នូរបស់ចៅក្រមទាំងអស់ក្នុងការអនុវត្តកិច្ចការតុលាការ ឬអយ្យការ ក៏ដូចជាការប្រកាន់នូវឥរិយាបថរបស់ខ្លួននៅក្រៅតុលាការ ដើម្បីបង្កើននូវសេចក្តីទុកចិត្តពីសាធារណជនលើប្រព័ន្ធតុលាការ និងការពារកេរ្តិ៍ឈ្មោះចៅក្រម។

- ឧទាហរណ៍ **ប្រការ ២** ចែងថា *"ចៅក្រមត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យ ឈរលើមូលដ្ឋាននៃការវាយតម្លៃលើអង្គហេតុ និងផ្អែកលើចំណេះដឹងផ្នែកច្បាប់ ដោយមិនត្រូវទទួលរងនូវឥទ្ធិពលផ្សេងៗដូចជា ការអូសទាញ ការគៀបសង្កត់ ការគំរាមកំហែង ឬ ការជ្រៀតជ្រែកពីសំណាក់ជនណាម្នាក់ ឬច្រើននាក់ ឬ ហេតុផលអ្វីមួយ ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី។ ចៅក្រម ត្រូវច្រានចោលនូវការប៉ុនប៉ងទាំងឡាយណាដែលធ្វើអោយមានឥទ្ធិពលដល់ការវិនិច្ឆ័យសេចក្តីរបស់ខ្លួន។"*
- **ប្រការ ៧** ចែងថា *"ចៅក្រមត្រូវមានអាកប្បកិរិយា ទាំងក្នុង និង ក្រៅតុលាការនូវលក្ខណៈអនាគតិរបស់ខ្លួនដើម្បីការពារថែរក្សា និងលើកកម្ពស់ជំនឿទុកចិត្តពីសំណាក់សាធារណជន អ្នកមានវិជ្ជាជីវៈច្បាប់ និងភាគីវិវាទ។ ចៅក្រមមិនត្រូវចូលរួមពិភាក្សាជាសាធារណៈ ពាក់ព័ន្ធទៅនឹងបញ្ហាដែលអាចមាននៅតុលាការឡើយ ព្រោះវាអាចនាំឱ្យប៉ះពាល់ដល់ ជំនឿទុកចិត្តអំពីអនាគតិរបស់ចៅក្រម។ នៅក្នុងការសម្រេចសេចក្តីចៅក្រម មិនត្រូវធ្វើបុរេវិនិច្ឆ័យ ទាក់ទងទៅនឹង ជាតិសាសន៍ ពណ៌សម្បុរ ភេទ សាសនា និន្នាការនយោបាយ ពិការភាព អាយុ ស្ថានភាពគ្រួសារ ស្ថានភាពសេដ្ឋកិច្ច និងសង្គមឡើយ។ ម្ចាស់បណ្តឹងអាជ្ញា ត្រូវស្វែងរកភស្តុតាងដាក់បន្ទុក ដើម្បីធ្វើការចោទប្រកាន់ ប៉ុន្តែមិនត្រូវមានភាពលម្អៀងក្នុងការចោទប្រកាន់ឬមិនចោទប្រកាន់ឡើយ គឺត្រូវធានានូវភាពត្រឹមត្រូវ និងប្រសិទ្ធភាពក្នុងការធ្វើបណ្តឹងអាជ្ញា។"*

## ៣. សារៈសំខាន់



សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង គឺជា**សសរស្តម្ភនៃការជំនុំជម្រះដោយយុត្តិធម៌** និងមានសារៈសំខាន់ក្នុងការធានានូវ**ការគ្រប់គ្រងយុត្តិធម៌ត្រឹមត្រូវ** និង**នីតិរដ្ឋ**។

[12] សម្រាប់ព័ត៌មានបន្ថែម សូមមើល ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅប្រទេសកម្ពុជានៅ ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍៖ របាយការណ៍ប្រចាំឆ្នាំ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ – ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩" (ខែតុលា ឆ្នាំ២០២០) កំណត់សម្គាល់លេខ២២នៅទំព័រទី៣ https://www.cchrcambodia.org/admin/media/report/report/english/FTR%20Annual%20Report_ENG%20(2018-2019).pdf ។

លក្ខខណ្ឌតម្រូវនៃសមត្ថកិច្ច និងភាពមិនលម្អៀងធានាថា មន្ត្រីតុលាការដែលជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌមាន**ជំនាញផ្នែកច្បាប់ និងសុចរិតភាពគ្រប់គ្រាន់** ដើម្បីធ្វើសេចក្តីសម្រេចដោយសត្យានុម័ត និង អព្យាក្រឹតផ្អែកទាំងស្រុងតែលើភស្តុតាង និងស្របតាមច្បាប់ពាក់ព័ន្ធតែប៉ុណ្ណោះ។[13]

លក្ខខណ្ឌតម្រូវនៃឯករាជ្យភាពធានាថាសេចក្តីសម្រេចដែលចេញដោយតុលាការ គឺមិនទទួលរងឥទ្ធិពលពីមូលហេតុនយោបាយ ឬមូលហេតុផ្ទាល់ខ្លួន។ លក្ខខណ្ឌតម្រូវនេះគឺចាក់ឫសគល់នៅក្នុងគោលការណ៍នៃ**ការបែងចែកអំណាច។** ដោយមានសារៈសំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យ គោលការណ៍នេះធានានូវ**តុល្យភាពអំណាច** រវាងអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងតុលាការ ព្រមទាំងការពារអំណាចទាំងនោះមិនឱ្យមានការបំពានអំណាចគ្នាវិញទៅមក[14] ហេតុដូច្នេះជួយជំរុញឱ្យនីតិរដ្ឋមានភាពរីកចម្រើន។

ដូចនេះ ការមិនគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងរារាំងដល់ការគ្រប់គ្រងយុត្តិធម៌ត្រឹមត្រូវ ក៏ដូចជាការអនុវត្តនីតិរដ្ឋផងដែរ។

## ៤.ដែនកំណត់

សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងគឺជា**សិទ្ធិដាច់ខាត** ដែល**មិនអាចលើកលែងបានទេ**[15] ទាំងនៅក្នុងស្ថានភាពអាសន្នផងដែរ។[16] លក្ខខណ្ឌតម្រូវនៃសមត្ថកិច្ច ឯករាជ្យភាព និងភាពមិនលម្អៀងអនុវត្តបន្ថែមទៀតទៅលើតុលាការទាំងអស់ដែលស្ថិតនៅក្រោមនិយមន័យតុលាការ (សូមមើលផ្នែក ១) មិនថាជាតុលាការសាមញ្ញ ឬឯកទេស តុលាការស៊ីវិល ឬយោធាឡើយ។[17] លក្ខខណ្ឌទាំងនេះក៏អនុវត្តចំពោះតុលាការសាសនា ឬតុលាការដែលផ្អែកលើច្បាប់ប្រពៃណី និងត្រូវបានទទួលស្គាល់ដោយរដ្ឋ ព្រមទាំងទទួលបន្ទុកកិច្ចការផ្លូវច្បាប់។



[13] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ទំព័រ ១១៥ ។

[14] ដូចខាងលើ ទំព័រ ១១១។

[15] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ឯកសារទំនាក់ទំនងលេខ ២៦៣/១៩៨៧ M. Gonzalez del Rio v. Peru (CCPR/C/៤៦/D/២៦៣/១៩៨៧) ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩២ វាក្យខណ្ឌ ៥.២., https://juris.ohchr.org/Search/Details/332។

[16] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ២៩ កថាខណ្ឌ ១៦ https://www.un.org/ga/search/view_doc.asp?symbol=CCPR/C/21/Rev.1/Add.11។

[17] ដូចខាងលើ កថាខណ្ឌ ២២។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងសំដៅដល់៖

☐ក. ចៅក្រមមិនរងសម្ពាធពីអំណាចនីតិប្រតិបត្តិ ឬអំណាចនីតិបញ្ញត្តិ ទៅលើនីតិវិធី និងសម្រេចសេចក្ដី

☐ខ. ការជំនុំជម្រះដោយតុលាការដែលមិនមានទំនោរទៅខាងភាគីណាមួយ

☐គ. សាលាជម្រះក្ដីត្រូវមានយុត្តាធិការក្នុងការជំនុំជម្រះរឿងក្ដី ហើយមន្ត្រីតុលាការត្រូវមានគុណវុឌ្ឍិ និងបទពិសោធន៍គ្រប់គ្រាន់

☐ឃ. ក, ខ និងគ

២.តើលិខិតុបករណ៍អន្តរជាតិណាខ្លះដែលធានាថាបុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាក្នុងការទទួលបានការជំនុំជម្រះដោយតុលាការមួយដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង?

☐ក. សេចក្ដីប្រកាសជាសកលស្ដីសិទ្ធិមនុស្ស

☐ខ. កតិកាសញ្ញាអន្តរជាតិស្ដីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

☐គ. កតិកាសញ្ញាអន្តរជាតិស្ដីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

☐ឃ. ចម្លើយ ក និង គ

☐ង. ចម្លើយ ក និង ខ

៣. សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង មានសារៈសំខាន់ណាស់ ដោយសារសិទ្ធិនេះជាមូលដ្ឋាននៃការទទួលបានការជំនុំជម្រះមួយដែលយុត្តិធម៌ និងប្រាកដថាប្រព័ន្ធយុត្តិធម៌ត្រូវបានអនុវត្តដោយខ្ជាប់ខ្ជួន។

☐ក. ត្រូវ ☐ខ. ខុស

៤. តើសកម្មភាព/រូបភាពមួយណាខ្លះ ដែលបង្ហាញថាសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងមិនត្រូវបានគោរព?

☐ក. មេធាវីការពារជនជាប់ចោទ ជាមិត្តភក្ដិនឹងគ្នា

☐ខ. ចៅក្រមដែលជម្រះក្ដី ជាបងប្អូនរបស់ភាគីនៅក្នុងរឿងក្ដីនោះ

☐គ. ចៅក្រមដែលជម្រះក្ដីជាមិត្តភក្ដិជិតស្និតជាមួយនឹងភាគីក្នុងរឿងក្ដី

☐ឃ. ក និង ខ

☐ង. ខ និង គ

៥. សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ជាសិទ្ធិដាច់ខាត គឺមិនមានការលើកលែងទេ។

☐ក. ត្រូវ ☐ខ. ខុស

៦. ប្រសិនបើភាគីជនជាប់ចោទដឹងថា ជនរងគ្រោះជាមិត្តភក្ដិនឹងចៅក្រមជំនុំជម្រះ ជនជាប់ចោទអាច៖

☐ក. ប្ដឹងសុំផ្លាស់ប្ដូរចៅក្រមបាន

☐ខ.មិនអាចប្ដឹងផ្លាស់ប្ដូរចៅក្រមបានទេ ដោយសារចៅក្រមត្រូវបានចាត់តាំងដោយប្រធានតុលាការរួចហើយ

៧. ចៅក្រមជំនុំជម្រះធ្វើការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដោយសំអាងតែលើ៖

☐ក. ព័ត៌មានទទួលពីអង្គនីតិប្រតិបត្តិ

☐ខ. អង្គហេតុ និងភស្តុតាងដែលមានក្នុងសំណុំរឿងតែប៉ុណ្ណោះ

# សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ









# មាតិកា


១.និយមន័យ ........ 64
២ .ក្របខ័ណ្ឌច្បាប់ ........ 64
២.១ .ច្បាប់អន្តរជាតិ ........ 64
២.២ .ច្បាប់ជាតិ ........ 65
៣ .សារៈសំខាន់ ........ 65
៤. ដែនកំណត់ ........ 66
៥ .សំណួរ ........ 67

## ១. និយមន័យ



មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការកំណត់ថាមានពិរុទ្ធភាព ឬភាពគ្មានទោសនៅក្នុង**ការជំនុំជម្រះជាសាធារណៈ** លើកលែងតែក្នុងកាលៈទេសៈលើកលែងមួយចំនួន។ ចំណុចនេះ មានន័យថា ដំណើរការជំនុំជម្រះត្រូវតែធ្វើឡើងជាសាធារណៈ និងផ្ទាល់មាត់ស្របតាមគោលការណ៍ ដើម្បីធានាឱ្យបាននូវតម្លាភាពនៃដំណើរការកាត់ក្តី។[1]

សិទ្ធិទទួលបាន**ការជំនុំជម្រះជាសាធារណៈ** ត្រូវអនុវត្តនៅ**គ្រប់ដំណើរការជំនុំជម្រះរឿងព្រហ្មទណ្ឌទាំងអស់** ឬបញ្ហាពាក់ព័ន្ធនឹងបណ្តឹងផ្លូវច្បាប់។ ប៉ុន្តែ ចំណុចនេះមិនមានន័យថាត្រូវអនុវត្តទៅគ្រប់ដំណើរការបណ្តឹងឧទ្ធរណ៍ ឬសេចក្តីសម្រេចមុនពេលពេលជំនុំជម្រះដែលធ្វើឡើងដោយព្រះរាជអាជ្ញា និងអាជ្ញាធរសាធារណៈផ្សេងទៀតនោះទេ។[2]



ដើម្បីឱ្យមាន**ការគោរពសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ** ការជំនុំជម្រះត្រូវតែធ្វើឡើងដោយបើកចំហសម្រាប់សាធារណជន ដោយក្នុងនោះរួមមានទាំងអ្នកសារព័ត៌មានហើយត្រូវធ្វើឡើងដោយផ្ទាល់មាត់។ សាធារណជន ត្រូវតែទទួលបានការជូនដំណឹងអំពីទីកន្លែង និងកាលបរិច្ឆេទជំនុំជម្រះត្រូវផ្តល់ជូនមធ្យោបាយគ្រប់គ្រាន់ដើម្បីធានាថាអ្នកចូលរួមត្រូវមានចំនួនកំណត់មួយសមស្រប។[3]

នៅក្នុងកាលៈទេសៈលើកលែងមួយចំនួន ដែលសាធារណជនមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងដំណើរការជំនុំជម្រះ សាលក្រម ដែលរួមមានទាំងលទ្ធផលរកឃើញសំខាន់ៗ ភស្តុតាង និងមូលហេតុស្របច្បាប់ ត្រូវតែផ្សព្វផ្សាយជូនជាសាធារណៈ[4] លើកលែងតែករណីជាក់លាក់ប៉ុណ្ណោះ (សូមមើលផ្នែកដែនកំណត់) ដើម្បីរក្សា**សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ** របស់ជនជាប់ចោទ (*សម្រាប់ព័ត៌មានលម្អិត សូមមើលមេរៀនអំពីសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ*)។

## ២. ក្របខ័ណ្ឌច្បាប់



### ២.១. ច្បាប់អន្តរជាតិ

**សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ** ត្រូវបានការពារដោយ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")** ដែលត្រូវបានបញ្ចូលទៅក្នុងច្បាប់កម្ពុជាដោយផ្ទាល់តាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

---

[1] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២--មាត្រា១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ,(CPPR/C/GC/32, (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ២៨, https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CCPR%2FC%2FGC%2F32&Lang=en (គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២)។

[2] ដូចខាងលើ កថាខណ្ឌ ២៨។

[3] ដូចខាងលើ កថាខណ្ឌ ២៨។

[4] ដូចខាងលើ កថាខណ្ឌ ២៨ ។

- **មាត្រា ១៤ (១) នៃ ក.អ.ស.ព.ន៖** *"ជនគ្រប់រូបត្រូវទទួលបានការកាត់ក្តីដោយ "សមធម៌ និងជាសាធារណៈ" [...]។ សារព័ត៌មាន និងសាធារណជន អាចមិនឱ្យចូលរួមទាំងស្រុង ឬដោយផ្នែកនៃសវនាការសម្រាប់ផលប្រយោជន៍នៃទំនៀមទម្លាប់ល្អសណ្តាប់ធ្នាប់សាធារណៈ ឬ សន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ឬ នៅពេលផលប្រយោជន៍នៃ ជីវិតឯកជនរបស់គូភាគី តម្រូវឱ្យធ្វើដូច្នេះ ឬ នៅក្នុងកម្រិតដែលចាំបាច់បំផុត តាមការយល់ឃើញរបស់តុលាការក្នុងស្ថានភាពពិសេសដែលថាការធ្វើជាសាធារណៈនឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌ [...]។"*



## ២.២. ច្បាប់ជាតិ

**ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** (ក្រមនីតិវិធីព្រហ្មទណ្ឌ) និង**ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ** ក៏បានធានាសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈផងដែរ។



- **មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"សវនាការត្រូវតែធ្វើឡើងជាសាធារណៈ។"*
- **មាត្រា ៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ៖** *"សវនាការត្រូវតែធ្វើឡើងជាសាធារណៈ នៅគ្រប់ករណីទាំងអស់ តុលាការត្រូវប្រកាសសេចក្តីសម្រេចនៅក្នុងសាលសវនាការដែលបើកជាសាធារណៈ។"*

## ៣. សារៈសំខាន់



សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ គឺជាមូលដ្ឋានគ្រឹះក្នុងការធានានូវ**តម្លាភាព**នៃដំណើរការកាត់ក្តី និង**គណនេយ្យភាព**របស់អ្នកដែលផ្តល់យុត្តិធម៌។នេះគឺជាដំណើរការ**ការពារប្រយោជន៍ដ៏សំខាន់**សម្រាប់**បុគ្គលម្នាក់ៗ**ក៏ដូចជាសង្គមទាំងមូលតែម្តង។[5]

សម្រាប់ភាគីដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង រួមទាំងជនជាប់ចោទផងនោះ ការចូលរួមពិនិត្យពិច័យជាសាធារណៈអាចជួយ**ត្រួតពិនិត្យ**លើការធ្វើការសម្រេចចិត្តតាមអំពើចិត្ត ការបំពានអំណាច និងការបំពាននីតិវិធី (រួមទាំងការប្រព្រឹត្តិចំពោះភាគីនីមួយៗមិនស្មើគ្នាផងដែរ) ព្រមទាំងការជ្រៀតជ្រែក និងការជះឥទ្ធិពលពីភាគីខាងក្រៅផងដែរ។[6] សម្រាប់សាធារណជន រួមមានអ្នកសារព័ត៌មាន ការជំនុំជម្រះជាសាធារណៈ អនុញ្ញាតឱ្យអ្នកសារព័ត៌មាន និងសាធារណជនធ្វើការ**តាមដាន**និង**ស្វែងយល់**ថា តើដំណើរការ និងសេចក្តីសម្រេចមានយុត្តិធម៌កម្រិតណានៅក្នុងប្រព័ន្ធតុលាការ។[7]



---

[5] ដូចខាងលើ កថាខណ្ឌ ២៨។

[6] ម.ស.ម.ក, សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសៀវភៅណែនាំអំពីការសង្កេតការណ៍សវនាការ (ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រ ២២ https://sithi.org/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook ។

[7] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំអំពីការជំនុំជម្រះយុត្តិធម៌, ការបោះពុម្ពលើកទី ២" (ខែមេសា ឆ្នាំ២០១៤) ទំព័រ ១២១ https://www.amnesty.org/en/documents/pol30/002/2014/en/។

ការផ្សព្វផ្សាយអំពីការជំនុំជំម្រះក៏ជួយបង្កើត**ទំនុកចិត្ត**ពាក់ព័ន្ធនឹងសមត្ថភាពរបស់រដ្ឋក្នុងការផ្តល់យុត្តិធម៌ នៅពេលពួកគេមើលឃើញថាប្រព័ន្ធច្បាប់ បានប្រព្រឹត្តិទៅស្របទៅតាមច្បាប់ និងគោលការណ៍ក្រមសីលធម៌។[8]



ការរាំងមិនឱ្យសាធារណជនតាមដានដំណើរការយុត្តិធម៌ គឺជាការគំរាមកំហែងលើគោលការណ៍នីតិរដ្ឋ។ ការបដិសេធសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈធ្វើឱ្យមានលំហសម្រាប់អំពើពុករលួយ និងនិទណ្ឌភាព និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ ដោយសារធ្វើឱ្យពួកគេប្រឈមនឹងការផ្តន្ទាទោសមិនត្រឹមត្រូវ និងការសម្រេចទោសដោយអយុត្តិធម៌។

## ៤. ដែនកំណត់

ច្បាប់អនុញ្ញាតឱ្យមានការរឹតត្បិតលើសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ នៅក្នុងលក្ខខណ្ឌជាក់លាក់មួយចំនួន និងកាលៈទេសៈដែលបានកំណត់យ៉ាងរឹតត្បិតមួយចំនួន។ យោងតាមមាត្រា ១៤(១) នៃ ក.អ.ស.ព.នសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈអាចត្រូវបានរឹតត្បិត ប្រសិនបើមានការគំរាមកំហែងលើចំណុចដូចខាងក្រោម៖



- សីលធម៌ (ឧទាហរណ៍ ប្រសិនបើសំណុំរឿងនោះពាក់ព័ន្ធនឹងបទល្មើសផ្លូវភេទ)[9]
- សណ្តាប់ធ្នាប់សាធារណៈ
- សន្តិសុខជាតិនៅក្នុងសង្គមប្រជាធិបតេយ្យ
- នៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឱ្យធ្វើដូច្នេះ (ឧទាហរណ៍ ការការពារអត្តសញ្ញាណជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ)[10] ឬ
- នៅក្នុងស្ថានភាពពិសេស នៅពេលតុលាការយល់ឃើញថាការធ្វើជាសាធារណៈនឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌។

[8] ម.ស.ម.ក, សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសៀវភៅណែនាំអំពីការការសង្កេតការណ៍សវនការ, ទំព័រ ២២។

[9] អង្គការលើកលែងទោសអន្តរជាតិ, 'សៀវភៅណែនាំអំពីការជំនុំជម្រះយុត្តិធម៌, ការបោះពុម្ពលើកទី ២' (ខែមេសា ឆ្នាំ២០១៤) ទំព័រ ១២៣, https://www.amnesty.org/en/documents/pol30/002/2014/en/។

[10] ដូចខាងលើ។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈគឺអនុញ្ញាតឱ្យ៖

☐ក. ភាគីក្នុងសំណុំរឿងព្រហ្មទណ្ឌ និងសាច់ញាតិភាគីក្នុងសំណុំរឿងអាចចូលក្នុងបន្ទប់សវនាការបាន

☐ខ. សាធារណជន និងសមាជិកនៃសារព័ត៌មានអាចចូលសង្កេតការណ៍សវនាការបាន

☐គ. មានទាំងអស់ខាងលើ

២. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈជាសិទ្ធិដាច់ខាត មានន័យថាសិទ្ធិនេះមិនត្រូវបានរឹតត្បិតទេ។

☐ក. ខុស ☐ខ. ត្រូវ

៣. សារៈសំខាន់នៃការជំនុំជម្រះជាសាធារណៈ៖

☐ក.ដើម្បីធានានូវតម្លាភាព,ទំនួលខុសត្រូវក្នុងដំណើរការស្វែងរកយុត្តិធម៌,បង្កើនទំនុកចិត្តពីសាធារណជនលើតុលាការក្នុងការផ្តល់យុត្តិធម៌

☐ខ. ដើម្បីបំពេញតម្រូវការដល់ភាគីក្នុងសំណុំរឿង

៤. តើច្បាប់ជាតិណាខ្លះដែលចែងធានានូវដំណើរការសវនាការត្រូវតែធ្វើជាសាធារណៈ?

☐ក. ក្រមនីតិវិធីព្រហ្មទណ្ឌ, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

☐ខ.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,ក្រមនីតិវិធីព្រហ្មទណ្ឌ,ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងក្រមព្រហ្មទណ្ឌ

៥. តើលិខិតុបករណ៍អន្តរជាតិណាខ្លះ ដែលចែងធានានូវដំណើរការសវនាការត្រូវតែធ្វើឡើងជាសាធារណៈ?

☐ក. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

☐ខ. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

☐គ. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

☐ឃ. ក និង ខ

☐ង. ខ និង គ

៦. តើតុលាការអាចធ្វើការជំនុំជម្រះជាអសាធារណៈលើសំណុំរឿងទាំងមូល ឬមួយផ្នែកក្នុងករណីដែលសំណុំរឿងនោះអាចប៉ះពាល់ដល់សីលធម៌ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ឬការពារផលប្រយោជន៍ជីវិតឯកជនរបស់គូភាគីដែរឬទេ?

☐ក. បាទ/ចាស ☐ខ. អត់បាន

៧. ចៅក្រមមិនអនុញ្ញាតឱ្យព្រះសង្ឃចូលរួមសង្កេតការណ៍សវនាការទេដោយលើកហេតុផលថា ព្រះសង្ឃមិនគួរចូលរួមក្នុងសវនាការនៃសំណុំរឿងព្រហ្មទណ្ឌណាមួយឡើយ។

☐ក. ខុស ☐ខ. ត្រូវ

# សិទ្ធិបង្ហាញភស្តុតាង

## (សិទ្ធិហៅ និងសាកសួរសាក្សី)



# មាតិកា


១.និយមន័យ........ 68

២. ក្របខ័ណ្ឌច្បាប់ ........ 69

២.១.ច្បាប់អន្តរជាតិ ........ 69

២.២.ច្បាប់ជាតិ ........ 69

៣. សារៈសំខាន់........ 71

៤.ដែនកំណត់ ........ 72

៥.សំណួរ ........ 73

## ១. និយមន័យ

រាល់សេចក្តីសម្រេចរបស់តុលាការ ត្រូវតែផ្អែកលើភស្តុតាង ដែលបានបង្ហាញនៅអំឡុងពេលជំនុំជម្រះ។ ហេតុដូច្នោះ នេះជាការសំខាន់ ដែលភាគីនីមួយៗត្រូវបានផ្តល់ឱកាសដើម្បីបង្ហាញភស្តុតាង និងហៅសាក្សីនានា ក្នុងការគាំទ្រដល់សំណុំរឿងរបស់ខ្លួន និងសួរដេញដោលសាក្សី ដែលត្រូវបានហៅមកដោយភាគីដទៃ ដើម្បីតទល់នឹងភស្តុតាង ដែលពួកគេមិនទទួលយក។[1]



សិទ្ធិបង្ហាញភស្តុតាង រួមមាន សិទ្ធិហៅ និងសាកសួរសាក្សី ផ្តល់ឱ្យភាគីជនជាប់ចោទនូវអំណាចស្របច្បាប់ ក្នុងការបង្ហាញភស្តុតាង ក៏ដូចជា ការហៅ និងសាកសួរសាក្សី ដូចព្រះរាជអាជ្ញាដែរ[2]។





- **ការហៅសាក្សី៖** សាក្សីអាចត្រូវបានហៅដោយតុលាការខ្លួនឯង ឬតាមការស្នើសុំរបស់ភាគី។ នេះមានន័យថា ជនជាប់ចោទអាចទាមទារឱ្យមានការចូលរួមរបស់សាក្សី និងវត្តមានសាក្សីរបស់ខ្លួន និងអ្នកជំនាញដើម្បីធ្វើសក្ខីកម្មគាំទ្ររបស់ខ្លួន។
- **ការសាកសួរសាក្សី៖** សាក្សីតុលាការអាចសាកសួរ ដោយមិនគិតថា នរណាជាអ្នកហៅសាក្សីនោះ។ ភាគីនីមួយៗ រួមមានជនជាប់ចោទ អាចសួរសាក្សីរបស់ខ្លួន ដើម្បីគាំទ្រសំណុំរឿងរបស់ខ្លួន។
- **ការសួរដេញដោលសាក្សី៖** ភាគីនីមួយៗមានសិទ្ធិសួរដេញដោលសាក្សី ដែលត្រូវបានបង្ហាញដោយភាគីដទៃទៀត។ នេះមានន័យថា ជនជាប់ចោទអាចសួរសាក្សីរបស់ព្រះរាជអាជ្ញា ក្នុងគោលបំណងដើម្បីតទល់នឹងសក្ខីកម្មដែលប្រឆាំងនឹងពួកគេ។ គ្រប់ភស្តុតាងទាំងអស់ ដែលត្រូវបានបង្ហាញនៅពេលសវនាការអាចត្រូវបានជំទាស់។

---

[1] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២--មាត្រា១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌, (CPPR/C/GC/32, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧), កថាខណ្ឌ ១៣ និងទី៣៩,
https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CCPR%2FC%2FGC%2F32&Lang=n

[2] គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៩។

## ២. ក្របខ័ណ្ឌច្បាប់

### ២.១. ច្បាប់អន្តរជាតិ

កតិកាសញ្ញាអន្តរជាតិស្ដីសិទ្ធិពលរដ្ឋ និងនយោបាយ ("ក.អ.ស.ព.ន") ការពារសិទ្ធិនេះ និងធានាដល់ជនជាប់ចោទទទួលបាននូវលទ្ធភាពក្នុងការហៅ និងសាកសួរសាក្សី។ ជនជាប់ចោទអាចហៅ និងសួរសាក្សីដើម្បីផ្ដល់ភស្ដុតាងជំនួសខ្លួនបាន។ នៃកតិកាសញ្ញាអន្តរជាតិស្ដីសិទ្ធិពលរដ្ឋ និងនយោបាយ ("ក.អ.ស.ព.ន") ចែងថា៖



**មាត្រា ១៤(៣)(ង)នៃក.អ.ស.ព.ន** "ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។"

### ២.២. ច្បាប់ជាតិ



សិទ្ធិហៅ និងសាកសួរសាក្សី ត្រូវបានការពារតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ដែលចែងថា "ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ"។

សិទ្ធិនេះក៏ត្រូវបានការពារតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា("ក្រមនីតិវិធី") ដែលចែងលម្អិតបន្ថែមអំពីអ្នកដែលត្រូវបានសវនាការនៅតុលាការ និងអ្នកដែលអាចហៅ និងសួរសាក្សីសាក្សីបាន។

**ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៥៣៖**

"ចៅក្រមស៊ើបសួរអាចសាកសួរបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសម្ដែងឱ្យឃើញការពិត [...] ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីផងដែរ។"



**មាត្រា ១៥៣៖** "មុននឹងឆ្លើយទៅនឹងសួរសំណួរ សាក្សីម្នាក់ៗ ត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិតប៉ុណ្ណោះ។ ទម្រង់នៃសម្បថ ត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនេះ។"

**មាត្រា ២៩៨៖** "ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណីអាចនាំចូលក្នុងសវនាការនូវសាក្សីទាំងឡាយណាដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញសោហ៊ុយ។

**មាត្រា ៣២១៖** "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្តអំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការសំអាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ។ ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ។ ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន និងមិនអាចយកមកធ្វើជាភស្តុតាងបានឡើយ។"

**មាត្រា ៣២៤៖** "នៅពេលបើកកិច្ចពិភាក្សាដេញដោល ភាគីនីមួយៗអាចសុំឱ្យតុលាការស្ដាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែបុគ្គលនោះមិនបានកោះហៅឱ្យបានត្រឹមត្រូវទេ។ ការស្ដាប់ចម្លើយសាក្សីនេះ ត្រូវមានការយល់ព្រមពីប្រធានសវនាការ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះឱ្យថយទៅនៅបន្ទប់រង់ចាំ។

**មាត្រា ៣២៦៖** "ប្រធានសវនាការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ [...]។ ព្រះរាជអាជ្ញា មេធាវី និងភាគីទាំងអស់ អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរគ្រប់ការលើកសំណួរទាំងអស់ ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈប្រធានសវនាការ។ ក្នុងករណីមានការតវ៉ាប្រធានសវនាការសម្រេចចិត្តដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរ ឬទេ។"

**មាត្រា ៣២៨៖** "មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីនីមួយៗ ត្រូវស្បថថា ខ្លួននិយាយតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន។"

**មាត្រា ៣៩៤៖** "ក្រោយពេលសួរចម្លើយជនជាប់ចោទរួច ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ សាក្សី និងអ្នកជំនាញនឹងត្រូវបានគេស្តាប់ចម្លើយ លុះត្រាតែតុលាការបង្គាប់ឱ្យស្តាប់ចម្លើយជនទាំងនេះ។"

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនក៏បានចែងពីសិទ្ធិរបស់កុមារទំនាស់ នឹងច្បាប់ក្នុងការហៅ និងការលើកជាសំណួរទៅកាន់សាក្សីនៅក្នុងមាត្រា ៦។




**ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៦៖** "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [.......] សិទ្ធិបង្ហាញភស្តុតាង។ សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី [...]."

## ៣. សារៈសំខាន់



សិទ្ធិហៅ និងសាកសួរសាក្សីចែងថា តុលាការមានឱកាសក្នុងការពិនិត្យភស្តុតាង និងស្តាប់ការដេញដោលផ្នែកច្បាប់ដោយយោងទៅតាមតម្លៃនៃភស្តុតាង។ ដូច្នេះ សិទ្ធិនេះជួយដល់តុលាការក្នុងការវាយតម្លៃការដេញដោលផ្សេងៗដែលបានត្រូវបង្ហាញ និងធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងពាក់ព័ន្ធ[3]។

សិទ្ធិនេះបើកផ្លូវឱ្យជនជាប់ចោទធ្វើការស៊ើបអង្កេតលើភាពគួរជឿបាននៃសាក្សីរបស់ព្រះរាជអាជ្ញា ឬរបស់ជនរងគ្រោះ និងភាពអាចទុកចិត្តបាននៃភស្តុតាងរបស់ពួកគេ ដោយសួរសំណួរពួកគេ និងតទល់នឹងសក្ខីកម្មរបស់ពួកគេ[4]។ សិទ្ធិនេះក៏អនុញ្ញាតឱ្យជនជាប់ចោទឆ្លើយតបយ៉ាងពេញលេញចំពោះគ្រប់ការដេញដោលទាំងអស់ និងភស្តុតាងដែលត្រូវបានបង្ហាញដោយភាគីដទៃនៅពេលសវនាការ[5]។ ហេតុដូចនេះ សិទ្ធិហៅ និងសាកសួរសាក្សី គឺសំខាន់ក្នុងការធានាដល់ជនជាប់ចោទនូវការការពារប្រកបដោយប្រសិទ្ធភាព[6]។

---

[3] ម.ស.ម.ក, សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ទំព័រទី២៥។

[4] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ("CSD") 'របាយការណ៍ប្រចាំឆ្នាំ៖ គម្រោងឃ្លាំមើលតុលាការ', (ខែកុម្ភៈ ឆ្នាំ២០០៧)។

[5] ដូចខាងលើ។

[6] ដូចខាងលើ។



ជាចុងក្រោយ សិទ្ធិហៅ និងសាកសួរសាក្សី គឺជាធាតុផ្សំសំខាន់នៃគោលការណ៍ភាពស្មើគ្នា[7]។ ភាពស្មើគ្នា គឺជាគោលការណ៍ ដែលគ្រប់ភាគីត្រូវបានប្រព្រឹត្តក្នុងវិធីដែលធានានូវសមភាពនៅគ្រប់ដំណាក់កាលនៃសវនាការ ហើយគ្មានភាគីណាមួយត្រូវបានកេងប្រយោជន៍ពី ភាគីដទៃក្នុងការបង្ហាញនូវសំណុំរឿងរបស់ពួកគេនោះទេ[8]។

**ជាផលវិបាក** ប្រសិនបើតុលាការមិនអនុញ្ញាតឱ្យភាគីជនជាប់ចោទហៅ និងសាកសួរសាក្សី និងតទល់នឹងភស្តុតាង ដែលត្រូវបានបង្ហាញប្រឆាំងនឹងជនជាប់ចោទដូចព្រះរាជអាជ្ញាទេ បញ្ហានេះនឹងធ្វើឱ្យពួកគេខាតប្រយោជន៍នៅអំឡុងពេលសវនាការ។ ដោយការធ្វើដូច្នេះ តុលាការនឹងធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ភាពស្មើគ្នា និងបដិសេធការការពារដ៏មានប្រសិទ្ធភាពរបស់ភាគីជនជាប់ចោទ។ បន្ថែមលើនេះ តុលាការនឹងមិនអាចស្តាប់រាល់ព័ត៌មាន និងភស្តុតាងពាក់ព័ន្ធ ដែលចាំបាច់ក្នុងការវាយតម្លៃដោយច្បាស់លាស់លើអង្គហេតុ។ បញ្ហានេះនឹងជះឥទ្ធិពលដល់សាលក្រម និង/ឬការកាត់ទោសរបស់តុលាការ និងភាគច្រើនទំនងជានាំឱ្យមានសេចក្តីសម្រេចអយុត្តិធម៌ប្រឆាំងនឹងជនជាប់ចោទ ដែលរួមមានការសម្រេចដាក់ទោសលើពួកគេមិនត្រឹមត្រូវ។

## ៤. ដែនកំណត់

សិទ្ធិហៅ និងសាកសួរសាក្សីជាសិទ្ធិដែលមានដែនកំណត់។ តុលាការមានតួនាទីត្រឹមតែហៅសាក្សីដែលសក្ខីកម្មរបស់ពួកគេពាក់ព័ន្ធនឹងសំណុំរឿងតែប៉ុណ្ណោះ។ ប្រសិនបើជនជាប់ចោទចង់ហៅសាក្សីណាមួយដាក់លាក់ជំនួសខ្លួន គេត្រូវពន្យល់ប្រាប់តុលាការពីមូលហេតុ ថាមានសារៈសំខាន់សម្រាប់សំណុំរឿង។

ទោះបីជាយ៉ាងនេះក្តី ការរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទនឹងកើតឡើង ប្រសិនបើតុលាការអនុញ្ញាតឱ្យព្រះរាជអាជ្ញាអញ្ជើញសាក្សីសំខាន់ ប៉ុន្តែបដិសេធចំពោះការអញ្ជើញសាក្សីសំខាន់ដូចគ្នាដែលបានស្នើដោយជនជាប់ចោទ។

[7] ដូចខាងលើ។

[8] ម.ស.ម.ក, សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ទំព័រទី២៥។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. សិទ្ធិបង្ហាញភស្តុតាងរួមមានសិទ្ធិហៅ និងសាកសួរសាក្សីសំដៅដល់ការផ្តល់ឱ្យជនជាប់ចោទនូវសិទ្ធិដែលធានាដោយច្បាប់ក្នុងការបង្ហាញភស្តុតាង ក៏ដូចជាការហៅសាក្សី និងសាកសួរសាក្សីដូចព្រះរាជអាជ្ញាដែរ នៅអំឡុងពេលជំនុំជម្រះ។

☐ក. ត្រូវ ☐ខ. ខុស

២. ប្រសិនបើតុលាការមិនអនុញ្ញាតឱ្យជនជាប់ចោទអាចហៅ និងសាកសួរសាក្សី ព្រមទាំងបង្ហាញនូវភស្តុតាង តើនឹងមានផលប៉ះពាល់អ្វីខ្លះ?

☐ក. ប៉ះពាល់ដល់គោលការណ៍ស្មើភាពគ្នា

☐ខ.ទទួលបានសេចក្តីសម្រេចដែលអយុត្តិធម៌

☐គ. បំពានសិទ្ធិមិនត្រូវបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព

☐ឃ. ក និង ខ

☐ង. ក, ខ និង គ

៣. តើសិទ្ធិបង្ហាញភស្តុតាងមានសារៈសំខាន់អ្វីខ្លះ?

☐ក. សិទ្ធិនេះផ្តល់ឱ្យតុលាការត្រួតពិនិត្យភស្តុតាង និងស្តាប់ភាគីទាំងអស់ធ្វើអំណះអំណាង និងធ្វើការសម្រេចចិត្តផ្អែកលើភស្តុតាងពាក់ព័ន្ធ។

☐ខ. សិទ្ធិនេះ ផ្តល់ឱ្យជនជាប់ចោទដាក់ភស្តុតាងប្រឆាំងឱ្យបានពេញលេញ ដើម្បីតតាំងក្នុងពេលសវនាការ រួមមានសក្ខីកម្មនៃសាក្សីរបស់ព្រះរាជអាជ្ញា។

☐គ. សិទ្ធិនេះ ផ្តល់ឱ្យជនជាប់ចោទបង្ហាញភស្តុតាងជាជំនួយដល់សំណុំរឿងរបស់ពួកគេ រួមមានការហៅ និងសាកសួរសាក្សីរបស់ពួកគេផ្ទាល់។

☐ឃ. ចម្លើយខាងលើទាំងអស់

៤. តើលិខិតុបករណ៍ជាតិ និងអន្តរជាតិណាខ្លះដែលមានចែងអំពីសិទ្ធិបង្ហាញភស្តុតាង?

☐ក.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

☐ខ. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

☐គ. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

☐ឃ. កតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

☐ង. ក,ខ និង គ

៥. តើជនរងការចោទប្រកាន់អាចសួរសំណួរទៅកាន់សាក្សីរបស់ព្រះរាជអាជ្ញាក្នុងពេលសវនាការបានដែរទេ?

☐ក. បាន ☐ខ. មិនបាន

៦. សិទ្ធិហៅ និងសាកសួរសាក្សីជាសិទ្ធិគ្មានដែនកំណត់ មានន័យថាជនរងការចោទប្រកាន់អាចទទួលបាននូវវត្តមានរបស់សាក្សី នៅគ្រប់ពេលវេលា និងគ្មានលក្ខខណ្ឌ។

☐ក. ខុស ☐ខ. ត្រូវ

៧. តើចៅក្រមអាចបដិសេធមិនកោះហៅសាក្សីតាមការស្នើសុំរបស់ភាគីជនជាប់ចោទ ដោយសំអាងថាសាក្សីនោះជាជនកម្សោយក្នុងការស្តាប់ និងនិយាយ។

☐ក. ខុស ☐ខ. ត្រូវ

# សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ










# មាតិកា


១.និយមន័យ ........ 74

១.១. សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ ........ 74

១.២. សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ........ 74

២. ក្របខ័ណ្ឌច្បាប់ ........ 75

២.១. ច្បាប់អន្តរជាតិ ........ 75

២.២.ច្បាប់ជាតិ ........ 76

៣.សារៈសំខាន់ ........ 77

៤.ដែនកំណត់ ........ 78

៥.សំណួរ ........ 80

## ១. និយមន័យ

### ១.១. សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ



សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ សំដៅលើការប្រកាសសេចក្តីសម្រេចទាំងរឿងក្តីរដ្ឋ- ប្បវេណី និងព្រហ្មទណ្ឌត្រូវតែធ្វើឡើងជាសាធារណៈ។ សិទ្ធិនេះផ្សារភ្ជាប់ទៅសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈរបស់ជនជាប់ចោទ ដែលសិទ្ធិទាំងពីរនេះមានគោលបំណង ដើម្បីធានាការគ្រប់គ្រងយុត្តិធម៌ជា សាធារណៈ និងដោយបើកចំហ។[1]

សិទ្ធិនេះក៏អនុវត្តផងដែរ នៅពេលសវនាការត្រូវបានធ្វើឡើងជាអសាធារណៈ។ បើទោះបីជាសាធារណជនមិនត្រូវអនុញ្ញាតឱ្យចូលរួមក្នុងសវនាការក៏ដោយ តុលាការមានកាតព្វកិច្ចចេញសេចក្តីសម្រេចជាសាធារណៈ រួមមានការរកឃើញសំខាន់ៗភស្តុតាង និងសំអាងហេតុផ្នែកច្បាប់។[2]





សេចក្តីសម្រេចត្រូវបានចាត់ទុកថាជាសាធារណៈ នៅពេលសេចក្តីសម្រេចនោះត្រូវបានប្រកាសដោយផ្ទាល់មាត់ដោយតុលាការនៅក្នុងសវនាការជាសាធារណៈ ឬផ្តល់ឱ្យជាលាយលក្ខណ៍អក្សរទៅភាគីពាក់ព័ន្ធ និងសាធារណជនអាចរកបានរួមទាំងតាមរយៈបញ្ជីការរបស់តុលាការ ឬតាមទីតាំងផ្សេងៗទៀត ដូចជាគេហទំព័រជាដើម។[3]



ប្រសិនបើជនជាប់ចោទមិនអាចយល់ភាសាដែលតុលាការប្រើប្រាស់ទេ តុលាការត្រូវតែធានាថា សេចក្តីសម្រេចជាភាសាដែលជនជាប់ចោទអាចយល់បាន និងមានការបកប្រែទៅតាមភាសានោះ ដែលអនុលោមតាមសិទ្ធិទទួលបានអ្នកបកប្រែ និងការបកប្រែ។[4]

### ១.២. សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

**សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ** គឺស្ថិតក្នុង**សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌** និងត្រូវបានបញ្ចូលនៅក្នុង**សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ**។[5] សិទ្ធិនេះមានន័យថា សេចក្តីសម្រេច

---

[1] អង្គការលើកលែងទោសអន្តរជាតិ, "សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌" (បោះពុម្ពលើកទី ២, ២០១២) ទំព័រ ១៧២ ផ្នែក ២៤.១, https://www.amnesty.org/download/Documents/8000/pol300022014en.pdf ("សៀវភៅណែនាំអំពីសិទ្ធិនៃការជំនុំជម្រះដោយយុត្តិធម៌របស់អង្គការលើកលែងទោសអន្តរជាតិ")។

[2] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សេចក្តីពន្យល់ទូទៅ លេខ៣២ មាត្រា ១៤ សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងសាលាជម្រះក្តី រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌", (UN Doc CCPR/C/GC/៣២, ២៣ សីហា ២០០៧), កថាខណ្ឌ ២៩, https://www.refworld.org/docid/478b2b2f2.html។ ("គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅ លេខ ៣២")។

[3] សៀវភៅណែនាំអំពីសិទ្ធិជំនុំជម្រះដោយយុត្តិធម៌អង្គការលើកលែងទោសអន្តរជាតិ, ទំព័រ ១៧២, ចំណុច ២៤.១; អ.ស.ស.អ, "សេចក្តីសង្ខេបផ្លូវច្បាប់ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ" (២៦ កញ្ញា ២០១២), ជំពូក IV, ទំព័រ ២០៨, https://www.osce.org/odihr/94214#:~:text=The%20Legal%20Digest%20of%20International,of%20OSCE%20trial%20monitoring%20operations។ ("អ.ស.ស.អ, សេចក្តីសង្ខេបផ្លូវច្បាប់ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ")។

[4] សៀវភៅណែនាំអំពីសិទ្ធិជំនុំជម្រះដោយយុត្តិធម៌អង្គការលើកលែងទោសអន្តរជាតិ, ទំព័រ ១៧២។

[5] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សិទ្ធិមនុស្សនៅក្នុងការគ្រប់គ្រងយុត្តិធម៌៖ សៀវភៅណែនាំស្តីពីសិទ្ធិមនុស្សសម្រាប់ចៅក្រម, ព្រះរាជអាជ្ញា និងមេធាវី", ជំពូក ៧, (ឆ្នាំ២០០៣) ទំព័រ ២៩៣,

ព្រហ្មទណ្ឌ ដែលប្រឆាំងនឹងបុគ្គល ត្រូវតែមានការពន្យល់ពីមូលហេតុ និងអំពីរបៀបនៃការចេញសាលក្រម/សាលដីកា និងមូលហេតុដែលបុគ្គលនោះត្រូវបានរកឃើញថាមានពិរុទ្ធភាព ឬគ្មានទោស។

សិទ្ធិនេះមានគោលបំណងដើម្បីធានាថា អ្នកដែលរកឃើញថាមានពិរុទ្ធភាព ត្រូវបានប្រព្រឹត្តទៅតាម **គោលការណ៍ច្បាប់។ សេចក្ដីសម្រេចមានសំអាងហេតុ**ក៏បើកផ្លូវឱ្យ**ប្ដឹងតវ៉ាទៅតុលាការជាន់ខ្ពស់** ប្រសិនបើសំអាងហេតុក្នុងសេចក្ដីសម្រេចនោះមិនស្របទៅតាមច្បាប់។

ការគោរពសិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ គឺតម្រូវឱ្យតុលាការពិនិត្យលើការចោទប្រកាន់ និងអំណះអំណាងនីមួយៗ ដែលបានបង្ហាញនៅអំឡុងពេលសវនាការ និងឆ្លើយតបទឡ្ហីករណ៍ជាលាយលក្ខណ៍អក្សរ ដែលបានដាក់ដោយភាគីណាមួយ។

នៅក្នុងសេចក្ដីសម្រេចរបស់តុលាការ ចៅក្រមត្រូវតែពន្យល់ទាំងផ្នែកអង្គហេតុ និងអង្គច្បាប់ ដែលជាមូលដ្ឋាននៃសេចក្ដីសម្រេច៖[6]



- **អង្គហេតុ៖** សេចក្ដីសម្រេចត្រូវតែកំណត់អំពីអង្គហេតុ សម្រាប់ជនដែលត្រូវបានផ្ដន្ទាទោសយ៉ាងច្បាស់លាស់តាមដែលអាចធ្វើទៅបាន រួមមាន ថ្ងៃកើតហេតុ ទីតាំងកើតហេតុ និងព្រឹត្តការណ៍ជាក់ស្ដែងផ្សេងៗទៀត។ ក្នុងការធ្វើដូច្នេះ ចៅក្រមត្រូវតែយោងទៅលើភស្តុតាង ចម្លើយសារភាព ឬសក្ខីកម្មរបស់សាក្សីជាក់លាក់ និងពន្យល់ពីមូលហេតុដែលពួកគេពឹងផ្អែក។



- **អង្គច្បាប់៖** សេចក្ដីសម្រេចក៏ត្រូវតែមានបញ្ចូលនូវមូលដ្ឋានគ្រឹះនៃច្បាប់ ដែលជាមូលដ្ឋាននៃសំអាងហេតុ ទាំងលក្ខខណ្ឌនៃច្បាប់ពិសេស (បទល្មើស) និងការទទួលខុសត្រូវព្រហ្មទណ្ឌ (របៀបនៃការទទួលខុសត្រូវ៖ ចារី អ្នកសមគំនិត ។ល។)។

# ២. ក្របខ័ណ្ឌច្បាប់

## ២.១. ច្បាប់អន្តរជាតិ

**សិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈ** ត្រូវបានធានាយ៉ាងច្បាស់លាស់ដោយមាត្រា ១៤ កថាខណ្ឌ ១ នៃ**កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ** ("ក.អ.ស.ព.ន") ដែលត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងច្បាប់ជាតិតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**សិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ** មិនត្រូវបានបញ្ជាក់ច្បាស់លាស់ទេនៅក្នុងកតិកាសញ្ញានេះ ប៉ុន្តែមាននៅក្នុងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (មាត្រា ១៤ នៃ ក.អ.ស.ព.ន) រួមទាំងសិទ្ធិ

---

https://www.ohchr.org/Documents/Publications/training9chapter7en.pdf ។ (« សៀវភៅណែនាំរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ »)

[6] ម.ស.ម.ក, "ព្រឹត្តិបត្រព័ត៌មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ សិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ,"(២០១៨), ទាញយកពី៖ https://cchrcambodia.org/admin/media/newsletter/newsletter/english/CCHR%20Fair%20Trial%20Rights%20Newsletter%20on%20Right%20to%20Reasoned%20Judgment_Eng.pdf ។

ទទួលបានសេចក្តីសម្រេចជាសាធារណៈ(មាត្រា ១៤ (១) និងសិទ្ធិប្តឹងតវ៉ាទៅតុលាជាន់ខ្ពស់ (មាត្រា ១៤ (៥)) នៃ ក.អ.ស.ព.ន។[7]



**មាត្រា ១៤ (១) នៃ ក.អ.ស.ព.ន៖** "[...] ប៉ុន្តែ ការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ" ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។"

**មាត្រា ១៤ (៥) នៃ ក.អ.ស.ព.ន៖** "ជនគ្រប់រូបត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ ពិនិត្យទៅលើការប្រកាស ពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់។"

## ២.២. ច្បាប់ជាតិ

**សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ** និង**សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ** ក៏ត្រូវបានការពារយ៉ាងជាក់លាក់ក្រោមច្បាប់កម្ពុជា។

**សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ** ត្រូវបានធានាដោយ**ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** ("ក្រមនីតិវិធីព្រហ្មទណ្ឌ") និង**ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ** ដូចដែលបានលើកឡើងខាងក្រោម៖



**មាត្រា ៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ៖** "[...] គ្រប់ករណីទាំងអស់ សាលក្រមត្រូវប្រកាសជាសាធារណៈ [...]"។



**មាត្រា ៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "នៅក្នុងគ្រប់ករណីទាំងអស់ សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ។"

- **សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ** ក៏ត្រូវបានធានាដោយ**ក្រមនីតិវិធីព្រហ្មទណ្ឌ**ផងដែរ៖

[7] សៀវភៅណែនាំរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, ជំពូក ៧, (ឆ្នាំ២០០៣) ទំព័រ២៥៣, https://www.ohchr.org/Documents/Publications/training9chapter7en.pdf ។

**មាត្រា ៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** គ្រប់សាលក្រមត្រូវមានពីរផ្នែក៖

- ផ្នែកសំអាងហេតុពោលគឺជាទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច។
- ផ្នែកសេចក្តីសម្រេចពោលគឺជាសេចក្តីសម្រេចរបស់តុលាការ។

អង្គហេតុត្រូវតែមានភាពច្បាស់លាស់ និងគ្មានការសង្ស័យ។ តុលាការត្រូវពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបាននៅពេលសវនាការ។

ផ្នែកសេចក្តីសម្រេចត្រូវចុះនិទ្ទេស អំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តខុស អត្ថបទច្បាប់ដែលអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី។

**មាត្រា ៤០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** វិធានស្តីពីទម្រង់ និងហត្ថលេខាលើសាលក្រមរបស់សាលាដំបូង ត្រូវអនុវត្តលើសាលដីការបស់សាលាឧទ្ធរណ៍។

## ៣. សារៈសំខាន់

*សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ* និង*សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ*មានសារៈសំខាន់ក្នុងការធានាប្រព័ន្ធយុត្តិធម៌បើកចំហ មាន*តម្លាភាព* និងការទទួលខុសត្រូវដែល*ប្រជាពលរដ្ឋជឿជាក់* និងជា*មូលដ្ឋានគ្រឹះនៃនីតិរដ្ឋ*។ សេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ អនុញ្ញាតឱ្យមានការត្រួតពិនិត្យជាសាធារណៈលើការគ្រប់គ្រងយុត្តិធម៌ និងសម្រាប់ការទទួលខុសត្រូវរបស់តុលាការចំពោះសេចក្តីសម្រេច ដែលពួកគេធ្វើ។[8]



ប្រជាពលរដ្ឋត្រូវតែអាចឃើញយុត្តិធម៌ត្រូវបានផ្តល់ជូន និងពីរបៀបដែលយុត្តិធម៌ត្រូវបានផ្តល់ ដើម្បីធានាថា យុត្តិធម៌ត្រូវបានគ្រប់គ្រងយ៉ាងត្រឹមត្រូវ។ ភាពចាំបាច់ក្នុងការធ្វើឱ្យមានសេចក្តីសម្រេចមានសំអាងហេតុ និងធ្វើឱ្យសេចក្តីសម្រេចនេះទៅជាសាធារណៈ តម្រូវឱ្យចៅក្រមពន្យល់ពីការសម្រេចចិត្តរបស់ខ្លួន និងធានាថាជនជាប់ចោទដឹងពីមូលហេតុ និងអ្វីដែលពួកគេកំពុងត្រូវបានកាត់ទោស ដែលការពារបុគ្គលពីភាពតាមទំនើងចិត្ត និងការរំលោភបំពានលើប្រព័ន្ធតុលាការ។[9]

បន្ថែមលើនេះ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុមានសារៈសំខាន់សម្រាប់ការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់មួយទៀត៖ **សិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់។**

[8] សៀវភៅណែនាំនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អង្គការលើកលែងទោសអន្តរជាតិ, ទំព័រ ១៧៣។

[9] សេចក្តីសង្ខេបផ្លូវច្បាប់នៃសិទ្ធិជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ, ជំពូក IV, ទំព័រ ២០៧។

យោងតាមបទដ្ឋានអន្តរជាតិ ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពចំពោះសិទ្ធិទទួលបានការកាត់ទោស និងការផ្តន្ទាទោស ដែលត្រូវបានពិនិត្យឡើងវិញដោយសាលាក្តីជាន់ខ្ពស់ ជនដែលត្រូវបានកាត់ឱ្យជាប់ទោសក្នុងរយៈពេលដ៏សមរម្យមួយ មាន**សិទ្ធិទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ** ដែលមានសំអាងហេតុត្រឹមត្រូវសម្រាប់ពាល់បណ្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់[10] សេចក្តីសម្រេចមានសំអាងហេតុ ពិតជាអនុញ្ញាតឱ្យភាគីមើលឃើញអំពីរបៀបដែលចៅក្រមវាយតម្លៃភស្តុតាង របៀបដែលពួកគេបានឈានដល់ការសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ ហើយហេតុដូច្នេះ អនុញ្ញាតឱ្យភាគីកំណត់ចំណុច ដែលពួកគេចង់តទល់ចំពោះមុខតុលាការជាន់ខ្ពស់។[11] សិទ្ធិទាំងនេះក៏អនុញ្ញាតឱ្យតុលាការជាន់ខ្ពស់ពិនិត្យ និងវិភាគយ៉ាងត្រឹមត្រូវលើសេចក្តីសម្រេចរបស់តុលាការជាន់ទាប។ ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេច ចៅក្រមត្រូវអាចពិនិត្យមើលថាតើភស្តុតាងណាពឹងផ្អែកលើអ្វីសម្រាប់ការកាត់ទោស និងមូលហេតុអ្វី។ ការទទួលបានឯកសារចាំបាច់ផ្សេងៗទៀត ដូចជាកំណត់ហេតុសវនាការ គួរធ្វើឱ្យភាគីអាចទទួលបានក្នុងលក្ខណៈទាន់ពេលវេលាផងដែរ ដើម្បីឱ្យពួកគេអនុវត្តសិទ្ធិរបស់ខ្លួនយ៉ាងមានអត្ថន័យក្នុងការប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់។[12] ប្រសិនបើបុគ្គលម្នាក់មិនទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ដោយពន្យល់អំពីមូលដ្ឋានផ្សេងៗសម្រាប់ការកាត់ទោស ឬការផ្តន្ទាទោស ដូច្នេះសិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ចាត់ទុកជាគ្មានន័យ ដែលរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[13]



ជាចុងក្រោយ សេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុអាចធ្វើឱ្យសាធារណជនទទួលបានព័ត៌មានផ្លូវច្បាប់ និងយល់ដឹងអំពីប្រភេទអំពើអ្វីប្រព្រឹត្តដែលស្របច្បាប់ ឬត្រូវបានហាមឃាត់ដោយច្បាប់។[14] សិទ្ធិទាំងនេះក៏មានសារៈសំខាន់ផងដែរសម្រាប់ការអភិវឌ្ឍនៃយុត្តិសាស្ត្រ និងភាពច្បាស់លាស់ផ្នែកច្បាប់អំពីការបកស្រាយ និងការអនុវត្តច្បាប់។

## ៤. ដែនកំណត់

**សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ** មិនមានលក្ខណៈដាច់ខាតទេ ហើយអាចត្រូវបានកម្រិតក្នុងកាលៈទេសៈមួយចំនួន។ យោងតាមមាត្រា ១៤ (១) នៃ ក.អ.ស.ព.ន ផ្តល់នូវបញ្ជីពេញលេញនៃការកម្រិត

---

[10] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅ លេខ ៣២, កថាខណ្ឌ ៤៩; គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, V. Francis ទល់នឹងប្រទេសចាម៉ៃកា, ទំនាក់ទំនង លេខ ៣២០/១៩៨៨, (១៩៩៣), កថាខណ្ឌ ១២.២, http://hrlibrary.umn.edu/undocs/html/320-1988.html។

[11] ម.ស.ម.ក, "ព្រឹត្តិបត្រព័ត៌មានស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ" (ឆ្នាំ២០១៨); សាលដីកាសាលាឧទ្ធរណ៍នៃ អ.វ.ត.ក សំណុំរឿងលេខ ០០២/០១, កថាខណ្ឌ ២០៥, ២០៧; សៀវភៅណែនាំនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អង្គការលើកលែងទោសអន្តរជាតិ, ទំព័រ ១៧៣, ចំណុច ២៤.២។

[12] ម.ស.ម.ក, "ព្រឹត្តិបត្រព័ត៌មានស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ", (ឆ្នាំ២០១៨); គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ ៣២, កថាខណ្ឌ ៤៩។

[13] ម.ស.ម.ក.," ព្រឹត្តិបត្រព័ត៌មានស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ", (ឆ្នាំ២០១៨); គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ ៣២, កថាខណ្ឌ ៨.៤។

[14] ម.ស.ម.ក, "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា៖ ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍" របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០)" ខែតុលា ឆ្នាំ២០២០, ទំព័រ ១៤ ។

ដែលអាចអនុញ្ញាតបានចំពោះសិទ្ធិនេះ។ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈអាចត្រូវបានកម្រិត នៅពេលដែលផលប្រយោជន៍របស់កុមារត្រូវបានតម្រូវ ឬក្នុងដំណើរការនីតិវិធី ដែលទាក់ទងនឹងជម្លោះអាពាហ៍ពិពាហ៍ ឬភាពជាអាណាព្យាបាលរបស់កុមារ។

**សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ** ត្រូវតែមានការគោរពគ្រប់ពេល និងគ្រប់ករណីទាំងអស់។ ទោះជាយ៉ាងនេះក្តី ចៅក្រមមិនត្រូវបានតម្រូវឱ្យឆ្លើយតបចំពោះអំណះអំណាងនីមួយៗ ដែលធ្វើឡើងដោយជនជាប់ចោទឡើយ។[15] សម្រាប់គណៈកម្មាធិការ**សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ** ("UNHRC") តុលាការត្រូវតែប្រកាសការរកឃើញសំខាន់ៗ ភស្តុតាង និងហេតុផលផ្លូវច្បាប់នៃការសម្រេចចិត្តរបស់ខ្លួនជាសាធារណៈ។

សម្រាប់**តុលាការសិទ្ធិមនុស្សអឺរ៉ុប** វិសាលភាពដែលតួនាទីរបស់តុលាការត្រូវផ្តល់សំអាងហេតុចំពោះការសម្រេចចិត្តរបស់ខ្លួន ផ្សេងគ្នាដោយយោងទៅតាមលក្ខណៈនៃការសម្រេចចិត្ត និងត្រូវតែកំណត់ទៅតាមកាលៈទេសៈនៃសំណុំរឿង។ ហេតុដូច្នេះ យ៉ាងហោចណាស់ ចៅក្រមប្រឈមនឹងការអះអាង ដែលសំខាន់ចំពោះលទ្ធផលនៃសំណុំរឿង។[16]



[15] សៀវភៅណែនាំនៃការិយាល័យឧត្តមស្នងការ, ជំពូក ៧, ទំព័រ ២៩៣-២៩៥ ។

[16] សៀវភៅណែនាំនៃការិយាល័យឧត្តមស្នងការ, ជំពូក ៧, ទំព័រ ២៩៣-២៩៥; សេចក្តីសង្ខេបផ្លូវច្បាប់នៃសិទ្ធិបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ, ទំព័រ ២១០ ។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១.សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈសំដៅលើការប្រកាសសេចក្តីសម្រេចទាំងសំណុំរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ត្រូវតែធ្វើឡើងជាសាធារណៈ។

□ក. ត្រូវ □ខ. ខុស

២. តើសេចក្តីសម្រេចជាសាធារណៈ ត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

□ក.សេចក្តីសម្រេចនោះត្រូវបានប្រកាសដោយផ្ទាល់មាត់ ដោយតុលាការនៅក្នុងសវនាការជាសាធារណៈ ឬ ផ្តល់ឱ្យជាលាយលក្ខណ៍អក្សរទៅភាគីពាក់ព័ន្ធ និងសាធារណជនអាចរកបាន រួមទាំងតាមរយៈបញ្ជីការរបស់តុលាការ ឬ តាមទីតាំងផ្សេងៗទៀត ដូចជាគេហទំព័រជាដើម។

□ខ.យ៉ាងហោចណាស់តុលាការត្រូវបង្ហាញពីការរកឃើញដែលមានសារៈសំខាន់កស្តុតាងនិងមូលដ្ឋានផ្លូវច្បាប់នៃសេចក្តីសម្រេចជាសាធារណៈ។

□គ. ចម្លើយ ក និង ខ

៣. តើច្បាប់ជាតិណាខ្លះដែលធានានូវសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ?

□ក. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

□ខ. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និង ក្រមព្រហ្មទណ្ឌកម្ពុជា

□គ. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និង ក្រមព្រហ្មទណ្ឌកម្ពុជា

៤. តើសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈត្រូវបានការពារដោយច្បាប់អន្តរជាតិណាមួយ?

□ក.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

□ខ.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

□គ.អនុសញ្ញាប្រឆាំងទារុណកម្ម

៥. សារៈសំខាន់នៃសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុគឺ៖

□ក. ធានាប្រព័ន្ធយុត្តិធម៌បើកចំហ មានតម្លាភាព និងការទទួលខុសត្រូវដែលប្រជាពលរដ្ឋជឿជាក់ និងជាមូលដ្ឋានគ្រឹះនៃនីតិរដ្ឋ។

□ខ.ការពារបុគ្គលពីការបំពានតាមទំនើងចិត្ត និងការរំលោភលើប្រព័ន្ធតុលាការ។

□គ.គូភាគីមានសិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់។

□ឃ.ក, ខ និង គ

៦. តើច្បាប់ជាតិ និងច្បាប់អន្តរជាតិណាខ្លះដែលបានចែងអំពីសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ?

□ក.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

□ខ.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ក្រមរដ្ឋប្បវេណី និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

□គ.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

៧.សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ សំដៅលើការធានាថាបុគ្គលដែលត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាព ឬ គ្មានទោស ដោយមានសេចក្តីសម្រេចបញ្ជាក់ពីអង្គហេតុ និងអង្គច្បាប់។

□ក. ត្រូវ □ខ. ខុស

៨. តើសេចក្តីសម្រេចដោយមានសំអាងហេតុត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

□ក. សេចក្តីសម្រេចសាធារណៈត្រូវធ្វើជាសាធារណៈ

□ខ.សេចក្តីសម្រេចត្រូវតែបញ្ជាក់ពីអង្គហេតុឱ្យច្បាស់ថាពាក់ព័ន្ធនឹងបុគ្គលដែលត្រូវបានផ្តន្ទាទោស រួមមានកាលបរិច្ឆេទ, ទីកន្លែង និងហេតុការជាក់ស្តែង ព្រមទាំងភស្តុតាងដែលជាមូលដ្ឋាន

□គ.សេចក្តីសម្រេចត្រូវមានសំអាងនូវមូលដ្ឋានច្បាប់

□ឃ. ខ និង គ

# ការហាមឃាត់ការអនុវត្តអានុភាព ភាពប្រតិសកម្ម នៃច្បាប់ព្រហ្មទណ្ឌ (ឬគោលការណ៍នីត្យានុកូលភាព)





# មាតិកា

១.និយមន័យ.......... 82
២.ក្របខ័ណ្ឌច្បាប់ .......... 83
២.១.ច្បាប់អន្តរជាតិ.......... 83
២.២.ច្បាប់ជាតិ .......... 84
៣.សារៈសំខាន់.......... 85
៤.ដែនកំណត់ .......... 85
៥.សំណួរ .......... 87

## ១. និយមន័យ



ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ហាមឃាត់ការអនុវត្តច្បាប់នៅពេលបទល្មើសបានកើតឡើងមុនពេលច្បាប់ចូលជាធរមាន។ ម៉្យាងទៀត ច្បាប់ព្រហ្មទណ្ឌដែលទើបតែចូលជាធរមានត្រឹមតែអនុវត្តទៅលើបទល្មើសណាដែលបានប្រព្រឹត្តបន្ទាប់ពីច្បាប់នោះចូលជាធរមាន និងកំណត់ការប្រព្រឹត្តបែបនោះថាជាបទល្មើស។

ការហាមឃាត់គោលការណ៍នីត្យានុកូលភាព ដែលបង្កើតឡើងដោយទ្រឹស្តីដូចខាងក្រោម៖

- ទ្រឹស្តី គ្មានបទល្មើស គ្មានទោស កាលណាគ្មានច្បាប់ចែង ត្រូវបានបកស្រាយយ៉ាងច្បាស់ថា "គ្មានបទល្មើស កាលណាគ្មានច្បាប់ចែង" បកស្រាយថា ជនណាមិនអាចប្រព្រឹត្តបទល្មើសបានទេ លុះត្រាតែអំពើនោះត្រូវបានហាមឃាត់ដោយច្បាប់ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្តឡើង។[1]
- ទ្រឹស្តី គ្មានបទល្មើស គ្មានទោស កាលណាគ្មានច្បាប់ចែង បកស្រាយយ៉ាងច្បាស់ថា "គ្មានទោស គ្មានច្បាប់ចែង" បកស្រាយថាមានតែការផ្តន្ទាទោស ដែលចែងនៅក្នុងច្បាប់ទេដែលអាចត្រូវបានកាត់ទោសជនណាម្នាក់បាន។ បន្ថែមលើនេះ តុលាការមិនអាចដាក់ទោសដែលធ្ងន់ជាងទោសនៅពេលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលបានចែងនៅក្នុងច្បាប់បានចូលជាធរមានហើយនោះទេ។[2]

គោលការណ៍នីត្យានុកូលភាពមានន័យជារួមថា មានតែច្បាប់ទេដែលអាចផ្តល់និយមន័យបទល្មើស និងចេញបញ្ញាការកាត់ទោស។

ផលវិបាក៖



- មិនមាននរណាម្នាក់ត្រូវបានកាត់ទោស និងអាចរកឃើញថាមានពិរុទ្ធភាពនៃបទលើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយដែលមិនមែនជាបទល្មើសនៅពេលដែលអំពើ ឬការខកខាននោះបានកើតឡើង។



- ប្រសិនបើរកឃើញថាមានពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌ **ជនត្រូវបានកាត់ទោសហើយមិនអាចត្រូវបានដាក់ទោស ដែលមិនមានចែងដោយច្បាប់ និងដែលធ្ងន់ជាងទោសដែលបានចែងដោយច្បាប់នៅពេលបទល្មើសបានប្រព្រឹត្ត។**

មូលដ្ឋានសមស្របនៅពីក្រោយគោលការណ៍នីត្យានុកូលភាព និងការហាមឃាត់ប្រឆាំងនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គឺថាបុគ្គលមិនអាចទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើស សម្រាប់អំពើដែលពួកគេបានប្រព្រឹត្តឡើយ លុះត្រាតែគេរកឃើញហេតុផលថា អំពើនេះជាបទល្មើសនៅពេលដែលច្បាប់កំពុងចូលជាធរមាន។

---

[1] ម.ស.ម.ក "សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ ២០១២) https://sithi.org/km/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook ។

[2] ដូចខាងលើ។

គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យរដ្ឋ **ផ្តល់និយមន័យច្បាស់លាស់ចំពោះបទល្មើសព្រហ្មទណ្ឌ និងការផ្តន្ទាទោសនៅក្នុងច្បាប់** ដើម្បីឱ្យបុគ្គលម្នាក់ៗអាចដឹងអំពីអំពើ និងការខកខាន ដែលពួកគេអាចទទួលខុសត្រូវព្រហ្មទណ្ឌ។[3]



ទោះបីជាយ៉ាងនេះក្តី ការតម្រូវនេះមិនមានន័យថា រដ្ឋត្រូវតែបង្ហាញថា បុគ្គលបានដឹងពីអំពើដែលកំពុងពិចារណា មានភាពខុសច្បាប់ ក្នុងការដាក់ទោសពួកគេចំពោះការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដោយសារតែបញ្ហានេះនឹងដាក់បន្ទុកហួសហេតុលើរដ្ឋ។ រដ្ឋត្រូវតែធានាថា បុគ្គលទទួលបានព័ត៌មាន ដែលអាចឱ្យពួកគេដឹងអំពីអំពើដែលត្រូវបានហាមឃាត់ និងមិនត្រូវបានហាមឃាត់ ជាការកត់សម្គាល់ តាមរយៈការផ្សព្វផ្សាយច្បាប់។[4]

សិទ្ធិនេះក៏មានសារៈសំខាន់ដែលរំលេចថា ការហាមឃាត់ប្រឆាំងនឹងការអនុវត្តសកម្មភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ដែលអនុវត្តទៅលើអំពើជាបទល្មើសព្រហ្មទណ្ឌស្ថិតក្រោម**ច្បាប់ជាតិ និងអន្តរជាតិ**។ នេះមានន័យថា ទោះបីជាច្បាប់ព្រហ្មទណ្ឌជាតិមិនកំណត់អំពើជាក់លាក់ណាមួយថាជាបទល្មើសព្រហ្មទណ្ឌ នៅពេលអំពើទាំងនោះត្រូវបានប្រព្រឹត្ត ប៉ុន្តែច្បាប់ព្រហ្មទណ្ឌអន្តរជាតិកំណត់យ៉ាងច្បាស់ ដូច្នេះអំពើទាំងនេះអាចត្រូវបានកាត់ទោស។ នេះគឺជាឧទាហរណ៍មួយនៅក្នុងសំណុំរឿងនៃបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ល។[5]

# ២. ក្របខ័ណ្ឌច្បាប់

## ២.១. ច្បាប់អន្តរជាតិ

ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌត្រូវបានហាមឃាត់នេះយ៉ាងច្បាស់តាមច្បាប់អន្តរជាតិ រួមមាន**សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ("ស.ស.ស.ម") និង**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ("ក.អ.ស.ព.ន")។ ការហាមឃាត់នេះក៏បានចែងនៅក្នុង**អនុសញ្ញាស្តីពីសិទ្ធិកុមារ** ("អ.ស.ក")ផងដែរ។

**មាត្រា ១១(២) នៃ ស.ស.ស.ម៖**

"គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌដោយបានប្រព្រឹត្ត ឬភ្លាំងភ្លាត់ប្រព្រឹត្ត ដែលអំពើនេះមិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិ។ មិនត្រូវផ្តន្ទាទោសឱ្យធ្ងន់ជាងទោសដែលបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេលបទល្មើសបានកើតឡើងឡើយ។

---

[3] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌" (ការបោះពុម្ពលើកទី២ ឆ្នាំ២០១៤) ជំពូកទី១៨ ទំព័រទី១៣៨ ដល់១៤១ https://sithi.org/km/tmp/publication/view/2014-04-10-fair-trial-manual-published-by-amnesty-international ។

[4] ម.ស.ម.ក "សៀវភៅមគ្គុទេសក៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ" (ខែកុម្ភៈ ឆ្នាំ ២០១២) ទំព័រ ២៨ https://sithi.org/km/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook ។

[5] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ ទំព័រ ១៣៨។

**មាត្រា ១៥ នៃ ក.អ.ស.ព.ន៖**

"គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុនជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងមុន។ គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើឬការខកខាននោះជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ។"

**មាត្រា ៤០ (២)(ក) នៃ អ.ស.ក៖**

*"[...] ២. ក្នុងទិសដៅនេះ និងដោយគិតទៅនឹងបទប្បញ្ញត្តិនៃលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធរដ្ឋភាគីត្រូវធានា ជាពិសេសថា៖*

*(ក). គ្មានកុមារណាម្នាក់ ត្រូវជាប់សង្ស័យ ជាប់ចោទ ឬទទួលស្គាល់ថាបានល្មើសនឹងច្បាប់ព្រហ្មទណ្ឌដោយអំពើ ឬការខកខានដែលច្បាប់ជាតិឬអន្តរជាតិ មិនបានហាមឃាត់នៅពេលអំពើ ឬការខកខាននោះត្រូវបានប្រព្រឹត្ត [...]។"*

## ២.២. ច្បាប់ជាតិ

ការហាមឃាត់ប្រឆាំងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌត្រូវបានធានាតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") នៅមាត្រា ៣, ៩ និង ១០។

**មាត្រា ៣៖** "មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះ មានចែងនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបផ្តន្ទាទោសព្រហ្មទណ្ឌបាន។."

**មាត្រា ៩៖** "បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម។ អំពើដែលប្រព្រឹត្តិនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តិទៅនោះត្រូវបញ្ចប់។ ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត។

មាត្រា ១០៖ "បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។ ប៉ុន្តែការផ្តន្ទាទោសជាស្ថាពរហើយនោះ ត្រូវអនុវត្តទោះបីជាទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាងនឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ។"

## ៣. សារៈសំខាន់



ការហាមឃាត់ប្រឆាំងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌគឺសំខាន់ ដោយសារតែការហាមឃាត់នេះពង្រឹងគោលការណ៍មួយក្នុងចំណោមគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ព្រហ្មទណ្ឌ៖ គោលការណ៍នីត្យានុកូលភាព ដែលតម្រូវថា បទល្មើសព្រហ្មទណ្ឌត្រូវបានបញ្ញត្តិដោយ ច្បាប់។ គោលការណ៍នេះជាសសរស្តម្ភនៃ**នីតិរដ្ឋ។**

តាមរយៈការផ្តល់នូវក្របខណ្ឌសម្រាប់ការអនុវត្តនៃអំណាចតុលាការ ការហាមឃាត់ប្រឆាំងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌការពារបុគ្គល**ប្រឆាំងនឹងការរំលោភបំពានដោយរដ្ឋ** ជាការកត់សម្គាល់**ប្រឆាំងនឹងការកាត់ទោស ការដាក់ទោស និងទណ្ឌកម្មតាមអំពើចិត្ត និងមិនស្របច្បាប់**[6] ហើយដូច្នេះ ធានាថា **ភាពយុត្តិធម៌នៃអាជ្ញាធរតុលាការ** និង**ភាពប៉ាន់ប្រមាណជាមុនដោយច្បាប់**។[7] ដោយការយល់ដឹងថា អំពើ និងការខកខានអាចធ្វើឱ្យពួកគេទទួលខុសត្រូវព្រហ្មទណ្ឌ និងទោស ដែលពួកគេប្រឈម ព្រមទាំងនៅពេលដែលអំពើ ឬការខកខានបែបនេះចាប់ផ្តើម ឬបញ្ឈប់ការត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ បុគ្គលអាចសម្របឥរិយាបថរបស់ពួកគេស្របតាមច្បាប់។

ហេតុដូចនេះ ការរំលោភបំពានលើការហាមឃាត់នេះជាការគំរាមកំហែងដល់ភាពយុត្តិធម៌ ដែលបុគ្គលត្រូវបានប្រព្រឹត្តមកលើដោយតុលាការ និងអាចឈានទៅដល់ការរំលោភបំពាន ជាពិសេសការកាត់ទោស ការដាក់ទោស និងទណ្ឌកម្មមិនស្របច្បាប់ទៅលើបុគ្គលចំពោះអំពើ ឬការខកខាន ដែលមិនចាត់ជាបទល្មើសព្រហ្មទណ្ឌនៅពេលដែលអំពើ ឬការខកខានទាំងនោះត្រូវបានប្រព្រឹត្ត។

## ៤. ដែនកំណត់



មាត្រា១៥ នៃ ក.ស.អ.ព.ន ដែលធានាការហាមឃាត់ប្រឆាំងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គឺនៅក្នុងបញ្ជីដែលបានពិនិត្យជិតដល់ មានចែងនៅមាត្រា ៤ នៃ ក.អ.ស.ព.ន អំពីសិទ្ធិ និងគោលការណ៍ ដែលមិនអាចត្រូវបានដកហូតនៅអំឡុងពេលរដ្ឋនៅក្នុងភាពអាសន្ន។



ទោះបីជាយ៉ាងនេះក្តី ច្បាប់អន្តរជាតិកំណត់ករណីលើកលែង ដោយចែងថាបទប្បញ្ញត្តិណាមួយដែលដាក់ទោសស្រាលជាងត្រូវតែផ្តល់ជាប្រយោជន៍ដល់ជនល្មើស។ ហេតុដូច្នេះ ការអនុវត្តប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌត្រូវបានអនុញ្ញាតចំពោះច្បាប់ព្រហ្មទណ្ឌមានភាពអត់ឱន ដែលជាប្រយោជន៍ដល់ជនជាប់ចោទ។ នេះមានន័យថា

---

[6] អង្គការលើកលែងទោសអន្តរជាតិ សៀវភៅណែនាំអំពីការជំនុំជម្រះដោយយុត្តិធម៌ ទំព័រ ១៣៩។

[7] អ.ស.ស.អ, "សេចក្តីសង្ខេបស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ", (២០១២) ទំព័រទី១៨៥-១៨៦ https://www.osce.org/odihr/94214#:~:text=The%20Legal%20Digest%20of%20International,of%20OSCE%20trial%20monitoring%20operations។

ប្រសិនបើច្បាប់ព្រហ្មទណ្ឌផ្លាស់ប្តូរបន្ទាប់ពីពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ប៉ុន្តែមុនពេលដែលសេចក្តីសម្រេចស្ថាពរត្រូវបានចេញ ដូចនេះតុលាការត្រូវតែអនុវត្តច្បាប់ព្រហ្មទណ្ឌដែលអនុគ្រោះបំផុតដល់ជនជាប់ចោទ។[8]



ដូចគ្នានេះដែរ បុគ្គលអាចលែងត្រូវបានកាត់ទោសចំពោះអំពើ ដែលចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនៅពេលប្រព្រឹត្ត ប៉ុន្តែអំពើនោះត្រូវបានកំណត់ថាលែងជាបទល្មើសព្រហ្មទណ្ឌនៅមុនពេលដែលបុគ្គលនោះត្រូវបានកាត់ទោសជាស្ថាពរ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានបញ្ជាក់យ៉ាងច្បាស់ថា មាត្រា ១៥(១) នៃ ក.អ.ស.ព.ន ចែងអំពីការហាមឃាត់ប្រឆាំងការអនុវត្តអានុភាពប្រតិសកម្មនៃទោសដែលស្រាលជាង និងថាវិសាលភាពនៃមាត្រានេះមិនត្រូវបានបកស្រាយចង្អៀតនោះទេ។ អាស្រ័យហេតុនេះ ការហាមឃាត់ប្រឆាំងការអនុវត្តអានុភាពប្រតិសកម្មទៅលើច្បាប់ដែលបានលុបចោលទោសចំពោះអំពើ ដែលលែងកំណត់ថាជាបទល្មើស។[9]



បន្ថែមលើនេះ ការហាមឃាត់ប្រឆាំងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌត្រឹមតែអនុវត្តចំពោះការផ្លាស់ប្តូរច្បាប់ ដែលមានឥទ្ធិពលលើការកំណត់បទល្មើសនៃអំពើណាមួយ ហើយមិនចំពោះការផ្លាស់ប្តូរនីតិវិធី ឬវិធានភស្តុតាង ដែលមិនប៉ះពាល់ដល់ លក្ខណៈនៃបទល្មើសឡើយ។[10]

---

[8] ដូចខាងលើ ទំព័រ១៣៩។

[9] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "Jean-Pierre Cochet ទល់នឹងប្រទេសបារាំង៖ ទំនាក់ទំនង លេខ១៧៦០/២០០៨ " (ឯកសារអង្គការសហប្រជាជាតិ ស្ថាប័នសិទ្ធិពលរដ្ឋ និងនយោបាយ/គ/១០០/ឃ/១៧៦០/២០០៨,២០១០) កថាខណ្ឌ ៧.២ ដល់ ៧.១០ , http://hrlibrary.umn.edu/undocs/1760-2008.html ។

[10] អ.ស.ស.អ, "សេចក្តីសង្ខេបស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ" ផ្នែកទី៨.១.៣ ទំព័រទី១៨៨; សូមមើលគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "David Nicholas ទល់នឹងប្រទេសអូស្ត្រាលី៖ ទំនាក់ទំនង លេខ១០៨០/២០០២" (ឯកសារអង្គការសហប្រជាជាតិ ស្ថាប័នសិទ្ធិពលរដ្ឋ និងនយោបាយ/គ/១/៨០/១០៨០/២០០២ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤) កថាខណ្ឌ ៧.៧ http://www.worldcourts.com/hrc/eng/decisions/2004.03.19_Nicholas_v_Australia.htm ។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ សំដៅដល់ការហាមឃាត់ការអនុវត្តច្បាប់នៅពេលបទល្មើសបានកើតឡើងមុនពេលច្បាប់ចូលជាធរមាន។

☐ក. ត្រូវ ☐ខ. ខុស

២. តើគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ព្រហ្មទណ្ឌណាមួយ ដែលបញ្ជាក់ពីការហាមឃាត់អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ?

☐ក. គោលការណ៍នីត្យានុកូលភាព ☐ខ. គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់

☐គ. គោលការណ៍បែងចែកអំណាចដាច់ពីគ្នា ☐ឃ.មិនមែនទាំងអស់ខាងលើ

៣. តើច្បាប់ជាតិមួយណាដែលមានចែងអំពីការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្ម (ការអនុវត្តច្បាប់ថយក្រោយ) នៃច្បាប់ព្រហ្មទណ្ឌដែលជាគោលការណ៍សកល?

☐ក. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ☐ខ.ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា

☐គ. ក្រមព្រហ្មទណ្ឌកម្ពុជា ☐ឃ. មិនត្រឹមត្រូវទាំងអស់

៤. ក្នុងករណីបុគ្គលម្នាក់ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចំនួន ៦ឆ្នាំ តែសេចក្តីសម្រេចរបស់តុលាការមិនទាន់បានចូលជាស្ថាពរនៅឡើយ បន្ទាប់មកមានច្បាប់មួយទៀតចូលជាធរមាន ត្រូវផ្តន្ទាទោសត្រឹមតែ ៤ឆ្នាំសម្រាប់បទល្មើសដដែល។ តើច្បាប់ដែលចូលជាធរមានក្រោយនេះ អាចត្រូវយកមកអនុវត្តបានដែរ ឬទេ?

☐ក. បាន ☐ខ. មិនបាន

៥. ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានសារៈសំខាន់ណាស់ ដោយសារតែការហាមឃាត់នេះពង្រឹងគោលការណ៍មួយក្នុងចំណោមគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ព្រហ្មទណ្ឌ គឺការពារបុគ្គលពីការរំលោភបំពានដោយរដ្ឋប្រឆាំងនឹងការចោទប្រកាន់ ការដាក់ទោស និងទណ្ឌកម្មដែលធ្វើតាមអំពើចិត្ត និងមិនស្របច្បាប់ និងធានានូវភាពត្រឹមត្រូវរបស់អាជ្ញាធរតុលាការ ព្រមទាំងភាពប៉ាន់ប្រមាណនៃច្បាប់។

☐ក. ត្រូវ ☐ខ. ខុស

៦. បុគ្គលមួយអាចមិនត្រូវបានចោទប្រកាន់ទេ ចំពោះអំពើមួយដែលកំណត់ថាជាបទល្មើសព្រហ្មទណ្ឌនៅពេលដែលបុគ្គលនោះបានប្រព្រឹត្ត ប៉ុន្តែក្រោយមកអំពើនោះត្រូវបានចាត់ទុកថាលែងជាបទល្មើសព្រហ្មទណ្ឌទៀតហើយ នៅមុនពេលដែលបុគ្គលនោះត្រូវបានកាត់ទោសជាស្ថាពរ។

☐ក. ត្រូវ ☐ខ. ខុស

៧. តើបុគ្គលម្នាក់អាចត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិដែរឬទេ? ខណៈដែលបទល្មើសនោះមិនមានចែងក្នុងជាតិរបស់ខ្លួនទេ?

☐ក. បាន ☐ខ. មិនបាន

# ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល



# មាតិកា


១. និយមន័យ ........................................ 88
២. ក្របខ័ណ្ឌច្បាប់ ........................................ 88
 ២.១. ច្បាប់អន្តរជាតិ ........................................ 88
 ២.២. ច្បាប់ជាតិ ........................................ 89
៣.សារៈសំខាន់ ........................................ 89
៤. ដែនកំណត់ ........................................ 90
៥. សំណួរ ........................................ 91

## ១. និយមន័យ

ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល គឺដើម្បីការពារបុគ្គលពីការកាត់ទោសពីរដងចំពោះអំពើដដែល។

ការហាមឃាត់នេះរួមបញ្ចូលនូវគោលការណ៍ ***ការមិនចោទប្រកាន់ត្រួតគ្នា*** ដែលសំដៅ "*មិនចោទប្រកាន់ពីរដងចំពោះអំពើដដែល*" និងធានាបុគ្គលណាមួយនូវសិទ្ធិរួចផុតពីការជំនុំជម្រះ ឬការដាក់ទណ្ឌកម្មចំពោះបទល្មើស ដែលពួកគេត្រូវបានកាត់ទោស ឬរួចផុតពីទោសចូលជាស្ថាពររួចហើយ តាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌនៃប្រទេសនីមួយៗ។[1]



គោលការណ៍នៃការមិនចោទប្រកាន់ត្រួតគ្នា ពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងទ្រឹស្តី ***អាជ្ញាអស់ជំនុំ*** ឬថា "***បានវិនិច្ឆ័យរួចហើយ***" និងមានន័យថា ការវិនិច្ឆ័យជាស្ថាពរដោយតុលាការ ឬស្ថាប័នមានសមត្ថកិច្ច ដាច់ស្រេចហើយ។ នីតិវិធីថ្មីជាប់ពាក់ព័ន្ធនឹងគោលបំណងដូចគ្នា មូលដ្ឋានច្បាប់ដូចគ្នា និងភាគីដូចគ្នាមិនអាចដំណើរការបានឡើយ។[2] ដូច្នេះ ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែលនេះអនុវត្តនៅត្រឹមពេលដែលមាន**សេចក្តីសម្រេចចូលជាស្ថាពរ** ឬម្យ៉ាងទៀត នៅពេលដែលបណ្តឹងជំទាស់ទៅតុលាការជាន់ខ្ពស់អស់ចុងក្រោយ។

បន្ថែមលើនេះ ការហាមឃាត់នេះអនុវត្តចំពោះ**បទល្មើសព្រហ្មទណ្ឌ និងមិនត្រឹមតែចំពោះតុលាការដែលកាត់ក្តីលើសំណុំរឿងនៅសាលាដំបូងប៉ុណ្ណោះទេ ប៉ុន្តែចំពោះសាលាក្តីដទៃទៀតផងដែរ**។ ឧទាហរណ៍ បុគ្គលដែលរួចផុតទោសដោយតុលាការស៊ីវិល មិនអាចត្រូវបានកាត់ទោសម្តងទៀតចំពោះអំពើដដែលដោយតុលាការយោធា ឬតុលាការពិសេស។[3]

## ២. ក្របខ័ណ្ឌច្បាប់

### ២.១. ច្បាប់អន្តរជាតិ

ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែលត្រូវបានការពារក្រោម**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")** ដែលអនុវត្តផ្ទាល់នៅក្នុងច្បាប់ប្រទេសកម្ពុជានៅក្នុងមាត្រា ៣១ នៃ រដ្ឋធម្មនុញ្ញកម្ពុជា។



មាត្រា ១៤(៧) នៃ ក.អ.ស.ព.ន៖

*"គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ។"*

---

[1] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ៣២ -មាត្រា១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌, (CPPR/C/GC/32, ២៣ ខែសីហា ឆ្នាំ២០០៧), កថាខណ្ឌ ៣ និង៥៤, https://www.refworld.org/docid/478b2b2f2.html(គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ,សេចក្តីពន្យល់ទូទៅលេខ៣ ។

[2] Victor Barin Chaharbakhsh and Seyed Asgher Jafari, "គោលការណ៍នៃអាជ្ញាអស់ជំនុំនៅក្នុងច្បាប់អន្តរជាតិ" វ៉ុល៧ លេខ៨ ទិន្នានុប្បវត្តិនៃការត្រួតពិនិត្យសំខាន់, ឆ្នាំ២០២០។

[3] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ៣២, កថាខណ្ឌ ៥៤។

## ២.២. ច្បាប់ជាតិ

ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែលនេះក៏ត្រូវបានបញ្ចូលនៅក្នុងច្បាប់កម្ពុជាតាម **ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") និង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ")**។

មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ *"ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែលទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។"*



ក្រមព្រហ្មទណ្ឌ មាត្រា ២៣៖ *"ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តិប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវជំនុំជម្រះជាស្ថាពរនៅឯបរទេស ចំពោះអំពើដដែល ហើយក្នុងករណីដែលមានផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល។"*

## ៣.សារៈសំខាន់

ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែលផ្តល់ឱ្យមាន**ការការពាររបស់តុលាការសម្រាប់បុគ្គលប្រឆាំងនឹងការរំលោភបំពានរបស់រដ្ឋ**។ ការហាមឃាត់នេះរក្សាគោលការណ៍**អាជ្ញាអស់ជំនុំ** ដែលឱ្យការបញ្ចប់ និងភាពពេញលេញទៅដល់នីតិវិធីព្រហ្មទណ្ឌ។[4] ការបញ្ចប់នៃសេចក្តីសម្រេចបង្ការបុគ្គលពីការរស់នៅក្នុងភាពភ័យខ្លាចដែលពួកគេអាចប្រឈមនឹងការគំរាមជាប់មិនដាច់នៃការធ្វើទុក្ខបុកម្នេញ និងការរុកកួនតាមរយៈការស៊ើបអង្កេត និងការកាត់ទោសម្តងហើយម្តងទៀតដោយតុលាការចំពោះអង្គហេតុដដែល។



ការហាមឃាត់នេះការពារគោលការណ៍នៃ**ភាពច្បាស់លាស់នៃច្បាប់** ដែលពង្រឹងនូវប្រព័ន្ធយុត្តិធម៌។ ការហាមឃាត់នេះក៏ចៀសវាង**ការខ្ជះខ្ជាយធនធានច្បាប់សំខាន់**[5] ដោយរារាំងនីតិវិធីជាច្រើនដោយតុលាការដដែល ឬផ្សេងគ្នាចំពោះបទល្មើសព្រហ្មទណ្ឌដដែល។

ដូចនេះ ការហាមឃាត់នេះជាគោលការណ៍ដែលសំខាន់ចំពោះ**ការគ្រប់គ្រងយុត្តិធម៌ដ៏សមស្រប និង ជៀសវាងការខុសឆ្គងក្នុងការជម្រះក្តីដោយភាន់ច្រឡំនៃតុលាការ**។

---

[4] អ.ស.ស.អ, "សេចក្តីសង្ខេបស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ", (ឆ្នាំ២០១២), ផ្នែក៨.៤, ទំព័រទី១៩៧-១៩៨, https://www.osce.org/odihr/94214#:~:text=The%20Legal%20Digest%20of%20International,of%20OSCE%20trial%20monitoring%20operations ។

[5] ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍៖ របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៨-ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០" (ខែតុលា ឆ្នាំ២០២០), ទំព័រ ២៦។

## ៤. ដែនកំណត់

ការហាមឃាត់នៃការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល អាចជាកម្មវត្ថុនៃដែនកំណត់មួយចំនួន ដែលអាចខុសគ្នារវាងយុត្តាធិការអន្តរជាតិ និងតំបន់។

សម្រាប់ **គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ** ដែលត្រួតពិនិត្យលើការអនុវត្តនៃ ក.អ.ស.ព.ន ការហាមឃាត់មិនឱ្យ៖

១. ហាមឃាត់ការកាត់ទោសឡើងវិញលើជនដែលត្រូវបានកាត់ទោសហើយ ក្នុងការអនុប្បវាទចំពោះអ្នកដែលស្នើសុំការកាត់ទោសឡើងវិញ។

២. ហាមឃាត់ការកាត់ទោសបុគ្គលឡើងវិញ បន្ទាប់ពីសាលាជម្រះក្តីជាន់ខ្ពស់បដិសេធការកាត់ទោសចោល។

៣. ហាមឃាត់ការចាប់ផ្តើមការជំនុំជម្រះបទល្មើសព្រហ្មទណ្ឌឡើងវិញ ប្រសិនបើត្រូវបានកែតម្រូវដោយ "*កាលៈទេសៈពិសេស*" ដូចជាការរកឃើញភស្តុតាងថ្មី។



៤. ធានាថាបុគ្គលនឹងមិនត្រូវបានជំនុំជម្រះពីបទល្មើសព្រហ្មទណ្ឌដែលគោរពតាមយុត្តាធិការជាតិនៃរដ្ឋពីរ ឬច្រើនជាងនេះ។ ប៉ុន្តែរដ្ឋត្រូវបានជំរុញក្នុងការបង្ការការជំនុំជម្រះឡើងវិញសម្រាប់អំពើដដែលតាមរយៈកតិកាសញ្ញាអន្តរជាតិ[6] និង

៥. ការពារពីវិធានការវិន័យដទៃទៀត ដែលមិនសមាមាត្រនឹងទណ្ឌកម្មព្រហ្មទណ្ឌសម្រាប់បទល្មើសដដែល។ ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែលអនុវត្តទៅលើបទល្មើសព្រហ្មទណ្ឌតែមួយគត់[7] មានន័យថាការហាមឃាត់នេះមិនអនុវត្តចំពោះនីតិវិធីរដ្ឋបាល ឬរដ្ឋប្បវេណីឡើយ។

បន្ថែមលើនេះ **អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា ("អ.វ.ត.ក")** បានបញ្ជាក់ថា គោលការណ៍ **មិនចោទប្រកាន់ទោសពីរដង** មិនហាមឃាត់ការកាត់ទោសសម្រាប់បទល្មើសព្រហ្មទណ្ឌអន្តរជាតិ ដូចជាបទល្មើសប្រឆាំងមនុស្សជាតិ។[8]

---

[6] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ៣២, កថាខណ្ឌ ៥៧។

[7] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ៣២, កថាខណ្ឌ ៥៤-៥៧។

[8] ការិយាល័យឧត្តមស្នងការ, "សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖ សេចក្តីពន្យល់របស់ អ.វ.ត.ក និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមួយចំនួន", បោះពុម្ពលើកទី២ (ខែធ្នូ ឆ្នាំ២០១៥), មាត្រា១២៖ អាជ្ញាអស់ជំនុំទំព័រទី៧, យោងទៅលើ អ.វ.ត.ក, អ.ជ.ស.ជ, "សេចក្តីសម្រេចលេខ៨៩របស់អៀង សារី លើការជំទាស់បឋម," (ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១), កថាខណ្ឌ ៣៣ ទៅដល់ ៣៦, https://cambodia.ohchr.org/~cambodiaohchr/sites/default/files/Annotated%20Cambodian%20Code%20of%20Criminal%20Procedure%20%5BKH%5D%20%5BMaster%20-%20Fiinal%5D.pdf ។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល សំដៅដល់គោលការណ៍មិនចោទប្រកាន់ពីរដងចំពោះអំពើដដែល និងធានានូវសិទ្ធិរបស់បុគ្គលក្នុងការរួចផុតពីការជំនុំជម្រះ ឬការដាក់ទណ្ឌកម្មចំពោះបទល្មើសដែលពួកគេត្រូវបានកាត់ទោស ឬរួចផុតពីទោសដែលសេចក្ដីសម្រេចបានចូលជាស្ថាពររួចហើយស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌនៃប្រទេសនីមួយៗ។

□ក. ត្រូវ □ខ. ខុស

២. ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល មានសារៈសំខាន់ដូចជា៖

□ក. ការពារគោលការណ៍នីត្យានុកូលភាពដើម្បីពង្រឹងនូវប្រព័ន្ធយុត្តិធម៌

□ខ. ចៀសវាងការខ្ជះខ្ជាយធនធាន និងការជម្រះក្ដីដោយភាន់ច្រឡំ

□គ. ការពារនូវគោលការណ៍អាជ្ញាអស់ជំនុំដែលផ្ដល់ឱ្យនូវភាពពេញលេញ និងសុចរិតភាពនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ □ឃ. ក, ខ និង គ

៣. ប្រសិនបើតុលាការសម្រេចឱ្យបុគ្គលម្នាក់រួចផុតពីបទចោទ និងសេចក្ដីសម្រេចបានចូលជាស្ថាពររួចហើយ ក្រោយមកតើតុលាការអាចកាត់ក្ដីឡើងវិញលើអង្គហេតុ មូលដ្ឋានច្បាប់ និងភាគីពាក់ព័ន្ធដដែលនោះបានដែរឬទេ?

□ក. បាន □ខ. មិនបាន

៤. ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះអំពើដដែល គឺអាចអនុវត្តបានតែនៅពេលដែលសេចក្ដីសម្រេចចូលជាស្ថាពរតែប៉ុណ្ណោះ។

□ក. ត្រូវ □ខ. ខុស

៥. តើច្បាប់ជាតិណាមួយដែលចែងថា "ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ម្ដងទៀតទេចំពោះអំពើដដែល ទោះបីក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ"?

□ក. ក្រមព្រហ្មទណ្ឌកម្ពុជា □ខ. ក្រមរដ្ឋប្បវេណីកម្ពុជា

□គ. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា □ឃ. មិនមានទាំងអស់

៦. តើច្បាប់ជាតិ និងអន្តរជាតិណាខ្លះដែលធានាចំពោះការហាមឃាត់ប្រឆាំងនឹងការកាត់ទោសពីរដងចំពោះអំពើដដែល?

□ក. កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ □ខ. ក្រមព្រហ្មទណ្ឌប្រទេសកម្ពុជា

□គ. ក្រមនីតិវិធីព្រហ្មទណ្ឌ □ឃ. ចម្លើយ ក និង គ

៧. អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា("អ.វ.ត.ក") បានបញ្ជាក់ថាគោលការណ៍មិនចោទប្រកាន់ពីរដងចំពោះអំពើដដែល មិនហាមឃាត់ការកាត់ទោសសម្រាប់បទល្មើសព្រហ្មទណ្ឌអន្តរជាតិទេ ដូចជាបទល្មើសប្រឆាំងមនុស្សជាតិ។

□ក. បាន □ខ. មិនបាន

# សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់











# មាតិកា

១និយមន័យ ........................................................................................................ 92
២ក្របខ័ណ្ឌច្បាប់ ................................................................................................... 97
  ២ .១.ច្បាប់អន្តរជាតិ .............................................................................................. 97
  ២ច្បាប់ជាតិ .២. ................................................................................................. 100
៣សារៈសំខាន់ ...................................................................................................... 101
៤ដែនកំណត់ ........................................................................................................ 101
៥សំណួរ ............................................................................................................. 102

## ១. និយមន័យ

**កុមារ** គឺត្រូវបានកំណត់និយមន័យជាអន្តរជាតិថាជាមនុស្សដែលមាន**អាយុក្រោម ១៨ ឆ្នាំ**។[1] នៅក្នុង**ដំណើរការនីតិវិធីព្រហ្មទណ្ឌ** កុមារដែលជាប់ចោទពីបទល្មើស គឺមានសិទ្ធិទទួលបាន**ការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់ដូចគ្នា ទៅនឹងនីតិជនដែរ**។[2] ប៉ុន្តែកុមារក៏ត្រូវការ**ការការពារ**[3] និង**ការថែទាំពិសេស** ដែលស្របទៅតាមអាយុ ភាពចាស់ទុំ ព្រមទាំងការអភិវឌ្ឍផ្នែកបញ្ញា និងអារម្មណ៍របស់ពួកគេផងដែរ។



ចំណុចនេះបកស្រាយដោយភាពចាំបាច់ពិសេសសម្រាប់អាជ្ញាធរក្នុងប្រទេសក្នុងការៈ [4]

- ការពារការសន្មតទុកជាមុនថាគ្មានទោសរបស់កុមារទំនាស់ច្បាប់តាមរយៈដំណើរការនីតិវិធីព្រហ្មទណ្ឌដោយផ្តល់ **ព័ត៌មានអំពីការអភិវឌ្ឍរបស់កុមារទៅកាន់អាជ្ញាធរ និងតួអង្គពាក់ព័ន្ធ**។ ចំណុចនេះមានសារៈសំខាន់ ដោយសារតែកុមារអាចប្រព្រឹត្តឥរិយាបថដែលមានលក្ខណៈសង្ស័យដោយសារតែខ្វះការយល់ដឹងអំពីនីតិវិធី ភាពនៅក្មេងខ្ចី ការភ័យខ្លាច ឬមូលហេតុផ្សេងៗទៀត។[5]



[1] មាត្រា ១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក)។

[2] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ ៣២-មាត្រា១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ,(CPPR/C/GC/32 (២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ៤២, https://www.refworld.org/docid/478b2b2f2.html។

[3] ដូចខាងលើ កថាខណ្ឌ ៤២។

[4] មាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក); គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៤២។

[5] គណៈកម្មាធិការសិទ្ធិកុមារ "សេចក្តីពន្យល់ទូទៅលេខ ២៤ ប្តូរសេចក្តីពន្យល់លេខ ១០ (ឆ្នាំ២០០៧)៖ សិទ្ធិកុមារនៅក្នុងយុត្តិធម៌កុមារ" CRC/C/GC/១០ (ឆ្នាំ២០០៧) កថាខណ្ឌ ៥៣, https://www2.ohchr.org/english/bodies/crc/docs/CRC.C.GC.10.pdf។

- ជូនដំណឹងដល់កុមារដោយផ្ទាល់ និងការចោទប្រកាន់ឱ្យបានឆាប់តាមតែអាចធ្វើបាន និងប្រាប់អំពីជំហាននីតិវិធីនីមួយៗ បើអាច ត្រូវជូនដំណឹងទៅកាន់អាណាព្យាបាល ឬឪពុកម្ដាយ។ ព័ត៌មានដែលពាក់ព័ន្ធត្រូវតែបង្ហាញតាមរយៈ**ភាសាដែលពួកគេអាចយល់ និងពាក្យពេចន៍ដែលសមស្របជាមួយអាយុ និងភាពក្មេងខ្ចីរបស់ពួកគេ** ឧទាហរណ៍ប្រើប្រាស់ពាក្យធម្មតា ជាជាងប្រើប្រាស់ភាសាអ្នកវិជ្ជាជីវៈច្បាប់។



- *ផ្ដល់ជូនកុមារទំនាស់នឹងច្បាប់នូវ**ជំនួយឥតគិតថ្លៃ និងគ្រប់គ្រាន់**នៅក្នុងការរៀបចំការពារក្ដីរបស់ពួកគេ។ កុមារក៏ត្រូវ**ផ្ដល់នូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការពារក្ដី** និងការសម្ងាត់នៃទំនាក់ទំនងជាមួយមេធាវីរបស់ពួកគេត្រូវតែធានានូវការការពារឯកជនភាព ។*[6]



- *នាំកុមារទំនាស់នឹងច្បាប់មកចំពោះមុខអាជ្ញាធរ ឬស្ថាប័នតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងដោយ "**មិនមានការពន្យារពេល**"។* នេះមានន័យថា ការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌នៃបទល្មើសព្រហ្មទណ្ឌទៅលើជនដែលប្រព្រឹត្តបទល្មើសជាកុមារត្រូវផ្ដល់**ឱ្យឆាប់រហ័ស ជាជាងផ្ដល់ឱ្យនីតិជន** ជាពិសេសនៅពេលដែលកុមារត្រូវបានដកហូតសេរីភាពដែលជាការគោរពនូវសិទ្ធិរបស់ពួកគេ។ សិទ្ធិនេះមានភាពដាច់ខាតក្នុងការធានានូវភាព**វិជ្ជមានផលប៉ះពាល់ទៅលើការបង្រៀន និងការបង្ការនូវការម៉ាកងាយ**ទៅលើកុមារទំនាស់ច្បាប់។ វត្តមានឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេនៅក្នុងដំណើរការនីតិវិធីគឺជាគោលការណ៍មូលដ្ឋានដែលផ្ដល់ឱ្យជំនួយទៅលើ**ជំនួយផ្នែកផ្លូវចិត្ត និងអារម្មណ៍ទៅដល់កុមារ** និងធានា**ការឆ្លើយតបដែលមានប្រសិទ្ធិភាព**ទៅដល់បទល្មើសព្រហ្មទណ្ឌរបស់កុមារ។ ឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់ត្រូវធានាថាពួកគេត្រូវតែបានទទួលដំណឹងយ៉ាងលឿនតាមដែលអាចធ្វើទៅបានអំពីស្ថានភាពរបស់ កុមារ។[7]



[6] ដូចខាងលើ កថាខណ្ឌ ៤៩ និង ៥០។

[7] ដូចខាងលើ កថាខណ្ឌ ៥១ ដល់ ៥៥។

- ការពារសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យផ្តល់សក្ខីកម្ម ឬសារភាពពីពិរុទ្ធភាព របស់កុមារទំនាស់នឹងច្បាប់។ ដូចនីតិជនដែរ កុមារត្រូវការការពារ**ប្រឆាំងនឹងអំពើទារុណកម្ម អមនុស្សធម៌ ឬការបន្ទាបបន្ថោកដើម្បី**ទទួលបាននូវការសារភាព និងបញ្ចុះបញ្ចូល។[8] ការបញ្ចុះបញ្ចូលកុមារដើម្បីទទួលបានចម្លើយសារភាពមានងាយស្រួលតាមរយៈការបន្ថយអំពើហិង្សា ការប្រើប្រាស់ពាក្យ“**បង្ខិតបង្ខំ**”**ត្រូវតែបកស្រាយក្នុងន័យទូលាយជាងនីតិជន** និងមិនកំណត់ត្រឹមការប្រើប្រាស់កម្លាំងបង្ខិតបង្ខំ ឬសភាពផ្សេងៗនៃការរំលោភបំពានសិទ្ធិមនុស្ស។ សិទ្ធនេះមានលក្ខណៈដាច់ខាតដែលកុមារត្រូវតែ**មានជំនួយពីក្រុមប្រឹក្សាផ្នែកច្បាប់ ឬមេធាវីត្រឹមត្រូវនៅពេលសួរចម្លើយ** និងត្រូវអនុញ្ញាតឱ្យមាន**វត្តមានអាណាព្យាបាលរបស់ពួកគេនៅពេលសួរចម្លើយ**។



- គោរពគោលការណ៍ស្មើភាពគ្នាចំពោះច្បាប់ដោយអនុញ្ញាតិឱ្យកុមារទំនាស់នឹងច្បាប់កោះហៅ និងសាកសួរសាក្សី។ រដ្ឋត្រូវតែបង្កើតនូវនីតិវិធីសម្រួលដល់ជនជាប់ចោទជាកុមារបាន**យល់ និងចូលរួម** រួមមានការបង្ហាញនីតិវិធីក្នុងបន្ទប់សវនាការ និងការអនុវត្តស្របតាមអាយុ និងភាពក្មេងខ្ចីរបស់ពួកគេបើចាំបាច់។[9]



- ធានាថាឯកជនភាពរបស់ពួកគេ ត្រូវបានគោរព គ្រប់ដំណាក់កាលនៃនីតិវិធីដើម្បីជៀសវាងគ្រោះថ្នាក់បណ្តាលមកពីការផ្សព្វផ្សាយជា**សាធារណៈ ឬក៏ដាក់ស្លាកសញ្ញា**។ អាជ្ញាធរមិនត្រូវបង្ហាញពត៌មានណាដែលអាចនាំឱ្យបង្ហាញអត្តសញ្ញាណរបស់កុមារទំនាស់នឹងច្បាប់ ដើម្បីបង្ការការមើលងាយ និងផលប៉ះពាល់ដែលអាចកើតមានឡើងដូចជា ការចែកផ្សាយពត៌មានដែលអាចពួកគេមានសមត្ថភាពក្នុងទទួលបានចំណេះដឹងការងារ និងទីលំនៅ ឬក៏ទីសុវត្ថិភាពរបស់ពួកគេ។ សវនាការកុមារ ត្រូវធ្វើឡើងជា**អសាធារណៈដែលជាវិធានទូទៅ** និងជាសាធារណៈក្នុងករណីលើកលែង មានន័យថាការធ្វើឡើងជាសាធារណៈនេះ ក្នុងករណីពិសេស និងសំណុំរឿងមានកំរិតដែលកំណត់ដោយច្បាប់ និងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយតុលាការ។ សេចក្តីសម្រេចត្រូវតែប្រកាសជាសាធារណៈ ប៉ុន្តែក្នុងវិធីដែល**មិនបង្ហាញអត្តសញ្ញាណរបស់ពួកគេ**។[10]



---

[8] មាត្រា ៣៧(គ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក)។

[9] គណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ១០ កថាខណ្ឌ ៤៩។

[10] ដូចខាងលើ កថាខណ្ឌ ៦៤ ទៅដល់ ៦៧។

- **គោរពសិទ្ធិទទួលបានសវនាការរបស់កុមារនៅគ្រប់នីតិវិធី**[11] មិនមែនត្រឹមតែតាមរយៈមេធាវីរបស់ពួកគេ ឬក៏អង្គភាពសមស្រប ប្រសិនបើវាជាឧត្តមប្រយោជន៍ និងយោងតាមអាយុ និងភាពក្មេងខ្ចីរបស់ពួកគេ។ ការអនុវត្តនេះផ្តល់ឱ្យនូវព័ត៌មានគ្រប់គ្រាន់ដល់កុមារអំពីបទចោទ និងដំណើរការយុត្តិធម៌កុមារ និងវិធានការដែលអាចធ្វើបានទៅលើពួកគេដើម្បីជំរុញឱ្យពួកគេចូលរួមយ៉ាងមានប្រសិទ្ធិភាពនៅក្នុងនីតិវិធី។[12]



- **បង្ការនូវការដកហូតតាមទំនើងចិត្ត និងខុសច្បាប់នៃសេរីភាពរបស់កុមារនៅគ្រប់ពេលវេលា** និងប្រើប្រាស់ការឃាត់ខ្លួន ឃុំខ្លួន ឬដាក់ពន្ធនាគាររបស់កុមារអនុលោមតាមច្បាប់ និងជាមធ្យោបាយចុងក្រោយសម្រាប់រយៈពេលខ្លីតែប៉ុណ្ណោះ។[13] ការឃុំខ្លួនកុមារទំនាស់នឹងច្បាប់**ត្រូវដាច់ដោយឡែកពីនីតិជន លុះត្រាតែវិធានការនេះចាត់ទុកថាជាឧត្តមប្រយោជន៍របស់កុមារទាំងក្នុងពន្ធនាគារដទៃជាជាងនីតិជន ឬបំបែកហេដ្ឋារចនាសម្ព័ន្ធផ្សេងគ្នា ឬក៏មជ្ឈមណ្ឌលសម្រាប់កុមារ និងមានគោលការណ៍ និងការអនុវត្តជាក់លាក់**ដើម្បីការពារភាពជាមនុស្ស និងសមត្ថភាពរបស់ពួកគេនៅពេលអនាគត ដើម្បីរួចផុតពីបទល្មើស និងភាពជួបជុំម្តងទៀត។ ការឃុំខ្លួនកុមារ ត្រូវតែឱ្យពួកគេ**រក្សាទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ**តាមរយៈការឆ្លើយឆ្លង ការជួបសួរសុខទុក្ខ លើកលែងតែកាលៈទេសៈចាំបាច់ និងត្រូវឃុំខ្លួននៅទីកន្លែងដែលជិតបំផុតពីផ្ទះគ្រួសាររបស់ពួកគេ។[14]



- **ហាមឃាត់ការកាត់ទោសប្រហារជីវិត និងការដាក់ពន្ធនាគារអស់មួយជីវិត**ដោយមិនមានលទ្ធភាពនៃការដោះលែងសម្រាប់កុមារ[15]គឺប្រឆាំងទៅនឹងគោលបំណងនៃការលើកកម្ពស់ការធ្វើសមាហរណកម្មកុមារទៅក្នុងសង្គមវិញ ដែលសម្រេចឱ្យបានតាមរយៈការផ្តល់យុត្តិធម៌កុមារ។



---

[11] មាត្រា ១២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក)។

[12] គណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ កថាខណ្ឌ ៥៧, និង ៥៨។

[13] មាត្រា ៣៧(គ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក)។

[14] មាត្រា ៣៧ (គ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក); គណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ កថាខណ្ឌ ១០៤ ទៅដល់ ១០៨។

[15] មាត្រា ៣៧ (ក) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក)។

រដ្ឋក៏ត្រូវបានលើកទឹកចិត្តឱ្យ**បង្កើតប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់កុមារសមស្រប** ដោយមានច្បាប់ នីតិវិធី អាជ្ញាធរ និង**ស្ថាប័នដែលអនុវត្តជាពិសេសចំពោះកុមារ** ដើម្បីធានាថាកុមារទទួលបានការប្រព្រឹត្តចំពោះខ្លួនក្នុងលក្ខណៈមួយដែលស្របទៅនឹងអាយុរបស់ពួកគេ។[16] តុលាការកុមារអាចជាអង្គភាពដាច់ដោយឡែកនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់ខ្លួន ឬជាផ្នែកមួយនៃតុលាការមានស្រាប់ គួរតែបង្កើតឡើង។ ប្រសិនបើមិនអាចបង្កើតបានទេ រដ្ឋយ៉ាងហោចណាស់គួរតែចាត់តាំងចៅក្រមជំនាញសម្រាប់ដោះស្រាយសំណុំរឿងយុត្តិធម៌កុមារនេះ។[17]

រដ្ឋត្រូវតែ**កំណត់អាយុអប្បបរមាសម្រាប់ទំនួលខុសត្រូវព្រហ្មទណ្ឌ** របស់កុមារស្របតាមភាពចាស់ទុំនៃរូបកាយ និងផ្លូវចិត្តរបស់កុមារ[18] ដែលនៅក្រោមអាយុកំណត់នេះ កុមារមិនអាចទទួលខុសត្រូវ ព្រហ្មទណ្ឌដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌបានទេ។ ប្រសិនបើមានមន្ទិលសង្ស័យអំពីអាយុរបស់ជនជាប់ចោទ ជនជាប់ចោទត្រូវទទួលបានអត្ថប្រយោជន៍ពីវិមតិសង្ស័យ និងអត្ថប្រយោជន៍ពីប្រព័ន្ធយុត្តិធម៌កុមារ។[19]

នៅពេលអាចអនុវត្តបាន និងនៅពេលសមស្រប រដ្ឋត្រូវតែ**កំណត់អាទិភាពវិធានការ ដែលមិនតម្រូវឱ្យមានការអនុវត្តដំណើរការនីតិវិធីព្រហ្មទណ្ឌជាជម្រើសមកលើកុមារ** ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ (ឧទាហរណ៍ វិធានការនេះ រួមមាន ការថែទាំ របៀបណែនាំ និងវិធានការត្រួតពិនិត្យ ការពិគ្រោះយោបល់ ការព្យួរទោសសាកល្បង។ល។)។ វិធានការទាំងនេះត្រូវតែសមស្របតាមសុខុមាលភាពរបស់កុមារ និងមានសមាមាត្រទៅនឹងកាលៈទេសៈ និងបទល្មើសដែលពួកគេបានប្រព្រឹត្ត។[20]

ដើម្បីធានានូវ**ការផ្តល់យុត្តិធម៌កុមារឱ្យបានត្រឹមត្រូវ គ្រប់អ្នកវិជ្ជាជីវៈដែលធ្វើការងារ ជាមួយនឹង កុមារ ឬពាក់ព័ន្ធនឹងយុត្តិធម៌កុមារ** (ឧទាហរណ៍ មន្ត្រីនគរបាល ព្រះរាជអាជ្ញា ចៅក្រម មន្ត្រីគ្រប់គ្រងការព្យួរទោសសាកល្បង ។ល។) ត្រូវ**ឆ្លងកាត់ការបណ្តុះបណ្តាលមានលក្ខណៈជាប្រព័ន្ធ និងជាបន្តបន្ទាប់** អំពីកុមារ ការអភិវឌ្ឍរូបកាយ ចិត្តសាស្ត្រ ផ្លូវចិត្ត និងសង្គម ក៏ដូចជាអំពីតម្រូវការពិសេសរបស់កុមារងាយរងគ្រោះបំផុត ។[21]

---

[16] មាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក); គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌ ៤៣។

[17] គណៈកម្មាធិការសិទ្ធិកុមារ "សេចក្តីពន្យល់ទូទៅ លេខ ២៤ កថាខណ្ឌ ១១៩; គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ ៣២ កថាខណ្ឌ ៩២ ដល់ ៩៥។

[18] មាត្រា ៤០(ក) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក); គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ ៣២ កថាខណ្ឌ ៤៣។

[19] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ការបោះពុម្ពផ្សាយលើកទី ២ (ឆ្នាំ០១៤) ទំព័រ ១៩២, /https://www.amnesty.org/en/documents/pol30/002/2014/en។

[20] មាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក); គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅ លេខ ៣២ កថាខណ្ឌ ៤៤។

[21] គណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅ លេខ ១២ ។

## ២. ក្របខ័ណ្ឌច្បាប់

### ២.១. ច្បាប់អន្តរជាតិ

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក")** ចែងអំពីបញ្ញត្តិជាក់លាក់សម្រាប់ការប្រព្រឹត្តចំពោះកុមារនៅក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ លិខិតុបករណ៍អន្តរជាតិទាំងនេះ គឺត្រូវបានដាក់បញ្ចូលដោយផ្ទាល់នៅក្នុងច្បាប់កម្ពុជា តាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា៖



- **មាត្រា ១៤(៤) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖** *"នីតិវិធីអនុវត្តចំពោះយុវជន-យុវនារីដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ។"*
- **មាត្រា ២៤ (១)នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ៖** *"១. កុមារគ្រប់រូបមានសិទ្ធិទទួលបានវិធានការការពារ តម្រូវនឹងស្ថានភាពរបស់ខ្លួនជាកុមារ ពីសំណាក់គ្រួសាររបស់ខ្លួន សង្គម និងរដ្ឋដោយគ្មានការរើសអើងពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ឬកំណើតឡើយ [...]។*
- **មាត្រា ១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖** *"[...], កុមារត្រូវគេទទួលស្គាល់ថាជាមនុស្សមានអាយុក្រោមដប់ប្រាំបីឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ។"*




- **មាត្រា ៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖** *"១. នៅក្នុងវិធានការទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជន ឬសាធារណៈទទួលការៈខាងសុខុមាលភាពសង្គម ឬដោយតុលាការ ឬអាជ្ញាធររដ្ឋ ឬអង្គការនីតិបញ្ញត្តិ ២.រដ្ឋភាគីសន្យាធានាដល់កុមារនូវការការពារ និងការថែទាំចាំបាច់ ដើម្បីសុខុមាលភាពរបស់កុមារ ដោយយកមកគិតនូវសិទ្ធិ និងករណីកិច្ចរបស់ឪពុក-ម្តាយ អ្នកអាណាព្យាបាល ឬបុគ្គលផ្សេងទៀតដែលទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះកុមារ និងដើម្បីសម្រេចទិសដៅនេះ រដ្ឋភាគីត្រូវចាត់វិធានការខាងនីតិប្បញ្ញត្តិ និងរដ្ឋបាលដែលសមស្របទាំងអស់។ [...].*
- **មាត្រា ១២ (២) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖** *"[...] ក្នុងទិសដៅនេះ កុមារត្រូវបានផ្តល់ជាពិសេស នូវឱកាសត្រូវបានការស្តាប់នៅក្នុងនីតិវិធីតុលាការ និងរដ្ឋបាលដែលពាក់ព័ន្ធនឹងកុមារ ទោះដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ឬស្ថាប័នសមស្របណាមួយ ស្របតាមបទប្បញ្ញត្តិនីតិវិធីច្បាប់ជាតិ។"*
- **មាត្រា ៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖** *" រដ្ឋភាគីត្រូវធានាថា៖ (ក) គ្មានកុមារណាម្នាក់ ត្រូវទទួលរងទារុណកម្ម ឬការប្រព្រឹត្តទៅលើខ្លួន ឬការផ្តន្ទាទោស ឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។ ទោសប្រហារជីវិត ឬដាក់ពន្ធនាគារអស់មួយជីវិត ដោយគ្មានលទ្ធភាពដោះលែង មិនត្រូវដាក់ចំពោះបទល្មើសដែលប្រព្រឹត្តដោយមនុស្សមានអាយុក្រោមដប់ប្រាំបីឆ្នាំឡើយ។*

(ខ) គ្មានកុមារណាម្នាក់ ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬតាមអំពើចិត្តឡើយ។ ការចាប់ខ្លួន ការឃាត់ឬការឃុំខ្លួន ឬការដាក់ពន្ធនាគារ កុមារ ត្រូវធ្វើស្របតាមច្បាប់ និងត្រូវប្រើសម្រាប់តែវិធានការចុងក្រោយ និង សម្រាប់រយៈពេលខ្លីបំផុតប៉ុណ្ណោះ។

(គ) កុមារណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្ត មកលើខ្លួន ប្រកបដោយមនុស្សធម៌ ដោយការគោរពចំពោះសេចក្តីថ្លៃថ្នូរពីកំណើតរបស់មនុស្ស និងគិតដល់សេចក្តីត្រូវការរបស់មនុស្សក្នុងវ័យរបស់ខ្លួន។ ជាពិសេស រាល់កុមារដែលត្រូវបានដកហូតសេរីភាព ត្រូវដាក់ឱ្យនៅដោយឡែកពីមនុស្សពេញវ័យ លើកលែងតែឧត្តមប្រយោជន៍របស់កុមារ មិនតម្រូវឱ្យធ្វើដូច្នេះ ហើយកុមារទាំងនេះត្រូវមានសិទ្ធិទាក់ទងជាមួយគ្រួសារខ្លួន តាមរយៈការឆ្លើយឆ្លង និងការជួបសួរសុខទុក្ខ លើកលែងតែក្នុងកាលៈទេសៈពិសេសចេញ។

(ឃ) កុមារដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិទទួលបានភ្លាមៗ នូវជំនួយផ្នែកច្បាប់ និងជំនួយសមស្របផ្សេងៗទៀត និងមានសិទ្ធិជំទាស់ភាពស្របច្បាប់នៃការដកហូតសេរីភាពខ្លួន នៅចំពោះមុខតុលាការ ឬអាជ្ញាធរមាន សមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង និងមានសិទ្ធិទទួលបានសេចក្តីសម្រេចយ៉ាងឆាប់លើចំណាត់ការបែបនេះ។"

- **មាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖** *"១. រដ្ឋភាគីទទួលស្គាល់ថា កុមារដែលជាប់សង្ស័យ ជាប់ចោទ ឬដែលគេស្គាល់ថាបានល្មើសនឹងច្បាប់ព្រហ្មទណ្ឌ មានសិទ្ធិទទួលបាននូវការប្រព្រឹត្តមកលើខ្លួន តាម លក្ខណៈមួយដែលលើកស្ទួយសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់កុមារដែលពង្រឹងកុមារ ឱ្យចេះគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់ អ្នកដទៃ ដោយគិតអំពីអាយុរបស់កុមារ ព្រមទាំងពីអត្ថប្រយោជន៍នៃការលើកស្ទួយ ការធ្វើសមាហរណកម្មកុមារមកក្នុងសង្គមវិញ និងឱ្យកុមារបំពេញតួនាទីស្ថាបនានៅក្នុង សង្គម។*

*២. ក្នុងទិសដៅនេះ និងដោយគិតទៅនឹងបទប្បញ្ញត្តិនៃលិខិតុបករណ៍អន្តរជាតិ ដែលពាក់ព័ន្ធ រដ្ឋភាគីត្រូវធានាជាពិសេសថា៖*

*(ក) គ្មានកុមារណាម្នាក់ ត្រូវជាប់សង្ស័យ ជាប់ចោទ ឬទទួលស្គាល់ ថាបានល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ដោយសារអំពើ ឬការមិនគោរពតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ មិនបានហាមឃាត់នៅពេលអំពើ ឬការខកខាននោះត្រូវបានប្រព្រឹត្ត។*

*(ខ) កុមារដែលជាប់សង្ស័យ ឬជាប់ចោទថា បានរំលោភច្បាប់ព្រហ្មទណ្ឌ យ៉ាងហោចណាស់ ត្រូវទទួលបាននូវការធានាដូចតទៅ៖*

*(i) ចាត់ទុកកុមារថាឥតទោស រហូតទាល់តែពិរុទ្ធភាពត្រូវបានបង្ហាញស្របតាមច្បាប់។*

*(ii) ប្រាប់កុមារភ្លាមៗ និងដោយផ្ទាល់ អំពីបទចោទមកលើខ្លួន ឬបើសមស្រប ប្រាប់តាមរយៈឪពុក-ម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់ កុមារ និងផ្តល់ជំនួយផ្នែកច្បាប់ ឬជំនួយសមស្របផ្សេងទៀត សម្រាប់ការ រៀបចំ និងដាក់ចេញនូវមធ្យោបាយការពារខ្លួន។*

(iii) ទទួលបានការដោះស្រាយបញ្ហាដោយគ្មានការយឺតយ៉ាវពីសំណាក់ អាជ្ញាធរ ឬស្ថាប័នតុលាការ ដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀងនៅ ក្នុងការជំនុំជម្រះដ៏យុត្តិធម៌មួយ ដែលសមស្រប ទៅតាមច្បាប់ និងដោយមានជំនួយផ្នែកច្បាប់ ឬជំនួយសមស្របផ្សេងៗទៀត លើកលែងតែមិនបាន ផ្តល់ជាឧត្តមប្រយោជន៍របស់កុមារនោះ ជាពិសេស ត្រូវគិតគូរទៅលើអាយុ ឬស្ថានភាពរបស់កុមារ ដោយមានវត្តមានរបស់ឪពុក-ម្តាយឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារផង។

(iv) មិនត្រូវទទួលរងការបង្ខិតបង្ខំឱ្យផ្តល់សក្ខីកម្ម ឬសារភាពកំហុសឡើយ។ ត្រូវសួរចម្លើយ ឬឱ្យ មានការសួរចម្លើយសាក្សី និងត្រូវឱ្យ មានការចូលរួម និងការសួរចម្លើយសាក្សីដោះបន្ទុកក្នុងនាម កុមារក្រោមលក្ខខណ្ឌសមភាព។

(v) បើយល់ឃើញថាបានរំលោភច្បាប់ព្រហ្មទណ្ឌ កុមារអាចសុំឱ្យអាជ្ញាធរ ដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ឬតុលាការថ្នាក់លើ ពិនិត្យឡើងវិញលើសេចក្តីសម្រេចនេះនិងលើវិធានការ ណាមួយដែលដាក់បង្ខំ តាមសេចក្តីសម្រេចនេះដោយស្របតាមច្បាប់។

(vi) ទទួលបានដោយឥតគិតថ្លៃនូវជំនួយពីអ្នកបកប្រែ បើកុមារមិនអាច យល់ ឬ និយាយភាសា ដែលត្រូវបានប្រើនោះទេ។

(vii)ត្រូវគោរពយ៉ាងពេញលេញនូវសិទ្ធិនៃជីវិតឯកជនរបស់កុមារនៅក្នុងគ្រប់ដំណាក់កាលនៃ នីតិវិធី។

៣. រដ្ឋភាគី ត្រូវខិតខំលើកស្ទួយការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នសម្រាប់អនុវត្ត ជាពិសេសទៅ លើកុមារដែលជាប់សង្ស័យ ជាប់ចោទ ឬទទួលស្គាល់ថា បានរំលោភច្បាប់ព្រហ្មទណ្ឌ និងជាពិសេស៖

(ក) ត្រូវកំណត់អាយុអប្បបរមាដែលក្រោមអាយុអប្បបរមានេះ កុមារ ត្រូវបានសន្មតជាមុនថា ពុំមាន សមត្ថភាពរំលោភច្បាប់ព្រហ្មទណ្ឌឡើយ។

(ខ) ក្នុងករណីសមស្រប និងចាំបាច់ វិធានការសម្រាប់ដោះស្រាយ ចំពោះកុមារទាំងនេះ មិនចាំបាច់ ឆ្លងកាត់នីតិវិធីតុលាការឡើយ ឱ្យតែធានា និងគោរពបានពេញលេញនូវសិទ្ធិមនុស្ស និងការធានា ខាងផ្លូវច្បាប់ ។

៤. ចំណាត់ការមួយចំនួនដូចជា ការថែទាំ របៀបណែនាំ និងដឹកតាមដាន និងត្រួតពិនិត្យ ការ ពិគ្រោះយោបល់ ការសាកល្បង ការថែទាំដោយឪពុក-ម្តាយធម៌ កម្មវិធីអប់រំ និងបណ្តុះបណ្តាល វិជ្ជាជីវៈ និងមធ្យោបាយផ្សេងៗទៀតជំនួស ការថែទាំតាមស្ថាប័ន ត្រូវធ្វើឱ្យមាន ដើម្បីធានាថា កុមារទទួលបាននូវចំណាត់ ការដែលសមស្របចំពោះសុខុមាលភាពរបស់ខ្លួន និងមានសមា មាត្រទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស។”

## ២.២. ច្បាប់ជាតិ

**រដ្ឋធម្មនុញ្ញកម្ពុជា** មានចែងអំពីការការពារសិទ្ធិកុមារ។ **ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** និង **ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ")** ចែងអំពីបញ្ញត្តិមួយចំនួនពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់។ ជាចុងក្រោយ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលបានអនុម័តនៅឆ្នាំ២០១៦ ចែងអំពីវិធានជាក់លាក់សម្រាប់ការប្រព្រឹត្តចំពោះកុមារដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

- **មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ៖** *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ [...]"*



- **មាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញ៖** *"រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ [...]។"*
- **មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ៖** *"អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើកុមារអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈ របស់កុមារតម្រូវ។"*
- **មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ៖** *"វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមាន ដូចតទៅ៖ ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះស័ក្តិសមនឹងទំនុកចិត្ត។ ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន។ ការប្រគល់អនីតិជនឱ្យ ទៅអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។ ការប្រគល់កុមារឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។ ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។"*



- **មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"កាលណាបុគ្គលដែលត្រូវបានឃាត់ ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មាន តាមគ្រប់មធ្យោបាយដល់ឪពុក ម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននោះ។"*



- **មាត្រា ២១២ និង២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖**វិធានជាក់លាក់ពាក់ព័ន្ធនឹងការឃុំខ្លួនអនីតិជន។
- **ច្បាប់ស្តីពីយុត្តិធម៌អនីតិជន៖** បញ្ញត្តិនៃច្បាប់នេះមានគោលបំណង ការពារសិទ្ធ និង ឧត្តមប្រយោជន៍របស់អនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។



## ៣. សារៈសំខាន់

កុមារគឺជាចំណែកមួយនៃជន**ងាយរងគ្រោះ**បំផុត ដោយសារតែអាយុ និងការអភិវឌ្ឍរបស់ពួកគេ។ **ឧត្តមប្រយោជន៍ និងសុខុមាលភាព**របស់ពួកគេ ត្រូវតែជាការពិចារណាចម្បងនៅ**គ្រប់វិធានការទាំងអស់** រួមទាំងវិធានការដែលអនុវត្តដោយស្ថាប័នរដ្ឋ ឬស្ថាប័នរដ្ឋាភិបាលឯកជន និងតុលាការ។[22]

កត្តាដែលកាន់តែសំខាន់ជាងនេះដើម្បីផ្ដល់នូវ ការការពារពិសេសដល់កុមារដែលត្រូវឆ្លងកាត់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីផ្ដល់**ជំនួយដល់ពួកគេនៅពេញមួយដំណើរការនីតិវិធីផ្លូវច្បាប់ដែលអាចជាបទពិសោធន៍មួយប៉ះទង្គិចផ្លូវចិត្ត ការពារសិទ្ធិរបស់ពួកគេ** និងចៀសវាង**ការធ្វើឱ្យមានស្លាកស្នាម**។ ដូចនេះ **យុត្តិធម៌កុមារ ដែលមានវិធាន និងវិធានការគ្រប់គ្រាន់ប្រព្រឹត្តចំពោះកុមារទំនាស់នឹងច្បាប់** ដោយពិចារណាទៅលើ**អាយុ ការអភិវឌ្ឍ និងភាពចាស់ទុំ**របស់ពួកគេ គឺមានសារៈសំខាន់។ ប្រការនេះជានាថា ជីវិតរបស់កុមារទំនាស់នឹងច្បាប់ គឺមិនទទួលរងផលប៉ះពាល់អចិន្ត្រៃយ៍អំពីអំពើដែលបានប្រព្រឹត្តនៅអាយុដែលពួកគេអាចនៅក្មេងពេកក្នុងការយល់ដឹង ឬក្មេងពេកក្នុងការគ្រប់គ្រងសកម្មភាពរបស់ខ្លួន។ យុត្តិធម៌កុមារ គឺមានសារៈសំខាន់ក្នុងការលើកកម្ពស់**ស្មារតីនៃការគោរពសេចក្ដីថ្លៃថ្នូរ និងតម្លៃរបស់កុមារ ពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ និងធានាការធ្វើសមាហរណកម្មមកក្នុងសង្គមវិញដោយជោគជ័យ ដែលកុមារអាចបំពេញតួនាទីបែបស្ថាបនានៅពេលអនាគត**។[23]

ប្រសិនបើកុមារទំនាស់នឹងច្បាប់មិនទទួលបានអត្ថប្រយោជន៍ពីការការពារពិសេសនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេឱ្យបានគ្រប់គ្រាន់តាមអាយុ និងភាពចាស់ទុំ ពួកគេអាចនឹងទទួលរងពីរបួសស្នាម និងទទួលរងផលវិបាកនៃបទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តនៅអាយុវ័យក្មេងអស់រយៈពេលពេញមួយជីវិតរបស់ពួកគេ ដូច្នេះបញ្ហានេះនឹងរារាំងពួកគេពីការស្ដារនីតិសម្បទាដោយជោគជ័យទៅក្នុងសង្គមវិញ។

## ៤. ដែនកំណត់



យុត្តិធម៌កុមារ**មិនការលើកលែងដែលបង្កឱ្យមានប៉ះពាល់ដល់កុមារ និងគឺអនុវត្តចំពោះកុមារទាំងអស់ដែលមានអាយុក្រោម ១៨ ឆ្នាំ នៅពេលត្រូវបានចោទប្រកាន់ពីបទល្មើស** ដើម្បីចៀសវាងការរើសអើងនោះទេ។ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិតម្រូវថា រដ្ឋមិនត្រូវកម្រិតទៅលើអនុវត្តច្បាប់ស្ដីពីយុត្តិធម៌កុមារ និងនីតិវិធីចំពោះកុមារដែលមានអាយុក្រោម ១៦ ឆ្នាំ ឬទាបជាងនេះ ឬជាពិសេសទាមទារឱ្យប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌប្រព្រឹត្តចំពោះកុមារអាយុ ១៦ ឬ ១៧ ឆ្នាំ ដែលប្រព្រឹត្តបទល្មើស ដូចគ្នាទៅនឹងនីតិជនផងដែរ ដើម្បីចៀសវាងពីការរើសអើងទៅលើកុមារទាំងនោះ។ ប៉ុន្តែការអនុវត្តយុត្តិធម៌កុមារចំពោះបុគ្គលដែលមានអាយុចន្លោះពី ១៨ និង ២១ ឆ្នាំត្រូវបានទទួលយកថាជាវិធានទូទៅ ឬករណីពិសេស។[24]

---

[22] មាត្រា ៣ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

[23] មាត្រា ៤០ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

[24] គណៈកម្មាធិការសិទ្ធិកុមារ សេចក្ដីពន្យល់ទូទៅលេខ ២៤ កថាខណ្ឌ ៣៨។

## ៥. សំណួរ

**សូមជ្រើសរើសចម្លើយតែមួយគត់ដែលអ្នកគិតថាត្រឹមត្រូវ៖**

១. តើសកម្មភាពណាខ្លះខាងក្រោមនេះ រំលោភលើសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់?

☐ក. ឃុំឃាំងកុមារទំនាស់ជានឹងច្បាប់ជាមួយនីតិជន

☐ខ. ជំនុំជម្រះរឿងក្តីកុមារទំនាស់ជាមួយនឹងច្បាប់ជាសាធារណៈ

☐គ. កុមារទំនាស់ជាមួយនឹងច្បាប់មានឱកាសចូលរួមសវនាការក្នុងដំណើរការនីតិវិធីដោយផ្ទាល់ និងតាមរយៈតំណាង

☐ឃ. កុមារស្លៀកពាក់ឯកសណ្ឋានពន្ធនាគារនៅពេលសវនាការរបស់ពួកគេ

☐ង. ក, ខ និងឃ

២. តើច្បាប់ជាតិណាមានគោលបំណងការពារជាក់លាក់នូវសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារដែលប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ?

☐ក. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ☐ខ. រដ្ឋធម្មនុញ្ញកម្ពុជា

☐គ. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ☐ឃ. ក្រមព្រហ្មទណ្ឌកម្ពុជា

៣. តើមូលហេតុអ្វីត្រូវផ្តល់ការការពារពិសេសដល់កុមារទំនាស់នឹងច្បាប់?

☐ក. ដើម្បីជួយពួកគេពីការប៉ះពាល់ផ្នែកផ្លូវចិត្តដោយសារដំណើរការនីតិវិធីច្បាប់ និងការពារឧត្តមប្រយោជន៍របស់ពួកគេ ក៏ដូចជាសុខុមាលភាពរបស់ពួកគេផងដែរ។

☐ខ. ដើម្បីលើកកម្ពស់នូវសេចក្តីថ្លៃថ្នូរ និងភាពមានតម្លៃ ព្រមទាំងធានានូវសមាហរណកម្មដោយជោគជ័យ

☐គ. ការពារសិទ្ធិមនុស្សរបស់គេ និងបង្ការពីការមាក់ងាយទៅលើពួកគេ។ ☐ឃ. ក, ខ និងគ

៤. សវនាការរឿងក្តីកុមារទំនាស់នឹងច្បាប់ ត្រូវតែជំនុំជម្រះជាអសាធារណៈជាគោលការណ៍ទូទៅ និងជាសាធារណៈក្នុងលក្ខខណ្ឌលើកលែង។ សាលក្រម ឬសាលដីកា ត្រូវតែប្រកាសជាសាធារណៈ ប៉ុន្តែមិនឱ្យសាធារណជនស្គាល់អត្តសញ្ញាណរបស់កុមារឡើយ។

☐ក. ខុស ☐ខ. ត្រូវ

៥. អាជ្ញាធរ និងអ្នកសារព័ត៌មាន អាចបង្ហាញព័ត៌មានដែលគេអាចកំណត់អត្តសញ្ញាណរបស់កុមារទំនាស់នឹងច្បាប់ពីបទព្រហ្មទណ្ឌបានក្នុងដំណើរនីតិវិធី។

☐ក. ខុស ☐ខ. ត្រូវ

៦. តើកុមារអាយុ១៣ឆ្នាំ អាចត្រូវបានចាប់ខ្លួន ឃុំខ្លួន និងជំនុំជម្រះពីបទល្មើសព្រហ្មទណ្ឌបានដែរឬទេ យោងតាមច្បាប់ប្រទេសកម្ពុជា?

☐ក. ចាស/បាទ ☐ខ. អត់បាន

៧. ក្នុងករណីមានភាពមិនច្បាស់លាស់អំពីអាយុរបស់កុមារ ដូចនេះកុមារទំនាស់នឹងច្បាប់ពីបទព្រហ្មទណ្ឌត្រូវទទួលប្រយោជន៍ពីប្រការនេះ និងអត្ថប្រយោជន៍នៃប្រព័ន្ធយុត្តិធម៌កុមារ។

☐ក. ខុស ☐ខ. ត្រូវ

# គន្ថនិទ្ទេស

## ១. ច្បាប់ប្រទេសកម្ពុជា

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣ វិសោធនកម្ម), https://sithi.org/km/laws/2008-02-19-constitution-of-the-kingdom-of-cambodia
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា(ឆ្នាំ២០០៧), https://sithi.org/km/tmp/publication/view/2007-09-03-criminal-procedure-code-of-the-kingdom-of-cambodia-2007
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៩), https://www.sithi.org/km/laws/2014-01-31-criminal-code-2014
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (ឆ្នាំ២០១៦), https://sithi.org/km/laws/2016-06-29-law-on-juvenile-justice
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ(ឆ្នាំ២០១៤) https://www.arbitrationcouncil.org/download/law-on-the-organization-of-courts/?lang=km&wpdmdl=2882&refresh=6350b066d18bd1666232422
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ឆ្នាំ២០១៤), https://www.arbitrationcouncil.org/download/law-on-the-organization-and-functioning-of-supreme-council-of-magistracy/?lang=km&wpdmdl=2876&refresh=6350afd7770ce1666232279
- ច្បាប់ស្តីពីលក្ខនិកៈចៅក្រម និងព្រះរាជអាជ្ញា (ឆ្នាំ២០១៤), https://www.arbitrationcouncil.org/download/law-on-the-status-of-judges-and-prosecutors/?lang=km&wpdmdl=2881&refresh=6350afd76cfa71666232279

## ២. ច្បាប់អន្តរជាតិ

២.១. សន្ធិសញ្ញាអន្តរជាតិ

- មហាសន្និបាតអង្គការសហប្រជាជាតិ, "សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស" (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨) https://www.ohchr.org/sites/default/files/UDHR/Documents/UDHR_Translations/khm.pdf
- មហាសន្និបាតអង្គការសហប្រជាជាតិ, "កតិកាសញ្ញាអន្តរជាតិស្តីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦), https://cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf
- មហាសន្និបាតអង្គការសហប្រជាជាតិ, "អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទារុណកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤) https://cambodia.ohchr.org/sites/default/files/Treaty/CAT-KH.pdf

- មហាសន្និបាតអង្គការសហប្រជាជាតិ, "អនុសញ្ញាស្តីពីសិទ្ធិកុមារ" (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៦៦), https://cambodia.ohchr.org/sites/default/files/book/CRC-Kh.pdf

### ២.២. លិខិតុបករណ៍អន្តរជាតិដទៃទៀត

- គណៈកម្មាធិការ សិទ្ធិកុមារ "សេចក្តីពន្យល់ទូទៅលេខ ២៤ ដែលជំនួសសេចក្តីពន្យល់លេខ ១០ (ឆ្នាំ ២០០៧)៖ សិទ្ធិកុមារនៅក្នុងយុត្តិធម៌អនីតិជន" CRC/C/GC/១០, ២០០៧), https://www.ohchr.org/sites/default/files/Documents/HRBodies/CRC/GC24/GeneralComment24.pdf
- មហាសន្និបាតអង្គការសហប្រជាជាតិ, "អង្គភាពគោលការណ៍ការពារជនគ្រប់រូបស្ថិតនៅក្រោមទម្រង់នៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ," (សេចក្តីសម្រេចលេខ ៤៣/១៧៣, ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៨), https://www.ohchr.org/sites/default/files/Documents/ProfessionalInterest/bodyprinciples.pdf
- គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាតិ, សេចក្តីពន្យល់ទូទៅលេខ ២៤, -បញ្ហាទាក់ទងនឹងអភិរក្សដែលធ្វើលើការផ្តល់សច្ចាប័ន ឬការសុំចូលកតិកាសញ្ញា ឬកពិធីសារបន្ថែម ឬទាក់ទងនឹងសេចក្តីប្រកាសក្រោមមាត្រា ៤១ នៃកតិកាសញ្ញា, "(CCPR/C/21/Rev.1/Add.6, ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៤), https://www.refworld.org/docid/453883fc11.html
- គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាតិ, សេចក្តីពន្យល់ទូទៅលេខ ៣២-មាត្រា១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (CCPR/C/GC/32, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧),
- គណៈកម្មាធិការ សិទ្ធិមនុស្សអង្គការសហប្រជាតិ, សេចក្តីពន្យល់ទូទៅលេខ ៣៥-មាត្រា៩៖ សេរីភាពនិងសន្តិសុខរបស់មនុស្ស (CCPR/C/GC/35, ខែធ្នូ ឆ្នាំ២០១៤), https://www.refworld.org/docid/553e0f984.html

## ៣. សៀវភៅណែនាំពីស្តីការជំនុំជម្រះដោយយុត្តិធម៌

- អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌", ការបោះពុម្ពលើកទីពីរ, (ឆ្នាំ២០១៤), https://sithi.org/km/tmp/publication/view/2014-04-10-fair-trial-manual-published-by-amnesty-international.
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក), "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ", (ខែកុម្ភៈ ឆ្នាំ២០១២), https://sithi.org/km/tmp/publication/view/2012-02-13-fair-trial-rights-and-trial-monitoring-handbook
- OSCE "សេចក្តីសង្ខេបផ្លូវច្បាប់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ" (ឆ្នាំ២០១២) https://www.osce.org/odihr/94214#:~:text=The%20Legal%20Digest%20of%20International,of%20OSCE%20trial%20monitoring%20operations

## ៤. ករណីសិក្សា

- តុលាការសិទ្ធិមនុស្សអឺរ៉ុប, "សំណុំរឿង Barberà, Messegué និង Jabardo ទល់នឹង ប្រទេសអេស្ប៉ាញ," ១០៥៩០/៨៣ (ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៨៨), https://cambodia.ohchr.org/sites/default/files/echrsource/Barber%c3%a0,%20Messgu%c3%a9%20&%20Jabardo%20v.%20Spain%20%5b6%20Dec%201988%5d%20%5bEN%5d.pdf
- តុលាការសិទ្ធិមនុស្សអឺរ៉ុប, "សំណុំរឿង Telfner ទល់នឹង ប្រទេសអូទ្រីស," ៣៣៥០១/៩៦ (ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១), https://hudoc.echr.coe.int/eng#{%22fulltext%22:[%22telfner%22],%22languageisocode%22:[%22ENG%22],%22documentcollectionid2%22:[%22GRANDCHAMBER%22,%22CHAMBER%22],%22itemid%22:[%22001-59347%22]}
- តុលាការសិទ្ធិមនុស្សអឺរ៉ុប, "សំណុំរឿង O'Halloran និង Francis ទល់នឹង ចក្រភពអង់គ្លេស," ១៥៨០៩/០២-២៥៦២៤/០២, (ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧), https://hudoc.echr.coe.int/eng#{%22fulltext%22:[%22O'halloran%22],%22languageisocode%22:[%22ENG%22],%22documentcollectionid2%22:[%22GRANDCHAMBER%22,%22CHAMBER%22],%22itemid%22:[%22001-81359%22]}
- តុលាការសិទ្ធិមនុស្សអន្តរអាម៉េរិកាំង, "សំណុំរឿង Ricardo Canese ទល់នឹង ប្រទេសប៉ារ៉ាហ្គាយ (ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤), https://www.corteidh.or.cr/docs/casos/articulos/seriec_111_ing.pdf
- គណៈកម្មាធិការ សិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សេចក្តីសន្និដ្ឋានរួមទៅលើចក្រភពអង្គគ្លេស និងទឹកដីអធិបតេយ្យរបស់ចក្រភពអង្គគ្លេសនៅបរទេស," (UN Doc CCPR/CO/73/UKCCPR/CO/73/UKOT, ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០១), https://www.refworld.org/docid/3cbbec3d2.html
- គណៈកម្មាធិការ សិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សំណុំរឿង Daniel Pinto ទល់នឹង ប្រទេសទ្រីនីដេត និងតូបាហ្គោ," ទំនាក់ទំនងលេខ. ២៣២/១៩៨៧, (CCPR/C/29/D/232/1987, ថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩០), http://hrlibrary.umn.edu/undocs/session39/232-1987.html.
- គណៈកម្មាធិការ សិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សំណុំរឿង David Nicholas ទល់នឹង ប្រទេសអូស្ត្រាលី៖ ទំនាក់ទំនងលេខ ១០៨០/២០០២", (UN Doc CCPR/C/80/D/1080/2002, ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤), http://www.worldcourts.com/hrc/eng/decisions/2004.03.19_Nicholas_v_Australia.htm
- គណៈកម្មាធិការ សិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សំណុំរឿង Gonzalez del Rio ទល់នឹង ប្រទេស ប៉េរូ) ទំនាក់ទំនងលេខ ២៦៣/១៩៨៧, (UN Doc CCPR/C/46/D/263/1987, ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩២), https://juris.ohchr.org/Search/Details/332

- គណៈកម្មាធិការ សិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សំណុំរឿង Jean-Pierre Cochet ទល់នឹង ប្រទេសបារាំង," ទំនាក់ទំនងលេខ ១៧៦០/២០០៨, ((UN Doc CCPR/C/100/D/1760/2008, ឆ្នាំ ២០១០) http://hrlibrary.umn.edu/undocs/1760-2008.html
- គណៈកម្មាធិការ សិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សំណុំរឿង Onoufriou ទល់នឹង ប្រទេសសាយប្រឹស," ទំនាក់ទំនងលេខ ១៦៣៦/២០០៧, (UN Doc. CCPR/C/100/D/1636/2007, ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០), https://www.ccprcentre.org/wp-content/uploads/2012/11/1636-2007-Onoufriou-v.-Cyprus_en.pdf
- គណៈកម្មាធិការ សិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សំណុំរឿង Peart ទល់នឹង ប្រទេសចាម៉ៃកា," ទំនាក់ទំនងលេខ ៤៦៤/១៩៩១ & ៤៨២/១៩៩១, (UN Doc CCPR/C/54/D464/1991, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៥), http://hrlibrary.umn.edu/undocs/html/464-482-1991.html

**៥. ឯកសាររបស់ ម.ស.ម.ក**

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក), "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍៖ របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ – ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០" (ខែតុលា ឆ្នាំ២០២០)
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក), "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍៖ របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ – ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០" (ខែតុលា ឆ្នាំ២០២០)
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក), "ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលសេចក្តីសម្រេចមានសំអាងហេតុ" (ឆ្នាំ២០១៨), https://sithi.org/km/tmp/publication/view/2018-11-15-fair-trial-right-to-the-right-to-reasoned-judgment
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក), "ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង", (ឆ្នាំ២០២០), https://sithi.org/km/tmp/publication/view/2020-11-16-the-right-not-to-be-compelled-to-confess-guilt-or-to-testify-against-oneself
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក), "ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ និងការពន្យល់ប្រាប់សិទ្ធិដល់ជនជាប់ចោទជាស្ត្រី," (ខែមីនា ឆ្នាំ២០២១), https://sithi.org/km/tmp/publication/view/2021-03-04-the-right-to-understand-the-nature-and-cause-of-the-charges-and-explanation-of-rights-for-women-defendants

**៦. ផ្សេងៗ**

- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ("CSD") 'របាយការណ៍ប្រចាំឆ្នាំស្តីពីគម្រោងឃ្លាំមើលតុលាការ', (ខែកុម្ភៈ ឆ្នាំ២០០៧)

- ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, "សេចក្ដីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ សេចក្ដីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក និងអន្តរជាតិសម្រាំង," ការបោះពុម្ពផ្សាយលើកទី២ (ខែធ្នូ ឆ្នាំ២០១៥), https://cambodia.ohchr.org/~cambodiaohchr/sites/default/files/Annotated%20Cambodian%20Code%20of%20Criminal%20Procedure_KHMER%20VERSION%20FINAL.pdf
- ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី១), ជំពូកទី៦, https://www.ohchr.org/Documents/Publications/training9chapter6en.pdf
- ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, "សិទ្ធិមនុស្សនៅក្នុងការគ្រប់គ្រងនៃប្រព័ន្ធយុត្តិធម៌៖ សៀវភៅស្ដីពីសិទ្ធិមនុស្សសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី," ជំពូកទី៧ (ឆ្នាំ២០០៣), https://www.ohchr.org/Documents/Publications/training9chapter7en.pdf.
- អង្គការសហប្រជាជាតិ, "ប្រវត្តិនៃសេចក្ដីប្រកាស," https://www.un.org/en/about-us/udhr/history-of-the-declaration
- Victor Barin Chaharbakhsh និង Seyed Asgher Jafari, "គោលការណ៍អាជ្ញាអស់ជំនុំនៅក្នុងច្បាប់អន្តរជាតិ" ស៊េរីលេខ៧ លេខ៨ ទិន្នានុប្បវត្តិ នៃការត្រួតពិនិត្យការរិះគន់ (ឆ្នាំ២០២០)

# “បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានយុត្តិធម៌!”




ចូលទៅកាន់កម្រងមេរៀន

https://sithi.org/km/fair-trial-rights

ឬ ស្កេនទីនេះ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

Sweden
Sverige

People
Change
the World
Diakonia